**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# មូលហេតុនៃការរំលត់កាតព្វកិច្ច

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ស្រាវជ្រាវឡើងដោយ

និស្សិតឈ្មោះ **លោក. លុន ហានហ្វា**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ស្រី វណ្ណធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំសិក្សាចូលរៀន ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **លុន ហានហ្វា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមគោរពប្រណិបតន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

-លោក **ឪពុក** និង **អ្នកម្តាយ** ជាអ្នកមានគុណដ៏មហាសាលបំផុតចំពោះកូន។ លោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងកូនសព្វបែបយ៉ាង ទាំងស្មារតី ទាំងសំភារៈ ជាពិសេសលោកតែងតែផ្តល់នូវដំបូន្មាន ប្រៀនប្រដៅកូន ដើម្បីឲ្យក្លាយជា កូនល្អ សិស្សល្អ មិត្តល្អ ដែលជាកោសិកាមានតំលៃសំរាប់សង្គមជាតិ។ លោកទាំងទ្វេ ហាក់ដូចជាប្រទីប ដែលបានបំភ្លឺផ្លូវជាដរាបរៀងមកចំពោះកូន ទើបកូនទទួលបានលទ្ធផលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រដោយជោគជ័យបែបនេះ។

-ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសដល់យើងខ្ញុំ បានទទួលនូវចំណេះដឹងបន្ថែមតាមរយៈការសរសេរសារណាបញ្ចប់ការសិក្សានេះ។

-លោកស្រីសាស្ត្រាចារ្យ **ស្រី វណ្ណធី** ដែលមិនត្រឹមតែជួយបង្ហាត់បង្រៀនដល់ខ្ញុំបាទប៉ុណ្ណោះទេ ថែមទាំងចំណាយពេលវេលាដ៏មានតំលៃជួយណែនាំ និងខិតខំបង្ហាញផ្លូវ ក្នុងការចងក្រងជាសារណាបញ្ចប់ការសិក្សានេះឡើង ព្រមទាំងបានផ្តល់នូវឯកសារផ្សេងៗ ដែលខ្ញុំបាទខ្វះខាតលទ្ធភាពក្នុងការស្វែងរកទៀតផង។

-សាកលវិទ្យាធិការរង លោក/លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា និងបណ្ណារ័ក្ស នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកំលាំងកាយចិត្ត ក្នុងការដឹកនាំ គ្រប់គ្រង រៀបចំកម្មវិធីសិក្សាល្អៗ ជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនខ្ញុំបាទឲ្យមានចំណេះដឹង មិនត្រឹមតែផ្នែកទ្រឹស្តីច្បាប់នោះទេ ថែមទាំងផ្តល់នូវបទពិសោធន៍មួយចំនួន ដែលកើតមាននៅក្នុងសង្គមទៀតផង។

-សូមថ្លែងអំណរគុណទៅដល់មិត្តរួមថ្នាក់ $L_4C_1$ ទាំងអស់គ្នា ដែលបានចូលរួមគាំទ្រ និងលើកទឹកចិត្ត និងមានគំនិតកែលំអនៃស្នាដៃសារណារបស់រូបខ្ញុំបាទនេះ។

ឆ្លៀតឱកាសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណ និងគោរពជូនពរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង អស់លោក លោកស្រី ជាសាស្ត្រាចារ្យ និងមន្ត្រីបុគ្គលិក និងមិត្តរួមថ្នាក់ទាំងអស់ សូមទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច និងសមប្រកបដោយពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទសូមគោរពលោក-លោកស្រីសាស្ត្រាចារ្យ ព្រមទាំងស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេសសិស្ស-និស្សិត ជាទីរាប់អាន។

ខ្ញុំបាទមានមោទនភាពខ្លាំងណាស់ ដែលបានធ្វើការសិក្សាស្រាវជ្រាវចងក្រងឯកសារសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ក្រោមប្រធានបទស្ដីពី **មូលហេតុនៃការរំលត់កាតព្វកិច្ច** ដោយសារមើលឃើញពីគុណប្រយោជន៍នៃការសិក្សាស្រាវជ្រាវទាក់ទងនឹងកាតព្វកិច្ចនេះ ដែលជាញឹកញាប់កើតឡើងក្នុងសង្គមជាក់ស្ដែង ព្រមទាំងមានការគាំទ្រ និងលើកទឹកចិត្តបង្ហាត់បង្ហាញយ៉ាងពេញទំហឹងពីសំណាក់លោកស្រីសាស្ត្រាចារ្យ **ស្រី វណ្ណធី** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សារណានេះនឹងចូលរួមវិភាគទានដ៏សំខាន់នៅក្នុងការបំភ្លឺដល់ភាពស្រពិចស្រពិលផ្សេងៗ ទាក់ទងនឹងមូលហេតុនៃការរំលត់កាតព្វកិច្ច ដែលកន្លងមកមិនទាន់បានផ្សព្វផ្សាយឲ្យបានទូលំទូលាយនៅឡើយ ហើយខ្ញុំបាទសង្ឃឹមទៀតថា សារណាមួយនេះនឹងអាចជួយចែករំលែកនូវចំណេះដឹងដល់អ្នកដែលចង់ដឹង ចង់ចេះ និងចង់ស្រាវជ្រាវបន្ថែមលើមូលហេតុនៃការរំលត់កាតព្វកិច្ចនេះ ថាតើការរលត់កាតព្វកិច្ចអាចកើតឡើងដោយសារមូលហេតុអ្វីខ្លះ។ ជាពិសេសសារណានេះក៏ជាឯកសារមួយសម្រាប់និស្សិតជំនាន់ក្រោយៗ ដែលចង់សិក្សាស្រាវជ្រាវ ដើម្បីជាឯកសារជំនួយស្មារតី និងបំពេញឲ្យសេចក្ដីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ ដែលបាននឹងកំពុងជួបប្រទះនូវកង្វះខាតនាពេលបច្ចុប្បន្ននេះ។

យ៉ាងណាមិញ ខ្ញុំបាទក៏សូមអភ័យទោសផងដែរ នូវរាល់កង្វះខាតទាំងឡាយដែលមាននៅក្នុងសារណានេះ ខ្ញុំបាទរងចាំទទួលការរិះគន់ដើម្បីកែលម្អពីសំណាក់មិត្តអ្នកអានទាំងអស់គ្នាគ្រប់វិនាទី។

ជាទីបញ្ចប់ សូមជូនពរដល់អ្នកអានគ្រប់រូបឲ្យជួបប្រទះតែនឹងភាពសុខដុមរមនា រុងរឿង ថ្កុំថ្កើង និងមានសុភមង្គលជានិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ០១


## ជំពូកទី១

## សារសំខាន់អំពីកាតព្វកិច្ច


**១.១.និយមន័យកាតព្វកិច្ច** ........................................ ០៣

**១.២.ប្រភពនៃកាតព្វកិច្ច** ........................................ ០៣

១.២.១.កាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ........................................ ០៣

១.២.១.១.កិច្ចសន្យា ........................................ ០៤

១.២.១.២.សកម្មភាពឯកតោភាគី ........................................ ០៤

១.២.២.កាតព្វកិច្ចដែលកំណត់ដោយច្បាប់ ........................................ ០៥

១.២.២.១.ការគ្រប់គ្រងដោយឈឺឆ្អាល ........................................ ០៥

១.២.២.២.សេចក្តីចម្រើនដោយឥតហេតុ ........................................ ០៨

១.២.២.៣.អំពើអនីត្យានុកូល ........................................ ០៩

**១.៣.ប្រភេទនៃកាតព្វកិច្ច** ........................................ ១១

១.៣.១.កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព និងកាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាព ........................................ ១១

១.៣.១.១.កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព ........................................ ១១

១.៣.១.២.កាតព្វកិច្ចមិនមានគោលបំណងឲ្យធ្វើសកម្មភាព ........................................ ១១

១.៣.២.កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ និងកាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ ........................................ ១២

១.៣.២.១.កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ ........................................ ១២

១.៣.២.២.កាតព្វកិច្ចដែលកំណត់ប្រភេទនៃវត្ថុ ........................................ ១២

១.៣.៣.កាតព្វកិច្ចជាប្រាក់ ........................................ ១៣

១.៣.៤.កាតព្វកិច្ចអនិយ័ត ........................................ ១៣


## ជំពូកទី២

## លក្ខខណ្ឌនៃការរំលត់កាតព្វកិច្ច


**២.១.ការរលត់កាតព្វកិច្ចតាមសកម្មភាពគូភាគី** ........................................ ១៥

២.១.១.ការសង ........................................ ១៥

២.១.១.១.ការសងធម្មតា ..................................................................................................១៥
២.១.១.២.ការសងដោយឧបាទេសកម្ម ......................................................................................១៦
២.១.២. ការទូទាត់ .............................................................................................................១៧
២.១.២.១.លក្ខខណ្ឌ ..............................................................................................................១៧
២.១.២.២. ប្រភេទ ..................................................................................................................១៨
២.១.២.៣. អានុភាព...............................................................................................................១៩
២.១.៣. ការលើកលែងរបស់ម្ចាស់បំណុល...............................................................................១៩
២.១.៣.១.លក្ខខណ្ឌ...............................................................................................................១៩
២.១.៣.២. អានុភាព............................................................................................................... ២០
២.១.៤. នវកម្ម ឬព្យាកុលភាព................................................................................................. ២០
២.១.៥. ការទទួលបន្ទុកហានិភ័យ ............................................................................................ ២២
**២.២.ការរំលត់កាតព្វកិច្ចតាមច្បាប់កំណត់**.................................................................................. ២៤
២.២.១.ការរំលាយកិច្ចសន្យា ................................................................................................... ២៤
២.២.១.១. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ............................................................................ ២៤
២.២.១.២. អានុភាពនៃការរំលាយកិច្ចសន្យា...............................................................................២៧
២.២.២.ការផុតអាជ្ញាយុកាល .................................................................................................... ២៨
២.២.២.១.លក្ខខណ្ឌ ................................................................................................................ ២៨
២.២.២.២.ការផ្អាក និងការបង្អង់អាជ្ញាយុកាល.............................................................................. ២៩
២.២.២.៣.អានុភាព ...................................................................................................................៣១
២.២.៣.ការអនុវត្តសិទ្ធិលុបចោល ...............................................................................................៣២
២.២.៣.១. ការលុបចោលនូវសកម្មភាពដែលធ្វើឡើងដោយជនកម្រិតសមត្ថភាព...៣២
២.២.៣.២.ការលុបចោលដោយមានវិការៈ........................................................................................ ៣៣
២.២.៣.៣.អ្នកដែលមានសិទ្ធិលុបចោល ..........................................................................................៣៦
២.២.៣.៤.អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល ........................................................................ ៣៧
**សេចក្តីសន្និដ្ឋាន**..................................................................................................................៣៨
**អនុសាសន៍**..........................................................................................................................៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាការពិតណាស់ ការរស់នៅក្នុងសង្គមមួយតែងតែមានការប្រាស្រ័យទំនាក់ទំនងគ្នាទៅវិញទៅមកខានពុំបាន ដែលបុគ្គលមួយមិនអាចរស់នៅដោយឯកឯងនោះទេ ត្រូវតែមានទីពំនាក់គ្នាក៏ដូចជាទំនាក់ទំនងសាច់ញាតិ ការដោះដូររបរក្នុងការចិញ្ចឹមជីវិតប្រចាំថ្ងៃ យ៉ាងណាមិញទំនាក់ទំនងនោះទៀតសោត មានបំណងក្នុងការទទួលផលប្រយោជន៍រៀងៗខ្លួន ទៅតាមអ្វីដែលខ្លួនចង់បាន។ ការវិវត្តក្នុងសង្គមបានជំរុញឲ្យទំនាក់ទំនងទាំងនោះ បង្កើតឲ្យមានចំណងគតិយុត្តមួយចងភ្ជាប់នូវករណីកិច្ច និងកាតព្វកិច្ច រវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដែលក្នុងនោះមានម្ខាងជាបុគ្គលមានសិទ្ធិអាចទាមទារឲ្យភាគីម្ខាងទៀតបំពេញ ឬមិនបំពេញតាវកាលិក ហៅថាម្ចាស់បំណុល និងម្ខាងជាបុគ្គលដែលមានកាតព្វកិច្ចចំពោះបុគ្គលនោះ ហៅថាកូនបំណុល។ បន្ថែមពីលើនេះទៀត កាតព្វកិច្ចកើតឡើងពីការព្រមព្រៀងដោយឆន្ទៈរវាងភាគីទាំងសងខាង និងមួយចំនួនមិនមានការយល់ព្រមពីភាគីម្ខាងទៀតទេ តែច្បាប់បានកំណត់ឲ្យបុគ្គលម្ខាងជាកូនបំណុលត្រូវគោរព និងអនុវត្តកាតព្វកិច្ចជាចាំបាច់។

ក្នុងនោះផងដែរ សកម្មភាពទំនាក់ទំនងនោះអាចកើតមាននូវភាពមិនប្រក្រតី ដែលជាហេតុធ្វើឲ្យបាត់បង់នូវផលប្រយោជន៍របស់ភាគីណាមួយ ជាពិសេសខាងផ្នែកសេដ្ឋកិច្ច (ប្រាក់កាស)។ ដូច្នេះដើម្បីការពារនូវផលប្រយោជន៍ ភាគីទាំងពីរត្រូវបង្កើតនូវកិច្ចសន្យាមួយក្នុងទំនាក់ទំនងនោះ ដែលជាកូនសោដ៏សំខាន់ក្នុងការការពារនូវភាពអសកម្មណាមួយ ដែលធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងនោះ។ បើទោះបីជាភាគីទាំងពីរបានព្រមព្រៀងដោយបង្ហាញនូវឆន្ទៈ និងយល់ព្រមតាមលក្ខន្តិកៈដែលបានចែងរួចហើយនោះ តែអ្វីដែលសំខាន់នោះ គឺការអនុវត្តកាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យាតើមានការគោរពតាមលក្ខន្តិកៈ និងគោរពតាមអាជ្ញាយុកាលដែលបានកំណត់ដែរ ឬទេ? ម្យ៉ាងវិញទៀតយើងដឹងហើយថា កាតព្វកិច្ចមិនមែនសុទ្ធតែកើតឡើងតែចំពោះកិច្ចសន្យារវាងភាគីនោះទេ វាអាចកើតឡើងតាមរយៈច្បាប់កំណត់ ដែលមិនមានការយល់ព្រមតាមឆន្ទៈរបស់ភាគីក៏ដោយ តែភាគីម្ខាងដែលជាអ្នកបំពានលើសិទ្ធិ ឬមានគំនិតទុច្ចរិតទៅលើភាគីម្ខាងទៀត ជាមូលហេតុដែលនាំឲ្យភាគីដែលជាជនរងគ្រោះអាចលើកឡើងជាសម្អាងក្នុងការរំលត់កាតព្វកិច្ច ដែលធ្វើឲ្យខ្លួនរួចផុតពីការទទួលខុសត្រូវនោះ។ តើយើងអាចលើកយកមូលហេតុណាខ្លះ ដែលអាចរំលត់នូវកាតព្វកិច្ចបាន។ ហេតុនេះក្នុងនាមប្រទេសកម្ពុជា ជាប្រទេសនីតិរដ្ឋ បានបង្កើតនូវលិខិតបទដ្ឋាននានា ក្នុងការសម្របសម្រួល ដោះស្រាយ និងផ្តល់យុត្តិធម៌ដល់ភាគីទាំងពីរ។

តួយ៉ាងត្រង់ចំណុចនេះផងដែរ ក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ចែងអំពីការរលត់កាតួកិច្ច ដែលបញ្ជាក់

ច្បាស់អំពីមូលហេតុដែលនាំឲ្យមានការរំលត់កាតព្វកិច្ច ដែលក្នុងនោះយើងញែកចេញជាពីរ គឺការរំលត់កាតព្វកិច្ចតាមគូភាគី និងការរំលត់កាតព្វកិច្ចតាមច្បាប់កំណត់។

ការសិក្សាស្រាវជ្រាវលើប្រធានបទ "**មូលហេតុនៃការរំលត់កាតព្វកិច្ច**" មានគោលបំណងដើម្បីបង្ហាញ និងវិភាគឲ្យបានច្បាស់លាស់នូវមូលហេតុនីមួយៗ។ សម្រាប់ដំណើរការស្រាវជ្រាវប្រព្រឹត្តទៅបានល្អ និងអាចវិភាគបានគ្រប់ជ្រុងជ្រោយ គឺផ្តោតសំខាន់ទៅលើក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និងឯកសារជំនួយទាំងផ្នែកទន់ និងផ្នែករឹង របស់សាស្ត្រាចារ្យខាងផ្នែកច្បាប់ដែលមានបទពិសោធន៍។ លើសពីនេះទៅទៀត ឯកសារជំនួយជាច្រើនបានតម្កល់នៅក្នុងបណ្ណាល័យដែលមានពាក់ព័ន្ធទៅនឹងប្រធានបទពោរពេញទៅដោយគំនិតល្អៗ ជាគន្លឹះដើម្បីឲ្យការស្រាវជ្រាវមួយនេះកាន់តែមានភាពល្អប្រសើរថែមមួយកម្រិតទៀត។

ចំពោះសារៈសំខាន់នៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺជាទន់មួយក្នុងការសិក្សាស្វែងយល់ខាងផ្នែករដ្ឋប្បវេណី ជាពិសេសរំលេចនូវមូលហេតុនីមួយៗ ដែលនាំឲ្យមានការរំលត់កាតព្វកិច្ច និងបំពេញបន្ថែមនូវភាពខ្វះខាតនៃឯកសារនាពេលបច្ចុប្បន្នផងដែរ។

ដើម្បីឲ្យមានភាពងាយស្រួល និងបានយល់កាន់តែច្បាស់អំពីប្រធានបទនេះ ខ្ញុំបាទសូមធ្វើការសិក្សាដោយបែងចែកជាពីរជំពូកសំខាន់ៗ គឺ៖ ជំពូកទី១ បកស្រាយពីសារតារអំពីកាតព្វកិច្ច និងជំពូកទី២ បកស្រាយអំពី លក្ខខណ្ឌនៃការរំលត់កាតព្វកិច្ច។

# ជំពូកទី ១
# សាវតារអំពីកាតព្វកិច្ច

# ជំពូកទី១
# សាវតារអំពីកាតព្វកិច្ច

## ១.១.និយមន័យកាតព្វកិច្ច

កាតព្វកិច្ច គឺជាទំនាក់ទំនងដែលចងបុគ្គលពីរនាក់ ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។[1] កាតព្វកិច្ចត្រូវបានគេឲ្យនិយមន័យម្យ៉ាងទៀតថា គឺជាចំណងតាមផ្លូវច្បាប់ ដែលចងបុគ្គលពីរនាក់ ឬច្រើននាក់ ដោយឲ្យបុគ្គលដែលបានកំណត់ ហៅថា "កូនបំណុល" មានករណីកិច្ចមួយចំនួនចំពោះបុគ្គលដទៃទៀតដែលបានកំណត់ ហៅថា "ម្ចាស់បំណុល"។[2]

កាតព្វកិច្ច ដែលត្រូវបានប្រើក្នុងជីវភាពប្រចាំថ្ងៃ មានន័យថាជាអំពើរបស់ជនម្នាក់ដែលត្រូវតែអនុវត្តដើម្បីជាផលប្រយោជន៍របស់ជនដទៃទៀត ប៉ុន្តែការអនុវត្តអំពើទាំងនោះ វាស្តែងឡើងពីផ្នែកមនោសញ្ចេតនា ហើយវាពុំមានលក្ខណៈគតិយុត្តក្នុងការចាប់បង្ខំទេ។[3]

## ១.២.ប្រភពនៃកាតព្វកិច្ច

កាតព្វកិច្ចកើតឡើងដោយកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និងដោយបញ្ញត្តិនៃច្បាប់។

កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និងដោយសកម្មភាពឯកតោភាគី គឺជាកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី។

កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនឥតហេតុ ដោយអំពើអនីត្យានុកូល និងដោយបញ្ញត្តិនៃច្បាប់ គឺជាកាតព្វកិច្ចកំណត់ដោយច្បាប់ ដែលកើតឡើងដោយគ្មានការបង្ហាញឆន្ទៈរបស់ភាគី។[4]

### ១.២.១.កាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី

តាមលិខិតគតិយុត្ត ការបង្ហាញឆន្ទៈសំដៅបង្កើតឲ្យមានអានុភាពគតិយុត្ត។ ការបង្ហាញឆន្ទៈនេះអាចជាទ្វេភាគី (កាតព្វកិច្ចកិច្ចសន្យា) ឬជាឯកតោភាគី។ យ៉ាងណាមិញ កិច្ចសន្យា ត្រូវបង្កើត អានុភាពគតិយុត្តដោយការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យា ដោយធាតុផ្សំនៃការព្រមព្រៀងនេះ គឺការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរ។ ដោយហេតុថា សកម្មភាពឯកតោភាគី ដូចជាអច្ច័យទានជាដើម ធ្វើឡើងដោយ

[1] មាត្រា ៣០៨ នៃក្រមរដ្ឋប្បវេណី ,ឆ្នាំ ២០០៧

[2] សន្ធានុក្រម ផ្នែករដ្ឋប្បវេណីទំព័រទី១

[3] ញឹក វុទ្ធី ,*នីតិកាតព្វកិច្ច* ,ទំព័រទី១

[4] មាត្រា ៣០៩ នៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០០៧

ភាគីតែម្ខាង សកម្មភាពឯកតោភាគីនេះ ត្រូវបង្កើតអានុភាពគតិយុត្តដោយការបង្ហាញឆន្ទៈរបស់ភាគីនោះតែឯង។

គោលការណ៍នៃការបង្ហាញឆន្ទៈ ត្រូវមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីម្ខាងទៀត។ ការបង្ហាញឆន្ទៈ មានអានុភាពភ្លាម ក្នុងករណីដែលការបង្ហាញត្រូវបានធ្វើដោយផ្ទាល់ នៅចំពោះមុខភាគីម្ខាងទៀត ឬតាមរយៈសារអេឡិចត្រូនិចជាដើម។ ក្នុងករណីដែលការបង្ហាញឆន្ទៈ ធ្វើឡើងតាមរយៈលិខិតផ្ញើតាមប្រៃសណីយ៍ ពេលផ្ញើខុសពីពេលទទួលការជូនដំណឹងឯង ការបង្ហាញឆន្ទៈនោះ ត្រូវមានអានុភាពនៅពេលបានដល់ភាគីម្ខាងទៀត។

ការបង្ហាញឆន្ទៈបានដល់ ភាគីម្ខាងទៀតដែលទទួលការបង្ហាញឆន្ទៈនោះ ចាំបាច់ត្រូវមានសមត្ថភាពក្នុងការវិនិច្ឆ័យ។ ហេតុដូច្នេះ ប្រសិនបើភាគីម្ខាងទៀតជាអនីតិជន ការបង្ហាញឆន្ទៈត្រូវធ្វើឡើងចំពោះអ្នកតំណាងដែលច្បាប់បានកំណត់។[5]

### ១.២.១.១.កិច្ចសន្យា

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើតកែប្រែ ឬរំលត់នូវកាតព្វកិច្ច។[6]

តាមនិយមន័យនៃកិច្ចសន្យានេះផងដែរ ត្រូវបានកំណត់តាមទស្សនវិស័យពីរ។ ទស្សនវិស័យទីមួយថា កិច្ចសន្យាគឺជាការត្រូវគ្នានៃឆន្ទៈ ដោយផ្អែកលើគោលការណ៍នៃកិច្ចសន្យារបស់ប្រព័ន្ធច្បាប់ស៊ីវិល។ ទស្សនវិស័យមួយទៀតថា ឆន្ទៈភាគីគឺចង់បង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ច។[7]

-បង្កើតកាតព្វកិច្ចតាមកិច្ចសន្យា៖ "**ក**" មានដី "**ខ**" ចង់ជួល ហើយ "**ក**" និង "**ខ**" ព្រមព្រៀងបង្កើតកិច្ចសន្យាជួល ដោយ "**ក**" មានកាតព្វកិច្ចប្រគល់ដី ហើយ "**ខ**" មានកាតព្វកិច្ចបង់ប្រាក់ ដែលជាថ្លៃឈ្នួល។

-កែប្រែកាតព្វកិច្ចតាមកិច្ចសន្យា៖ កែប្រែ សំដៅទៅលើការផ្លាស់ប្តូរ ដូចជាផ្លាស់ប្តូរអំឡុងពេលជួល ថ្លៃឈ្នួល ពេលវេលាបង់ថ្លៃឈ្នួល ជាដើម។

-រំលត់កាតព្វកិច្ចតាមកិច្ចសន្យា៖ ពេលបង្កើត បានកំនត់អំឡុងពេលជួលរយៈពេល ១០ឆ្នាំ តែក្រោយមកភាគី "ក" និង "ខ" បានព្រមព្រៀងរំលាយកិច្ចសន្យាមុនអាណត្តិ។

### ១.២.១.២.សកម្មភាពឯកតោភាគី

សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់។[8]

---

[5] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០១០,មាត្រា ៣១០

[6] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០០៧

[7] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០១០,មាត្រា ៣១១

[8] មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០០៧

តាមគោលការណ៍ ការផ្លាស់ប្តូរទំនាក់ទំនងកាតព្វកិច្ច (ការបង្កើត ការផ្លាស់ប្តូរ ឬ ការរំលត់កាតព្វកិច្ច) ពុំមានអានុភាព បើគ្មានការព្រមព្រៀងទៅវិញទៅមក ដោយសារការផ្លាស់ប្តូរនេះ នឹងធ្វើឲ្យមានឥទ្ធិពលដល់ម្ចាស់បំណុល ឬកូនបំណុល។ ប៉ុន្តែ ក្នុងករណីដែលកិច្ចសន្យា ឬបញ្ញត្តិច្បាប់ ផ្តល់ឲ្យភាគីណាមួយ នូវសិទ្ធិផ្លាស់ប្តូរទំនាក់ទំនងកាតព្វកិច្ច ការផ្លាស់ប្តូរអាចកើតឡើង បើបុគ្គលដែលត្រូវបានផ្តល់សិទ្ធិនេះអនុវត្តសិទ្ធិរបស់ខ្លួន។[9]

-បង្កើតកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី៖ អច្ច័យទាន ជាសកម្មភាពឯកតោភាគីក្នុងការបង្កើតកាតព្វកិច្ច ប៉ុន្តែកាតព្វកិច្ចត្រូវធ្លាក់ទៅលើសន្តតិជន។ ការទទួលស្គាល់កូន ក៏ជាសកម្មភាពឯកតោភាគីដែរ ពីព្រោះឪពុកមានកាតព្វកិច្ចចិញ្ចឹម និងថែរក្សាកូនដែលជាអនីតិជន ជាដើម។

-ការកែប្រែកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី៖ ការកែប្រែ សំដៅទៅលើការផ្លាស់ប្តូរ។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញរថយន្ត អ្នកលក់បានសន្យាថានឹងយករថយន្តទៅឲ្យអ្នកទិញដល់ផ្ទះ។ នៅក្នុងកិច្ចសន្យា បានផ្តល់សិទ្ធិឲ្យអ្នកទិញអាចផ្លាស់ប្តូរទីកន្លែងនៃការប្រគល់ក្រៅពីក្រុងភ្នំពេញបាន ប្រសិនបើអ្នកទិញទាក់ទងមកអ្នកលក់នៅមុន ៣ថ្ងៃ។ ប្រសិនបើអ្នកទិញទាក់ទងទៅអ្នកលក់ ដោយសូមឲ្យផ្លាស់ប្តូរទីកន្លែងនៃការដឹកជញ្ជូនមកកន្លែងធ្វើការវិញនោះ នេះគឺជាការកែប្រែកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី។

-រំលត់កាតព្វកិច្ចតាមសកម្មភាពឯកតោភាគី៖ ការលុបចោលកិច្ចសន្យា ការរំលាយកិច្ចសន្យា ការលើកលែង ជាសកម្មភាពឯកតោភាគី។

### ១.២.២.កាតព្វកិច្ចដែលកំណត់ដោយច្បាប់

យើងបានដឹងហើយថា កាតព្វកិច្ចកើតឡើងដោយកិច្ចសន្យា និងសកម្មភាពឯកតោភាគី គឺភាគីមានគោលបំណងក្នុងការបង្កើតនូវកាតព្វកិច្ចនោះ ដោយការបង្ហាញឆន្ទៈ។ ដោយឡែក កាតព្វកិច្ចទាំងឡាយណាដែលកើតឡើងដោយសកម្មភាពអនីត្យានុកូល ការគ្រប់គ្រងដោយឈឺឆ្អាល និងសេចក្តីចម្រើនឥតហេតុ ក្នុងករណីកាតព្វកិច្ចទាំងនេះបានបំពេញលក្ខខណ្ឌដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីត្រូវបានហៅថា កាតព្វកិច្ចដែលកំណត់ដោយច្បាប់។ កាតព្វកិច្ចដែលកំណត់ដោយច្បាប់ផ្សេងទៀត ដូចជាកាតព្វកិច្ចបង់ពន្ធ កើតចេញដោយផ្ទាល់ពីបញ្ញត្តិនៃច្បាប់ ក៏ត្រូវបានហៅថាកាតព្វកិច្ចដែលកំណត់ដោយច្បាប់។

#### ១.២.២.១.ការគ្រប់គ្រងដោយឈឺឆ្អាល

ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាប្រភេទនៃកាតព្វកិច្ចមួយដែលកំណត់ដោយច្បាប់ មានន័យ

[9]សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០១០,មាត្រា ៣១២

ថា ការគ្រប់គ្រងដោយឈឺឆ្អាលមិនមែនកើតឡើងដោយឆន្ទៈព្រមព្រៀងរបស់គូភាគីទេ ប៉ុន្តែវាមានអានុភាពបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចដូចការព្រមព្រៀងដែរ។ ជាក់ស្តែង កាតព្វកិច្ចនោះសំដៅលើការអនុវត្តកិច្ចដើម្បីអ្នកដទៃ ទោះបីជាខ្លួនគ្មានករណីកិច្ចតាមច្បាប់ ឬករណីកិច្ចតាមរយៈកិច្ចសន្យាក៏ដោយ ពោលគឺប្រសិនបើបុគ្គលណាម្នាក់បានធ្វើអ្វីមួយក្នុងនាមអ្នកដទៃ ហើយមានឆន្ទៈក្នុងការបំពេញកិច្ចការ ក្នុងគោលបំណងការពារ ឬធ្វើឲ្យមានប្រយោជន៍ដល់បុគ្គលម្នាក់ទៀត នោះបុគ្គលដែលត្រូវបានគេយកអាសា ត្រូវមានកាតព្វកិច្ចចំពោះបុគ្គលនោះវិញ តាមការកំណត់របស់ច្បាប់ដែលត្រូវបានគេហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល។ ក្នុងករណីនេះផងដែរ បុគ្គលដែលអនុវត្តការគ្រប់គ្រងត្រូវបានគេហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល។[10]

ដើម្បីឲ្យការគ្រប់គ្រងដោយឈឺឆ្អាលមានអត្ថិភាពឡើង លុះត្រាតែបំពេញលក្ខខណ្ឌដូចខាងក្រោម៖

**-ការគ្រប់គ្រងដែលធ្វើឡើងដោយគ្មានសិទ្ធិអំណាច** គឺជាការធ្វើសកម្មភាពដោយគ្មានសិទ្ធិអំណាច ប៉ុន្តែទំនាក់ទំនងនៃការគ្រប់គ្រងដោយគ្មានសិទ្ធិអំណាចនេះត្រូវបានការពារដោយច្បាប់ ក្រោមគោលគំនិតថាមនុស្សត្រូវចេះជួយគ្នាទៅវិញទៅមក ទោះបីជាបុគ្គលទាំងនោះគ្មានទំនាក់ទំនងតាម ផ្លូវច្បាប់ក៏ដោយ។ ផ្ទុយទៅវិញប្រសិនបើបុគ្គលដែលធ្វើការគ្រប់គ្រងមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង ដូចនៅក្នុងកិច្ចសន្យាអាណត្តិ នោះការគ្រប់គ្រងដោយឈឺឆ្អាលមិនត្រូវបានកើតឡើងនោះទេ ពីព្រោះភាគីត្រូវអនុវត្តដោយអនុលោមតាមសិទ្ធិអំណាចដែលទទួលបានពីកិច្ចសន្យាទៅវិញ ហើយការគ្រប់គ្រងបែបនេះ មិនមែនជាការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ។[11]

**-ការគ្រប់គ្រងធ្វើឡើងដើម្បីបុគ្គលដទៃ** គឺជាសកម្មភាពមួយដែលអ្នកគ្រប់គ្រងចាំបាច់ត្រូវមានឆន្ទៈគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ។ ប្រសិនបើអ្នកគ្រប់គ្រងគ្មានឆន្ទៈគ្រប់គ្រងទេ សកម្មភាពគ្រប់គ្រងនោះមិនត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលទេ ហើយអ្នកគ្រប់គ្រងមិនអាចទាមទារឲ្យសងវិញនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងនោះ ជាអាទិ៍ទេ។ ប៉ុន្តែសកម្មភាពមួយក៏អាចត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលផងដែរ ប្រសិនបើអ្នកគ្រប់គ្រងមានទាំងឆន្ទៈគ្រប់គ្រងដើម្បីបុគ្គលដទៃ និងដើម្បីសាមីខ្លួន។[12]

**-អ្នកគ្រប់គ្រងចាប់ផ្តើមគ្រប់គ្រងកិច្ចការ** គឺជាសកម្មភាពនៃការអនុវត្តកិច្ច មានន័យថាដើម្បីឲ្យការគ្រប់គ្រងដោយឈឺឆ្អាលមានអត្ថិភាពឡើង អ្នកគ្រប់គ្រងឈឺឆ្អាលត្រូវចាប់ផ្តើមធ្វើសកម្មភាព

[10] មាត្រា៧២៩,កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០០៧

[11] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០១០,មាត្រា ៧២៩

[12] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០១០,មាត្រា ៧២៩

ពោលគឺមិនមែនគ្រាន់តែជាការគិតដោយមិនបានសម្តែងចេញជាសកម្មភាពនោះទេ។ ការចាប់ផ្តើមគ្រប់គ្រងកិច្ចការនេះអាចស្តែងឡើងក្រោមរូបភាពពីរគឺ ការចាប់ផ្តើមសកម្មភាពគតិយុត្ត និងការចាប់ផ្តើមសកម្មភាពដទៃផ្សេងទៀត។ សកម្មភាពគតិយុត្តសំដៅទៅលើកិច្ចសន្យា ឬសកម្មភាពឯកតោភាគី រីឯសកម្មភាពដទៃផ្សេងទៀតសំដៅលើសកម្មភាព ដែលបុគ្គលម្នាក់ចាប់ផ្តើមជួសជុល ឬបំពេញជាដើម។[13]

**-ការគ្រប់គ្រងធ្វើឡើងទៅតាមវិធីដែលសមរម្យជាងគេ ឬផ្អែកតាមឆន្ទៈរបស់បុគ្គលជាសាមីខ្លួន** លក្ខខណ្ឌនេះ គឺការពារដល់សាមីខ្លួនក្នុងការបង់សោហ៊ុយច្រើនហួសហេតុ ដោយការគ្រប់គ្រងដោយឈឺឆ្អាលនោះ ឬក៏ជាការធ្វើឲ្យបានត្រឹមត្រូវ និងយុត្តិធម៌ក្នុងនាមជាអ្នកជួយគ្រប់គ្រងដោយភាពសុចរិត និងឆ្លើយតបទៅនឹងអំពើមនុស្សធម៌ ប្រកបដោយសីលធម៌ និងសមធម៌រវាងបុគ្គលឯកជន។ ជារួម អ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រងឲ្យសមស្របទៅតាមលក្ខណៈនៃការគ្រប់គ្រងនោះ។ ចំពោះវិធីដែលសមរម្យជាងគេ ប្រសិនបើអ្នកគ្រប់គ្រងបានដឹង ឬអាចដឹងអំពីឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងនោះត្រូវគ្រប់គ្រងដោយផ្អែកលើឆន្ទៈនោះ។ ប៉ុន្តែប្រសិនបើអ្នកគ្រប់គ្រងមិនអាចដឹងអំពីឆន្ទៈពិតប្រាកដទេ អ្វីដែលសមស្របជាងគេនោះ គឺត្រូវកំណត់ដោយសត្យានុម័ត។[14]

ក្រោយពីការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបានកើតឡើង អ្នកគ្រប់គ្រងត្រូវបំពេញករណីកិច្ចមួយចំនួនដូចជា ករណីកិច្ចគ្រប់គ្រងតាមវិធីដែលសមរម្យជាងគេ ដើម្បីជាប្រយោជន៍ និងអនុវត្តតាមឆន្ទៈរបស់សាមីខ្លួន ករណីកិច្ចជូនដំណឹង ករណីកិច្ចបន្តការគ្រប់គ្រង ករណីកិច្ចធ្វើសេចក្តីរាយការណ៍ និងករណីកិច្ចទាមទារសំណងចំពោះប្រាក់ដែលបានចំណាយ។

អត្ថប្រយោជន៍ក្នុងការទទួលស្គាល់ការបង្កើតសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាល មាននៅត្រង់ចំណុចថា ប្រសិនបើសកម្មភាពគ្រប់គ្រងមួយរបស់អ្នកគ្រប់គ្រងត្រូវបានចាត់ទុកថាជាស្របច្បាប់ ករណីកិច្ចមួយចំនួននឹងកើតឡើងចំពោះសាមីខ្លួនដោយសារតែសកម្មភាពស្របច្បាប់របស់ អ្នកគ្រប់គ្រងដោយឈឺឆ្អាល។ ក្នុងចំណោមករណីកិច្ចដែលកើតឡើងចំពោះសាមីខ្លួន ករណីកិច្ចមួយដែលទទួលស្គាល់បានដោយមិនមានមន្ទិល គឺករណីកិច្ចសងនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រង។ ចំពោះអ្នកគ្រប់គ្រងវិញ វាគឺជាសិទ្ធិទាមទារឲ្យសងនូវសោហ៊ុយ។[15] ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬអាជីវកម្មរបស់អ្នកគ្រប់គ្រង ចំពោះកិច្ចការដែលនៅតែធ្វើបន្ត ក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះរួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅចំពោះការគ្រប់គ្រងដោយឈឺឆ្អាល

[13] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី,ឆ្នាំ២០១០,មាត្រា ៧២៩

[14] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២, ឆ្នាំ២០១៣,ទំព័រ៧៧

[15] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០,មាត្រា ៧៣៤

នោះបាន។[16]

### ១.២.២.២.សេចក្តីចម្រើនដោយឥតហេតុ

សេចក្តីចម្រើនដោយឥតហេតុ គឺជាប្រភពនៃកាតព្វកិច្ចដែលពុំមានការព្រមព្រៀងគ្នាជាមុនផងដែរ កាតព្វកិច្ចនេះបង្កើតនូវទំនាក់ទនងនៃសិទ្ធិលើបំណុល និងកាតព្វកិច្ចដែលបង្កើតឡើងក្រៅពីឆន្ទៈរបស់ភាគី ដែលដាក់បន្ទុកឲ្យបុគ្គលណាដែលគ្មានមូលហេតុគតិយុត្ត ក្នុងការទទួលបាននូវផលប្រយោជន៍ សងត្រឡប់នូវអ្វីដែលខ្លួនទទួលឲ្យទៅបុគ្គលដែលបានបាត់បង់នូវផលប្រយោជន៍ និងផ្តល់សិទ្ធិឲ្យភាគីដែលបាត់ប្រយោជន៍ ទាមទារយកមកវិញនូវអ្វីដែលបានបាត់បង់ ដោយគ្មានមូលហេតុតាមផ្លូវច្បាប់។ ម្យ៉ាងវិញទៀត សេចក្តីចម្រើនដោយឥតហេតុក៏អាចកើតឡើងក្នុងករណីដែលទាក់ទងនឹងកិច្ចសន្យាផងដែរ ប្រសិនបើបុគ្គលម្នាក់ទទួលបានផលប្រយោជន៍អ្វីមួយពីកិច្ចសន្យាដែលខ្លួនបានបង្កើតជាមួយបុគ្គលម្នាក់ទៀត ដែលជាអ្នកផ្តល់នូវផលប្រយោជន៍ ប៉ុន្តែក្រោយមកមានហេតុនាំឲ្យកិច្ចសន្យានោះបាត់បង់នូវអានុភាពជាប្រតិសកម្ម នោះបុគ្គលដែលទទួលបានផលប្រយោជន៍មានករណីកិច្ចសងផលប្រយោជន៍ដែលខ្លួនទទួលបាន ទៅបុគ្គលដែលបានផ្តល់នូវផលប្រយោជន៍នោះ។[17]

ដើម្បីកំណត់ពីអត្ថិភាពនៃសេចក្តីចម្រើនដោយឥតហេតុ ត្រូវបំពេញនូវលក្ខខណ្ឌទូទៅរួមមានផលប្រយោជន៍ ការបាត់បង់ផលប្រយោជន៍ ទំនាក់ទំនងហេតុ និងផលរវាងការទទួលផលប្រយោជន៍ និងការបាត់បង់ផលប្រយោជន៍ និងភាពមិនមានមូលហេតុលើផ្លូវច្បាប់ក្នុងការទទួលបានផលប្រយោជន៍។[18]

**-ការទទួលបានផលប្រយោជន៍** សំដៅលើផលប្រយោជន៍ដែលភាគីម្ខាងទទួលបាន ពីភាគីម្ខាងទៀតដែលបាត់បង់នូវផលប្រយោជន៍។ ផលប្រយោជន៍ដែលទទួលបាន គឺជាផលប្រយោជន៍ដែលបាត់បង់ ហើយវាអាចជាផលប្រយោជន៍រូបី និងផលប្រយោជន៍អរូបី។ ផលប្រយោជន៍រូបី នៅក្នុងករណីនៃសេចក្តីចម្រើនដោយឥតហេតុ គឺធម្មតាជាប្រាក់ ឬទំនិញ។ ម្យ៉ាងទៀត ផលប្រយោជន៍ អរូបីអាចជាផលប្រយោជន៍ក្នុងការប្រើប្រាស់ ឬសិទ្ធិនៃការចាត់ចែង។

**-ការបាត់បង់ផលប្រយោជន៍** សំដៅទៅលើទំហំនៃផលប្រយោជន៍ដែលបាត់បង់ ត្រូវសមាមាត្រទៅនឹងទំហំនៃផលប្រយោជន៍ដែលទទួលបាន។ នេះគឺជាគោលការណ៍នៃការសងត្រឡប់មកវិញនូវផលប្រយោជន៍ ដែលបានទទួលត្រឹមទំហំនៃផលប្រយោជន៍ដែលត្រូវបានបាត់បង់។

**-ទំនាក់ទំនងហេតុ និងផលរវាងការទទួលផលប្រយោជន៍ និងការបាត់បង់ផលប្រយោជន៍** សំដៅទៅលើលក្ខខណ្ឌដែលអាចទាមទារសំណងនៃការខូចខាត ដោយសារអំពើអនីត្យានុកូល ដូចជា ទំនាក់

[16] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០,មាត្រា ៧៣៥

[17] មាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[18] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីឆ្នាំ២០១៣ ភាគ២,ទំព័រ៨២

ទំនងហេតុ និងផល រវាងព្យសនកម្ម និងអំពើបំពានដោយខុសច្បាប់នូវសិទ្ធិ និងផលប្រយោជន៍ ចំពោះសេចក្តីចម្រើនដោយឥតហេតុ ដើម្បីទទួលស្គាល់នូវសិទ្ធិក្នុងការទាមទារយកមកវិញនូវផល ប្រយោជន៍ដែលបាត់បង់ បញ្ហាគឺស្ថិតនៅត្រង់ថា តើមានអ្នកទទួលបាននូវផលប្រយោជណ៍នោះដែរ ឬទេ? តើមានអ្នកដែលបាត់បង់ផលប្រយោជន៍ ដោយសារតែមានបុគ្គលម្នាក់ទៀត ទទួលបាននូវ ផលប្រយោជន៍ដែរ ឬយ៉ាងណា? ជាទូទៅ ទំនាក់ទំនងហេតុ និងផល ត្រូវបានទទួលស្គាល់ ប្រសិនបើ បានបង្ហាញថា មានអ្នកទទួលបានផលប្រយោជន៍ ដោយសារការបាត់បង់ផលប្រយោជន៍របស់បុគ្គល ម្នាក់ទៀតដោយគ្មានមូលហេតុ។

**-ភាពមិនមានមូលហេតុលើផ្លូវច្បាប់ក្នុងការទទួលផលប្រយោជន៍** សំដៅទៅលើភាពមិនមាន មូលហេតុត្រឹមត្រូវសម្រាប់រក្សាផលប្រយោជន៍។ នៅក្នុងលក្ខខណ្ឌនេះ គឺអ្នកទទួលបានផលប្រយោជន៍ គ្មានមូលហេតុគតិយុត្តណាមួយឲ្យខ្លួនត្រូវទទួល ឬរក្សាទុកផលប្រយោជន៍ដែលខ្លួនបានទទួលនោះទេ ពីព្រោះវាជារឿងមិនសមហេតុផល ដែលអនុញ្ញាតឲ្យបុគ្គលដែលមិនមានមូលហេតុត្រឹមត្រូវ ទទួល បានផលប្រយោជន៍ ឬអាចរក្សាទុកនូវផលប្រយោជន៍ដែលបានទទួលពីភាគីម្ខាងទៀត ដែលបាត់បង់ ផលប្រយោជន៍ដោយមិនសមហេតុផលនោះទេ។

ជារួមមក លក្ខខណ្ឌទាំងអស់ដែលបានរៀបរាប់ខាងលើនេះ គឺជាធាតុផ្សំដើម្បីកំណត់ពីអត្ថិភាព នៃសេចក្តីចម្រើនដោយឥតហេតុ មានន័យថាដើម្បីអាចបង្កើតកាតព្វកិច្ចដែលកំណត់ដោយច្បាប់ តាមរយៈសេចក្តីចម្រើនដោយឥតហេតុ លុះត្រាតែធាតុផ្សំទាំងបួនខាងលើត្រូវបានបំពេញ។

បន្ទាប់មក នៅពេលដែលមានសេចក្តីចម្រើនដោយឥតហេតុកើតឡើង អ្នកដែលបាត់បង់ផល ប្រយោជន៍ អាចទាមទារឲ្យអ្នកទទួលផលប្រយោជន៍សងមកវិញនូវផលប្រយោជន៍ដែលបានទទួល។ ក៏ប៉ុន្តែ ចំពោះទំហំផលប្រយោជន៍ដែលត្រូវសងនោះ វាខុសគ្នាដោយអាស្រ័យទៅលើថាតើអ្នកទទួល ផលប្រយោជន៍នោះសុចរិត ឬទុច្ចរិត។ ប្រសិនបើអ្នកទទួលផលប្រយោជន៍សុចរិត គឺសងត្រឹមកម្រិត ដែលផលប្រយោជន៍នៅមានសល់នាពេលបច្ចុប្បន្នទៅបានហើយ។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទទួល ផលប្រយោជន៍ទុច្ចរិត អ្នកទទួលផលប្រយោជន៍ត្រូវសងផលប្រយោជន៍ដែលបានទទួល និងការប្រាក់ ភ្ជាប់ទៅជាមួយផង។

### ១.២.២.៣.អំពើអនីត្យានុកូល

អំពើអនីត្យានុកូល គឺជាអំពើរបស់បុគ្គលម្នាក់ ដែលបានបង្កឲ្យមានការខូចខាតដោយខុសច្បាប់ លើសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ ដោយកំហុសចេតនា ឬអចេតនា ហើយបណ្តាលឲ្យមាន ការខូចខាតដល់ជនរងគ្រោះ។ អំពើអនីត្យានុកូល បង្កើតឡើងក្នុងគោលបំណងដើម្បីជួសជុលនូវ ការខូចខាត ដែលបានកើតឡើងចំពោះជនរងគ្រោះអំពីការរំលោភបំពានដោយខុសច្បាប់ ជាហេតុ

ដាក់បន្ទុកឲ្យជនដែលប្រព្រឹត្តអំពើអនីត្យានុកូលនោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយអំពើនោះ។ អំពើអនីត្យានុកូលមានច្រើនបែបច្រើនយ៉ាង ហើយមិនត្រឹមតែជាគ្រោះថ្នាក់ចរាចរណ៍ ឬការបង្ខូចបរិស្ថាន ឬកំហុសក្នុងការព្យាបាលនោះទេ គឺនៅមានការបំពានលើផលចំណេញ ការកាត់មុខយកកិច្ចសន្យាជាដើម។ ម្យ៉ាងវិញទៀត កម្មវត្ថុនៃសំណងនៃការខូចខាតមិនត្រឹមតែមាន ខូចខាតផ្នែកទ្រព្យសម្បត្តិប៉ុណ្ណោះទ មានរួមទាំងការខូចខាតខាងផ្លូវចិត្តផងដែរ។

ជាពិតណាស់ ដើម្បីអាចចាប់បង្ខំឲ្យនរណាម្នាក់ទទួលខុសត្រូវលើអំពើមួយ ដោយផ្អែកលើអំពើអនីត្យានុកូលបាន លុះត្រាបង្ហាញឲ្យឃើញនូវអត្ថិភាពនៃអំពើអនីត្យានុកូលជាមុនសិន។ យើងអាចកំណត់នូវអត្ថិភាពនៃអំពើអនីត្យានុកូលបានតាមលក្ខខណ្ឌទាំង ៤ មានដូចជា ប្រភេទនៃកំហុស ភាពខុសច្បាប់ ព្យសនកម្ម និងទំនាក់ទំនងហេតុ និងផល។[19]

**-ប្រភេទនៃកំហុស** គឺត្រូវបានចែកចេញជាពីរ កំហុសចេតនា និងកំហុសអចេតនា។ កំហុសចេតនា សំដៅលើការប្រព្រឹត្តអំពើបំពានមួយ ដោយខ្លួនបានដឹងជាមុននូវលទ្ធផលដែលអាចកើតឡើងចេញពីអំពើនោះ ហើយមានបំណងចង់ឲ្យលទ្ធផលនោះកើតឡើង។ ដោយឡែកកំហុសអចេតនាវិញ គឺជាការប្រព្រឹត្តអំពើបំពានមួយ ដែលកើតឡើងដោយការមិនអើពើចំពោះការទាមទារដោយច្បាប់ឲ្យមានករណីកិច្ចប្រុងប្រយ័ត្ន ហើយចារីអាចព្យាករណ៍ទុកជាមុននូវអំពើដែលបង្កឲ្យមានការខូចខាតដល់អ្នកដទៃ ក៏ប៉ុន្តែខ្លួនមិនបានធ្វើការព្យាករណ៍ទុកជាមុន ពោលគឺជននោះបានបំពានទៅនឹងករណីកិច្ចជៀសផុតពីលទ្ធផល និងករណីកិច្ចព្យាករណ៍ទុកជាមុន។[20] មិនថាអំពើបំពានដោយកំហុសចេតនា ឬអចេតនា សុទ្ធតែត្រូវចាប់បង្ខំអោយមានការទទួលខុសត្រូវទាំងអស់។

**-ភាពខុសច្បាប់** សំដៅទៅលើការប្រព្រឹត្តប្រាស់ចាកនូវបទបញ្ញត្តិគតិយុត្តផ្សេងៗ ព្រមទាំងវិន័យសង្គម។ មិនតែប៉ុណ្ណោះ អំពើរំលោភបំពានលើសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃ ដោយកំហុសចេតនា ឬកំហុសអចេតនាក្តី គឺជាអំពើខុសច្បាប់ ក៏ប៉ុន្តែ មានករណីខ្លះការបំពានសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃមិនមែនជាអំពើខុសច្បាប់នោះទេ។ ដូច្នេះ មានមូលហេតុមួយចំនួនដែលធ្វើឲ្យការបំពានសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃ មានភាពត្រឹមត្រូវតាមច្បាប់ដែលហៅថា ការរួចផុតពីភាពខុសច្បាប់ មានដូចជាការយល់ព្រមពីសំណាក់ជនរងគ្រោះ អំពើការពារជាធម្មានុរូប អំពើដោយសារស្ថានភាពចាំបាច់ និងអំពើដែលត្រូវបានសង្គមទទួលស្គាល់ថាសមរម្យ។

**-ព្យសនកម្ម** សំដៅទៅលើការខូចខាត ដែលជនរងគ្រោះអាចទាមទារអោយបុគ្គលណាម្នាក់

[19] មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[20] មាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ជួសជុល ឬទទួលខុសត្រូវ ប៉ុន្តែលុះត្រាតែបូរណភាពបុគ្គល ឬទ្រព្យសម្បត្តិបុគ្គល ឬកិត្តិយសបុគ្គល នោះទទួលរងនូវការខូចខាត។ ក្នុងការកំណត់អំពីទំហំនៃការខូចខាត យើងត្រូវពិចារណាទៅលើគោលគំនិតពីរគឺ ៖ ការចំណាយ និងការបាត់បង់អ្វីខ្លះ ដោយសារវត្តមាននៃអំពើអនីត្យានុកូល។ ការខូចខាតនៃអំពើអនីត្យាកូលត្រូវបែងចែកជាពីរចំណាត់ថ្នាក់ ការខូចខាតជាទ្រព្យសម្បត្តិ និងការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ។ ការខូចខាតជាទ្រព្យសម្បត្តិ គឺជាការខូចខាតដែលធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ ឬផលប្រយោជន៍ដែលមានតម្លៃអាចគណនាបាន ដូចជា ទ្រព្យសម្បត្តិ ប្រាក់បៀវត្សរ៍រូបរាងកាយ ចំណែកឯការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ គឺជាការខូចខាតដែលប៉ះពាល់ដល់សតិអារម្មណ៍ កិត្តិយស របស់ជនរងគ្រោះដែលពិបាកក្នុងការគណនាដោយសារវាមានភាពអរូបី និងពិបាកក្នុងការវាយតម្លៃប៉ុណ្ណាក្នុងការស្តារនូវផ្លូវចិត្តរបស់ជនរងគ្រោះ។

**-ទំនាក់ទំនងហេតុ និងផល** សំដៅទៅលើទំនាក់ទំនងនៃហេតុលទ្ធផលនៃការកើតឡើងនូវការខូចខាតចំពោះជនរងគ្រោះ និងចេតនា ឬកំហុសរបស់ចារី។ ដើម្បីកំណត់ថា ចារីបានបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះចាំបាច់ត្រូវមានអត្ថិភាពនៃទំនាក់ទំនងនៃហេតុផល មានន័យថាអ្នកទាមទារសំណងត្រូវបង្ហាញឲ្យឃើញថា ការខូចខាតដែលកើតមានឡើង គឺបណ្តាលមកពីវត្តមាននៃអំពើដែលជាកំហុសរបស់ចារីប្រព្រឹត្តយ៉ាងពិតប្រាកដ។

## ១.៣.ប្រភេទនៃកាតព្វកិច្ច

កាតព្វកិច្ច ជាទំនាក់ទំនងគតិយុត្ត ដែលបុគ្គលជាក់លាក់ម្នាក់ (កូនបំណុល) មានករណីកិច្ចចំពោះបុគ្គលជាក់លាក់ម្នាក់ទៀត (ម្ចាស់បំណុល)។ ចំពោះករណីកិច្ចអាចមានផ្សេងគ្នាដូចជា ការប្រគល់ ឬការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើវត្ថុ ឬប្រាក់។ក្រៅពីនេះកាតព្វកិច្ចអាចមានគោលបំណងក្នុងការបំពេញសកម្មភាពមួយចំនួន ឬការមិនបំពេញសកម្មភាពមួយចំនួន។

### ១.៣.១.កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព និងកាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាព

#### ១.៣.១.១.កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព

កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព គឺជាកាតព្វកិច្ចដែលភាគីម្ខាងជាកូនបំណុលធ្វើសកម្មភាពជាក់លាក់ណាមួយចំពោះភាគីម្ខាងដែលជាម្ចាស់បំណុល។ វាអាចធ្វើឡើងតាមរយៈកិច្ចសន្យាអាណត្តិ កិច្ចសន្យាការងារ។ ឧទាហរណ៍ ការសម្អាតផ្លូវថ្នល់ ការកាប់ដើមឈើ ការសាងសង់ ឬការបំផ្លាញអាគារ ការដឹកជញ្ជូនទំនិញជាដើម ។

#### ១.៣.១.២.កាតព្វកិច្ចមិនមានគោលបំណងឲ្យធ្វើសកម្មភាព

កាតព្វកិច្ចមិនមានគោលបំណងឲ្យធ្វើសកម្មភាព គឺជាកាតព្វកិច្ចដែលភាគីម្ខាងជាម្ចាស់បំណុល

មិនឲ្យកូនបំណុលធ្វើសកម្មភាពណាមួយដែលបានកំណត់ក្នុងកិច្ចសន្យាណាមួយ។ ដែលវាមានសុពលភាពដោយផ្អែកលើទៅលើគោលការណ៍សេរីភាពក្នុងការបង្កើតកិច្ចសន្យា។ ឧទាហរណ៍ កិច្ចសន្យារវាងអ្នកចម្រៀង និងផលិតកម្មសម្លេង ដោយហាមអ្នកចម្រៀងមិនឲ្យច្រៀងឲ្យផលិតកម្មផ្សេង។

**១.៣.២.កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ និងកាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ**

**១.៣.២.១.កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់**

កាតព្វកិច្ចប្រគល់វត្ថុ ត្រូវបានបែងចែកជាកាតព្វកិច្ចប្រគល់វត្ថុជាក់លាក់ និងកាតព្វកិច្ចប្រគល់វត្ថុមិនជាក់លាក់។ ក្នុងករណីដែលកាតព្វកិច្ច ជាកាតព្វកិច្ចប្រគល់វត្ថុជាក់លាក់ កូនបំណុលត្រូវមានករណីយកិច្ចគ្រប់គ្រង ឬថែរក្សាវត្ថុដែលជាកម្មវត្ថុ រហូតដល់ពេលប្រគល់វត្ថុនោះ។ ទោះបីជាក្នុងកិច្ចសន្យាពុំបានចែងអំពីករណីយកិច្ចថែរក្សាវត្ថុក៏ដោយ កូនបំណុលនៅតែមានការទទួលបន្ទុកចំពោះការថែរក្សាវត្ថុ គឺជាករណីយកិច្ចក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ។ ប្រសិនបើកូនបំណុលធ្វើឲ្យខូចខាត ឬបាត់បង់វត្ថុដែលជាកម្មវត្ថុនោះ ដោយផ្ទុយនឹងករណីយកិច្ចថែរក្សាវត្ថុនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ កូនបំណុលនោះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ដោយសន្មតថាមានកំហុស។ ចំណែកឯកាតព្វកិច្ចប្រគល់វត្ថុមិនជាក់លាក់ ទោះបីជាកូនបំណុលបំផ្លាញ ឬធ្វើឲ្យខូចខាតដល់វត្ថុមិនជាក់លាក់ក៏ដោយ ក៏ការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច មិនត្រូវបានកើតឡើងឡើយ ពីព្រោះមានវត្ថុមិនជាក់លាក់ដែលមានប្រភេទដូចគ្នា ហើយកូនបំណុលអាចរកវត្ថុដែល ដូចគ្នានោះមកជំនួសបាន និងផ្តល់តាវកាលិកនោះបាន[21]។

**១.៣.២.២.កាតព្វកិច្ចដែលកំណត់ប្រភេទនៃវត្ថុ**

កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ គឺជាកាតព្វកិច្ចដែលកម្មវត្ថុនោះត្រូវកំណត់ដោយផ្អែកលើប្រភេទ គុណភាព និងបរិមាណ។ ក្នុងករណីនេះកូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ច ដែលត្រូវផ្តល់តាវកាលិកជាវត្ថុកំណត់តាមប្រភេទ។ ចំពោះកាតព្វកិច្ចដែលបានកំណត់ប្រភេទ គុណភាពវត្ថុដែលកូនបំណុលត្រូវផ្តល់តាវកាលិក មានសារៈសំខាន់ ជាធម្មតា គុណភាពនោះត្រូវបានកំណត់ក្នុងកិច្ចសន្យា ប៉ុន្តែ ប្រសិនបើភាគីនៃកិច្ចសន្យាពុំបានកំណត់គុណភាព កូនបំណុលអាចផ្តល់តាវកាលិកនូវវត្ថុដែលមានគុណភាពមធ្យមបាន។ ក្នុងករណីកាតព្វកិច្ចប្រគល់ វត្ថុជាក់លាក់ ដូចជា ការទិញលក់អគារជាដើម អ្នកលក់គ្មានករណីកិច្ចប្រគល់វត្ថុជំនួសទេ ជម្រើសតែមួយ គឺត្រូវសងសំណងការខូចខាត។ ទោះបីជាកាតព្វកិច្ចដែលបានកំណត់ប្រភេទ ត្រូវបានកំណត់ជាក់លាក់ក៏

[21] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០,មាត្រា ៣១៤

ដោយ ក៏កាតព្វកិច្ចនេះមិនត្រូវក្លាយជា កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ដែរ ហើយមានវត្ថុដូចគ្នាដែលអាចយកជំនួសវត្ថុដែលខូចខាត ឬបាត់បង់នោះបាន ហេតុដូច្នេះ ម្ចាស់បំណុលអាចទាមទារវត្ថុជំនួស វត្ថុដែលខូចខាត ឬបាត់បង់ដោយកំហុសរបស់កូនបំណុល[22]។

### ១.៣.៣.កាតព្វកិច្ចជាប្រាក់

កាតព្វកិច្ចជាប្រាក់ គឺជាកាតព្វកិច្ចដែលមានកម្មវត្ថុនៃកាតព្វកិច្ចជាប្រាក់ ហើយកូនបំណុលអាចសងជារូបិយវត្ថុផ្សេងៗ តាមការជ្រើសរើសរបស់ខ្លួនបាន។ រូបិយវត្ថុ សំដៅទៅលើក្រដាសប្រាក់ក្តី ឬកាក់ ដែលអាចយកមកចាយវាយដោយស្របច្បាប់ ចំពោះប្រភេទនៃរូបិយវត្ថុ និងវិសាលភាពនៃភាពស្របច្បាប់ នឹងត្រូវបានកំណត់ដោយច្បាប់ផ្សេងៗ ប៉ុន្តែ ម្ចាស់បំណុល និងកូនបំណុលអាចកំណត់ការសងនោះជារូបិយវត្ថុពិសេសក៏បានដែរ ក្នុងករណីដែលរូបីយវត្ថុពិសេសដែលបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច លែងជារូបីយវត្ថុស្របច្បាប់នៅពេលអនុវត្តកាតព្វកិច្ច កូនបំណុលអាចសងជារូបីយវត្ថុណាមួយផ្សេងទៀតបាន។ យើងឃើញថាមានករណីមួយចំនួនដែលភាគីបានព្រមព្រៀងគ្នាក្នុងការសងជារូបីយវត្ថុបរទេស កូនបំណុលអាចសងដោយប្រើប្រាស់ប្រភេទផ្សេងៗនៃរូបីយវត្ថុបរទេសនោះ លើកលែងកូនបំណុលអាចសងជារូបីយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទៅតាមអត្រាការប្តូររូបីយបណ្ណ័បរទេស នៅកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចនោះនៅពេលកំណត់អនុវត្ត។ បើយើងក្រឡេកទៅមើលកាតព្វកិច្ចដែលមានកម្មវត្ថុ ជាការបង់ប្រាក់វិញ កូនបំណុលមិនអាចរួចផុតពីកាតព្វកិច្ចបង់ការប្រាក់ចំពោះការយឺតយ៉ាវឡើយ ទោះបីជាកូនបំណុលអាចបញ្ជាក់ថា ការយឺតយ៉ាវក្នុងការបង់នោះកើតឡើងដោយសារប្រធានសក្តិក៏ដោយ។ ប្រសិនបើកូនបំណុលបានបញ្ជាក់ថាមិនមានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ច នោះកូនបំណុលអាចរួចផុតពីករណីកិច្ចបង់ថ្លៃការខូចខាតដែលលើសពីការប្រាក់ដែលយឺតយ៉ាវ ប៉ុន្តែមិនអាចរួចផុតពីករណីកិច្ចបង់ការប្រាក់ដែលយឺតយ៉ាវនោះទេ។

### ១.៣.៤.កាតព្វកិច្ចអនិយ័ត

កាតព្វកិច្ចអនិយ័ត គឺជាកាតព្វកិច្ចដែលមានកម្មវត្ថុត្រូវបានកំណត់ដោយការជ្រើសរើសក្នុងចំណោមការផ្តល់តាវកាលិកច្រើនប្រភេទ។ ករណីចម្បងទាក់ទងនឹងកាតព្វកិច្ចនេះ គឺបញ្ហាត្រង់ថាតើអ្នកណាមានសិទ្ធិក្នុងការជ្រើសរើស? ជាទូទៅភាគីនៃកិច្ចសន្យាដែលព្រមព្រៀងគ្នាអំពីកាតព្វកិច្ចអនិយ័ត ផ្តល់សិទ្ធិនោះទៅឲ្យកូនបំណុលក្នុងការជ្រើសរើស ហើយកិច្ចព្រមព្រៀងដែលផ្តល់សិទ្ធិនោះក៏អាចផ្តល់ទៅអោយម្ចាស់បំណុលឬ តតិយជនតាមការកំណត់ផ្សេងបាន ហើយវា

[22] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០,មាត្រា ៣១៥

ក៏មានសុពលភាពផងដែរ [23] ។ ឧទាហរណ៍ "ក" បានធ្វើអោយខូចរថយន្តម៉ាក តូយ៉ូតារបស់ "ខ" ក្រោយមក "ក" និង "ខ" បានបង្កើតកិច្ចសន្យាសះជា ដោយព្រមព្រៀងគ្នាថា "ក" ត្រូវប្រគល់រថយន្តម៉ាក កាម៉ារី ថ្មីឲ្យទៅ "ខ" ក្នុងរយៈពេល១ខែ ឬបង់ប្រាក់ចំនួន ១៥.០០០ដុល្លារ។ ករណីមួយផ្សេងទៀតនៃកាតព្វកិច្ចអនិយ័តដែលកើតឡើងតាមរយៈកិច្ចសន្យា គឺករណីកិច្ចសន្យាសងដោយយកវត្ថុជំនួសវិញ ដោយកិច្ចសន្យាសងយកវត្ថុជំនួស គឺជាការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និងកូនបំណុលក្នុងការជំនួសឲ្យការប្រាក់ គឺត្រូវជំនួសដីវិញ ក្នុងពេលដែលបង្កើតកិច្ចសន្យាសងដោយវត្ថុជំនួស កូនបំណុលអាចជ្រើសរើសសងប្រាក់ ឬប្រគល់ដី។ មានករណីខ្លះកិច្ចសន្យាដោយយកវត្ថុជំនួសត្រូវបានបង្កើតស្របពេលជាមួយគ្នានឹងពេលខ្ចីប្រាក់ ករណីខ្លះទៀតនោះត្រូវបានបង្កើតនៅក្រោយពេលខ្ចីប្រាក់តែនៅមុនពេលកំណត់សង ហើយករណីខ្លះទៀតត្រូវបានបង្កើតនៅក្រោយពេលកំណត់សងផងដែរ។

[23] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០,មាត្រា ៣២០

# ជំពូកទី ២
# លក្ខណៈនៃការរំលត់កាតព្វកិច្ច

# ជំពូកទី២

# លក្ខខណ្ឌនៃការរំលត់កាតព្វកិច្ច

## ២.១.ការរលត់កាតព្វកិច្ចតាមសកម្មភាពគូភាគី

ជាការពិតណាស់ កាតព្វកិច្ចគឺជាចំណងគតិយុត្តិមួយដែលចងភ្ជាប់ភាគីពីរ ដែលម្ខាងជាម្ចាស់បំណុល ហើយម្ខាងទៀតជាកូនបំណុល ហើយកូនបំណុលត្រូវមានករណីកិច្ចណាមួយដើម្បីបំពេញទៅឲ្យម្ចាស់បំណុល[24]។ យ៉ាងណាមិញកូនបំណុលអាចរួចផុតពីការអនុវត្តនូវកាតព្វកិច្ចនេះផងដែរដោយករណីមួយចំនួន ដូចជា ការសង ការទូទាត់ ទៅឲ្យម្ចាស់បំណុល ។ ករណីមួយចំនួនទៀតកាតព្វកិច្ចត្រូវបានរលត់ដោយ មានការលើកលែងអំពីម្ចាស់បំណុល, នវកម្ម ឬព្យាកុលភាព និងការទទួលយកនូវហានិភ័យដែលគូភាគីបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យា។

### ២.១.១.ការសង

ការសង គឺជាវិធីសាមញ្ញមួយសម្រាប់ការបញ្ចប់នូវកាតព្វកិច្ចរវាងកូនបំណុល និងម្ចាស់បំណុល ហើយវាស្តែងអំពីឆន្ទៈនៃការព្រមព្រៀងគ្នាដោយត្រឹមត្រូវ ច្បាស់លាស់ និងពិតប្រាកដ ម្យ៉ាងទៀតវានិងមានអានុភាព ប្រសិនបើការសងនោះកើតឡើងរវាងភាគីដែលពាក់ពន្ធ័ទៅនឹងកិច្ចសន្យានោះ។ ចំពោះការសងវិញ ត្រូវបានបែងចែកជាពីរគឺ ការសងធម្មតា និងការសងដោយឧបាទេសកម្ម។

#### ២.១.១.១.ការសងធម្មតា

ការសងធម្មតា គឺសំដៅលើរបៀបសាមញ្ញមួយដែលជាប្រចាំយើងឃើញថា ប្រជាពលរដ្ឋតែងតែប្រើប្រាស់វិធីនេះសម្រាប់ជីវភាពប្រចាំថ្ងៃរបស់ពួកគេ ឧទាហរណ៍ដូចជាការខ្ចីប្រាក់ ហើយសងឲ្យទៅវិញនូវប្រាក់ ការសំខាន់បុគ្គលណាដែលបានខ្ចី គឺជាអ្នកសង ជាការពិតណាស់នៅពេលបុគ្គលដែលបានខ្ចីប្រាក់នោះ សងដល់ម្ចាស់បំណុលវិញ កាតព្វកិច្ចនោះនិងត្រូវរលត់តែម្តង។ ចំពោះការសងនេះក៏អាចធ្វើឡើងដោយតតិយជនផងដែរ ក្នុងករណីដែលកូនបំណុលអលទ្ធភាព ក្នុងការសងនូវបំណុលដែលបានជំពាក់ ឬជាប់កាតព្វកិច្ចជាមួយម្ចាស់បំណុល ហើយតតិយជនអាចជាឪពុកម្តាយ ឬបងប្អូន ឬសាច់ញាតិរបស់កូនបំណុលក្នុងការសងជំនួសបាន។ នៅក្នុងកិច្ចសន្យាម្ចាស់បំណុល និងកូនបំណុលតែងតែកំណត់ទុកជាមុននូវកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវសង។ ចំពោះអានុភាពនៃការសងវិញ នៅពេលដែលកូនបំណុល ឬតតិយជនបានសងបំណុលទៅអោយម្ចាស់បំណុលរួចហើយ នឹងមានអានុភាពធ្វើអោយកាតព្វកិច្ចត្រូវរលត់ ហើយអ្នកសងអាចទាមទារអោយអ្នកទទួលការសងចេញលិខិតបញ្ជាក់នូវការសងនោះបាន[25]។ ក្នុងករណីនេះប្រសិនបើ ម្ចាស់

[24] មាត្រា ៣០៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[25] មាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

បំណុលមិនព្រមចេញលិខិតបញ្ជាក់នោះទេ កូនបំណុលអាចបដិសេធក្នុងការសង រហូតដល់ម្ចាស់បំណុលយល់ព្រមចេញលិខិតបញ្ជាក់នៃការទទួលការសងនោះ។ ម្យ៉ាងវិញទៀត ប្រសិនបើមានលិខិតបញ្ជាក់លើបំណុល អ្នកសងអាចទាមទារ អោយម្ចាស់បំណុលប្រគល់នូវលិខិត នោះមកវិញបាន[26]។ ចំពោះការទាមទារនេះ ធ្វើអោយកូនបំណុលអាចជៀសផុតពីការខូចខាតនៃការសងនូវកាតព្វកិច្ចរួចនោះ និងបញ្ជាក់ពីអត្ថិភាពនៃការសងផងដែរ។

### ២.១.១.២.ការសងដោយឧបាទេសកម្ម

ការសងដោយឧបាទេសកម្ម គឺសំដៅលើការសងដោយបុគ្គលម្នាក់ទទួលការសងជំនួស បុគ្គលណាមួយតាមផ្លូវច្បាប់។ បុគ្គលនោះបានចំណាយចេញសងសំណងនោះ ត្រូវបានទទួលស្គាល់នូវសិទ្ធិទាមទារសំណងរបស់ខ្លួនចំពោះកូនបំណុលបាន ដូចនេះកូនបំណុលផ្សេងទៀត ត្រូវជាប់កាតព្វកិច្ចចំពោះបុគ្គលដែលបានចេញសងជំនួសនោះ ហើយត្រូវបំពេញកាតព្វកិច្ចចំពោះបុគ្គលដែលបានចេញសងជំនួសនោះ មិនត្រូវសងទៅម្ចាស់បំណុលដើមទេ។ ករណីនៃការសងដោយឧបាទេសកម្មនេះបានកើតឡើងតាមពីរប្រភេទ គឺប្រភេទតាមការព្រមព្រៀង និងប្រភេទតាមច្បាប់។ ប៉ុន្តែយើងលើកឡើងទាក់ទងនឹងការសងដោយឧបាទេសកម្ម ដែលកើតចេញពីការព្រមព្រៀងនោះប្រសិនបើកូនបំណុលអលទ្ធភាពក្នុងការសង តតិយជនអាចសងជំនួសបានដោយមានការព្រមព្រៀងអំពីម្ចាស់បំណុលក្នុងករណីដែលកាតព្វកិច្ចលើបំណុលជាកាតព្វកិច្ចសាមគ្គីវិញ ប្រសិនបើកូនបំណុលណាមួយដែលបានចំណាយក្នុងការសង ដែលជាទ្រព្យផ្ទាល់របស់ខ្លួនធ្វើអោយកូនបំណុលនៃកាតព្វកិច្ចសាមគ្គីផ្សេងទៀតរួចផុតពីកាតព្វកិច្ចដែរនោះ នាំអោយកូនបំណុលដែលបានចេញសងនោះទទួលបានសិទ្ធិទាំងឡាយដែលម្ចាស់បំណុលធ្លាប់មានទាំងអស់ ជាពិសេសសិទ្ធិទាមទារសំណងពីកូនបំណុលផ្សេងទៀតប្រសិនបើកូនបំណុលដែលបានចេញសង នោះបានជូនដំណឹងទៅអោយកូនបំណុលផ្សេងទៀតដឹងថាខ្លួនបានទទួលការទាមទារពីម្ចាស់បំណុល[27]។

នៅពេលដែលការសងត្រូវបានធ្វើឡើងហើយនោះ អានុភាពនៃការសងនិងកើតឡើងដែលក្នុងនោះបានដល់បុគ្គលពីរនាក់គឺ បុគ្គលម្នាក់ដែលជាអ្នកសង (កូនបំណុល) និងបុគ្គលដែលទទួលការសង (ម្ចាស់បំណុល)។ កាលណាដែលម្ចាស់បំណុលបានទទួលការសងនូវវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ចពីកូនបំណុលតាមរយៈការអនុវត្តសិទ្ធិឧបាទេសកម្មហើយនោះ កូនបំណុលត្រូវរួចផុតពីការអនុវត្តកាតព្វកិច្ចមានន័យថា កាតព្វកិច្ចដែលម្ចាស់បំណុលមានពីមុនត្រូវរលត់ ដោយហេតុកូនបំណុលបានផ្តល់នូវតារកាលិក ដែលជាកម្មវត្ថុនៃកិច្ចសន្យានោះរួចហើយ។ ចំពោះម្ចាស់បំណុលវិញ

[26] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[27] មាត្រា ៩៣៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ក្រោយពីមានការសងដោយឧបាទេសកម្មកើតឡើងហើយនោះ រាល់លិខិតទាំងអស់ដែលទាក់ទងសិទ្ធិលើបំណុល ត្រូវប្រគល់ជូនទៅឧបាទេសកវិញ[28]។ មានន័យថា ម្ចាស់បំណុលដែលបានទទួលការសង មានករណីកិច្ចមួយចំនួនដើម្បីធានានូវសិទ្ធិឧបាទេសកម្មរបស់អ្នកដែលបានសង និងផ្តល់នូវលិខិតបញ្ជាក់នៃការសង ឬលិខិតបំណុលនានាទៅអោយកូនបំណុលវិញ ដើម្បីជាភស្តុតាង ឬដើម្បីអោយកូនបំណុលអាចជឿជាក់បានថា ខ្លួននិងមិនមានការខូចខាតដោយសារការទាមទារបំណុលម្តងទៀតពីម្ចាស់បំណុលនូវបំណុលដែលបានសងរួចហើយនោះទេ។

### ២.១.២. ការទូទាត់

ការទូទាត់ សំដៅទៅលើការរំលត់កាតព្វកិច្ចដែលធ្វើឡើងដោយយកចំនួនប្រាក់ស្មើគ្នា ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ច ដែលមានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមក។ ភាគីម្ខាងអាចរំលត់កាតព្វកិច្ចទៅវិញទៅមកបានដោយយកប្រាក់ស្មើគ្នាដោយបង្ហាញឆន្ទៈឯកតោភាគី ហើយការទូទាត់ក៏អាចធ្វើបានដែរ ទោះបីជាកាតព្វកិច្ចទាំងពីរនោះមានគោលបំណង ផ្សេងគ្នាក៏ដោយ ប៉ុន្តែការទូទាត់នេះមិនអាចធ្វើអោយខូចប្រយោជន៍តតិយជននោះទេ[29]។

ម្យ៉ាងវិញទៀត អ្នកធានាមិនអាចជំទាស់មិនអោយទូទាត់បំណុល ដែលម្ចាស់បំណុលមានលើកូនបំណុលដែលខ្លួនធានានោះទេ។ ហើយកូនបំណុលក៏មិនអាចជំទាស់មិនអោយទូទាត់នូវបំណុលដែលម្ចាស់បំណុលមានលើអ្នកធានាខ្លួននោះទេ។ លើសពីនេះទៀត កូនបំណុលសាមគ្គីក៏មិនអាចជំទាស់មិនអោយទូទាត់បំណុលដែលម្ចាស់បំណុលមានលើកូនបំណុលរួមបាននោះទេ។

#### ២.១.២.១.លក្ខខណ្ឌ

ចំពោះការទូទាត់គឺ ដាច់ខាតត្រូវតែមានលក្ខខណ្ឌដែលពេលខ្លះគេអាចអនុញ្ញាតអោយមានការទូទាត់ ហើយពេលខ្លះគេមិនអនុញ្ញាតអោយមានការទូទាត់នោះទេដោយមានមូលហេតុផ្សេងៗដែលច្បាប់បានកំណត់។ ដូចនេះផងដែរ យើងអាចញែកលក្ខខណ្ឌជាពីរគឺ លក្ខខណ្ឌដែលអាចធ្វើការទូទាត់បាន និងលក្ខខណ្ឌដែលអាចមិនធ្វើការទូទាត់បាន។

លក្ខខណ្ឌដែលអាចធ្វើការទូទាត់បានមានដូចជាៈ

-បុគ្គលពីរនាក់ ទទួលបន្ទុកកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក គឺទោះបីជាកាតព្វកិច្ចមួយដែលគ្មានការព្រមព្រៀងគ្នាក្នុងការទូទាត់របស់ភាគីទាំងពីរ ប៉ុន្តែភាគីម្ខាងអាចធ្វើការទូទាត់បាន ដោយធ្វើការបង្ហាញឆន្ទៈឯកតោភាគី។

-កាតព្វកិច្ចទាំងពីរ ដែលមានគោលបំណងប្រភេទដូចគ្នា គឺការទូទាត់អាចធ្វើបានចំពោះកាតព្វកិច្ច

[28] មាត្រា ៥៦២នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[29] មាត្រា ៥៦៤នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ជាប្រាក់ ឬកាតព្វកិច្ចដែលមានកម្មវត្ថុជំនួសប្រភេទដូចគ្នា។

-កាតព្វកិច្ចទាំងពីរត្រូវដល់ពេលកំណត់សង ក្នុងករណីនេះ គឺជាការដល់ពេលវេលាដែលត្រូវកំណត់សងនូវសិទ្ធិលើបំណុល ដែលភាគីម្ខាងបានបង្ហាញឆន្ទៈអំពីការទូទាត់ មានចំពោះភាគីម្ខាងទៀត។

-ការបង្ហាញឆន្ទៈទូទាត់ គឺការទូទាត់ដោយភាគីម្ខាង បានបង្ហាញឆន្ទៈធ្វើការទូទាត់ទៅដល់ភាគីម្ខាងទៀត។

លក្ខខណ្ឌដែលអាចមិនធ្វើការទូទាត់បានមានដូចជា៖

-ការទូទាត់មិនអាចនិងធ្វើបានទេ ប្រសិនបើម្ចាស់បំណុលនៃកាតព្វកិច្ចនេះមិនមែនជាកូនបំណុលផ្ទាល់នៃកាតព្វកិច្ចនោះ ហើយម្ចាស់បំណុលនៃកាតព្វកិច្ចនេះក៏មិនមែនជាកូនបំណុលនៃកាតព្វកិច្ចនេះដែរ។

-ករណីដែលលក្ខណៈនៃកាតព្វកិច្ចណាមួយ ឬទាំងពីរមិនអនុញ្ញាតអោយធ្វើការទូទាត់។ ករណីដែលភាគីទាំងសងខាងធ្វើការសន្យាពិសេសមិនធ្វើការទូទាត់ ប៉ុន្តែការសន្យាពិសេសមិនធ្វើការទូទាត់នេះមិនអាចអះអាងចំពោះតតិយជនសុចរិតបានឡើយ។

-ក្នុងករណីដែលភាគីម្ខាងទៀតមានសិទ្ធិក្នុងការតវ៉ា និងសិទ្ធិលើបំណុលរបស់ភាគីដែលបង្ហាញឆន្ទៈទូទាត់ ទោះបីជាលក្ខខណ្ឌសម្រាប់ការទូទាត់ត្រូវបានបំពេញក៏ដោយ ក៏មិនអាចធ្វើការទូទាត់បានដែរ។

-កាតព្វកិច្ចកើតឡើងដោយអំពើអនីត្យានុកូល។ ឧទាហរណ៍ ករណីមួយដែល "ក" មានសិទ្ធិលើបំណុលចំពោះ "ខ" ហើយ "ខ" មានសិទ្ធិលើបំណុលចំពោះសំណងការខូចខាតដែលកើត ឡើងដោយសារអំពើអនីត្យានុកូលរបស់ "ក" មិនអាចអះអាងអំពីការរលត់កាតព្វកិច្ច ចំពោះសំណងការខូចខាតដែលកើតឡើងដោយអំពើអនីត្យានុកូលនោះ តាមការអះអាងអំពីការទូទាត់បានឡើយ។

### ២.១.២.២. ប្រភេទ

ការទូទាត់ ត្រូវបានបែងចែកជាពីរប្រភេទ គឺ ការទូទាត់តាមការយល់ព្រមពីភាគី និងការទូទាត់ដោយគ្មានការយល់ព្រមពីភាគី។

-ការទូទាត់តាមការយល់ព្រមពីភាគី ៖ គោលការណ៍ ភាគីមានសិទ្ធិក្នុងការយល់ស្របគ្នាដើម្បីរំលត់កាតព្វកិច្ច ហើយអានុភាពកើតមានឡើងនៅពេលដែលភាគីយល់ព្រមគ្នានោះ[30]។ ការទូទាត់និងមិនមានអានុភាពនោះទេ ប្រសិនបើភាគីមិនបានបង្ហាញឆន្ទៈ ហើយការបង្ហាញឆន្ទៈនោះចាំបាច់ត្រូវតែទៅដល់ភាគីម្ខាងទៀត។

-ការទូទាត់ដោយគ្មានការយល់ព្រមពីភាគី៖ យើងបានដឹងហើយថាដើម្បីអាចទូទាត់បាន

[30] មាត្រា ៤៦៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

លុះត្រាតែមានការបង្ហាញឆន្ទៈចំពោះការទូទាត់ពីភាគី នៅពេលដែលភាគីមិនបានបង្ហាញឆន្ទៈចំពោះការទូទាត់លើបំណុលទេ នោះភាគីដែលជាម្ចាស់បំណុលអាចទាមទារអោយតុលាការចេញនូវសេចក្តីសម្រេចមួយដោយបង្គាប់អោយកូនបំណុលសង ឬធ្វើការទូទាត់ជូនខ្លួនបាន។ មួយវិញទៀត នៅពេលដែលការទូទាត់បានធ្វើឡើងហើយ ប៉ុន្តែភាគីណាម្ខាង ម្ចាស់បំណុលឬ កូនបំណុលបានចំណេញច្រើនពីការទូទាត់នោះ ភាគីណាដែលបានបាត់បង់ផលប្រយោជន៍ច្រើន អាចធ្វើការទាមទារទៅតុលាការអោយសម្រេចសេចក្តីចំពោះការទូទាត់នោះ។

**២.១.២.៣. អានុភាព**

នៅពេលដែលលក្ខខណ្ឌនៃការទូទាត់ត្រូវបានបំពេញ ហើយនៅពេលដែលឆន្ទៈនៃការទូទាត់ត្រូវបានបង្ហាញនោះ អានុភាពពីរនិងកើតមានឡើង ដូចជា កាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ត្រូវរលត់ត្រឹមកម្រិតដែលចំនួននីមួយៗ មានតម្លៃស្មើគ្នា និងអានុភាពដែលរលត់កាតព្វកិច្ចដោយការទូទាត់នោះត្រូវកើតមានអានុភាពប្រតិសកម្មតាំងពីពេលដែលកាតព្វកិច្ចទាំងពីរនោះ សមស្របនឹងការទូទាត់មានន័យថា កាតព្វកិច្ចទាំងពីរនោះនឹងរលត់នៅកាលបរិច្ឆេទដែលកាតព្វកិច្ចទាំងពីរបានកំណត់សង[31]។

**២.១.៣. ការលើកលែងរបស់ម្ចាស់បំណុល**

ការលើកលែង គឺជាមូលហេតុមួយដែលនាំអោយមានការរំលត់កាតព្វកិច្ច ដោយម្ចាស់បំណុលអាចបង្ហាញឆន្ទៈឯកតោភាគីដើម្បីលើកលែងឲ្យកូនបំណុលរួចផុតពីកាតព្វកិច្ច។

**២.១.៣.១.លក្ខខណ្ឌ**

ដើម្បីបង្ហាញថាកាតព្វកិច្ចមួយរបស់កូនបំណុលត្រូវបានរំលត់ គឺការលើកលែងរបស់ម្ចាស់បំណុលត្រូវគោរពតាមលក្ខខណ្ឌពីរគឺ ការព្រមព្រៀងពីម្ចាស់បំណុល និងម្ចាស់បំណុលមិនត្រូវបានកម្រិតសិទ្ធិ។

-ការព្រមព្រៀងពីម្ចាស់បំណុល៖ នៅពេលដែលម្ចាស់បំណុល បង្ហាញឆន្ទៈក្នុងការលើកលែងទៅលើកាតព្វកិច្ចចំពោះកូនបំណុល នោះកាតព្វកិច្ចនឹងត្រូវរលត់។ ក្នុងនោះផងដែរ ម្ចាស់បំណុលអាចបង្ហាញឆន្ទៈក្នុងការលើកលែងកាតព្វកិច្ចទាំងអស់ ដើម្បីអោយកូនបំណុលរួចផុតពីកាតព្វកិច្ចបានម្យ៉ាងវិញទៀត ម្ចាស់បំណុលក៏អាចបង្ហាញឆន្ទៈលើកលែងតែមួយផ្នែកក៏បាន[32]។ ឧទាហរណ៍ ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលកូនបំណុលខ្ចីប្រាក់ពីម្ចាស់បំណុលចំនួន ១០.០០០ ដុល្លារ។ក្នុងករណីនេះម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ច ៤.០០០ ដុល្លារ ពីកាតព្វកិច្ច ១០.០០០ ដុល្លារ ឬម្ចាស់បំណុលអាចបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចត្រូវបង់ប្រាក់ជាដើម។

-ម្ចាស់បំណុលមិនត្រូវបានកម្រិតសិទ្ធិ៖ ម្ចាស់បំណុលអាចធ្វើការបង្ហាញឆន្ទៈក្នុងការលើកលែង

[31] មាត្រា ៤៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[32] មាត្រា ៤៧៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ទៅលើកូនបំណុលអោយរួចផុតពីកាតព្វកិច្ចបាន លុះត្រាតែម្ចាស់បំណុលមានសិទ្ធិចាត់ចែងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន។ ម្ចាស់បំណុលដែលមានសិទ្ធិចាត់ចែងបែបនេះ ភាគច្រើន ជាម្ចាស់បំណុលធម្មតា ក៏ប៉ុន្តែ ជួនកាលម្ចាស់បំណុលប្រភេទនេះមិនមានសិទ្ធិធ្វើការចាត់ចែងទេ ដោយសារតែគាត់បាត់បង់នូវសិទ្ធិចាត់ចែងនោះ ដូចជាក្នុងករណីដែលសិទ្ធិលើបំណុលរបស់គាត់ ត្រូវបានរឹបអូសជាដើម នាំអោយម្ចាស់បំណុលនោះមិនអាចធ្វើការលើកលែងបានទេ[33]។

### ២.១.៣.២. អានុភាព

អានុភាពនៃការលើកលែងនិងកើតមានឡើង នៅពេលដែលមានការបង្ហាញឆន្ទៈរបស់ម្ចាស់បំណុល។ អ្វីដែលសំខាន់នោះ កាលណាដែលម្ចាស់បំណុលបង្ហាញឆន្ទៈរបស់ខ្លួនលើកលែងកាតព្វកិច្ចទាំងអស់ទៅលើកាតព្វកិច្ចរបស់កូនបំណុល នោះកូនបំណុលនិងរួចផុតពីការទទួលខុសត្រូវលើកាតព្វកិច្ចនោះ ហើយសិទ្ធិលើបំណុលនឹងត្រូវរលត់ផងដែរ ប៉ុន្តែក្នុងករណីដែលម្ចាស់បំណុលធ្វើការលើកលែងត្រឹមមួយផ្នែកនៃកាតព្វកិច្ចនោះ កូនបំណុលនៅតែមានកាតព្វកិច្ចក្នុងការសង តែត្រូវបានសម្រាលមួយផ្នែកនៃកាតព្វកិច្ច។ សម្រាប់ការលើកលែងនេះត្រូវតែមានភស្តុតាងច្បាស់លាស់ដូចជាលិខិត ឬបង្កាន់ដៃនៃការលើកលែង ឬប្រគល់ប័ណ្ណបំណុលទៅអោយកូនបំណុលវិញ ឬក៏បំផ្លាញប័ណ្ណបំណុលនោះចោលជាអសារបង់ក៏បាន។

### ២.១.៤. នវកម្ម ឬព្យាកុលភាព

នវកម្ម គឺជាកិច្ចសន្យារវាងម្ចាស់បំណុល និងកូនបំណុលដែលរំលត់កាតព្វកិច្ចដើម និងបង្កើតកាតព្វកិច្ចថ្មីជំនួសកាតព្វកិច្ចដើមនោះ[34]។ នវកម្មមានចំនួនបីប្រភេទដូចជា៖

-ករណីនៃការផ្លាស់ប្តូរគោលបំណងក្នុងកាតព្វកិច្ច មានន័យថាការផ្តល់នូវកម្មវត្ថុ ឬតាវកាលិកថ្មីដែលអាចជំនួសកាតព្វកិច្ចចាស់បាន។ ឧទាហរណ៍៖ កិច្ចសន្យាខ្ចីប្រាក់ ប្តូរទៅជាការផ្តល់នូវវត្ថុដែលមានតម្លៃស្មើទៅនិងបំណុលរបស់ម្ចាស់បំណុលវិញ។

-ការប្តូរម្ចាស់បំណុលដែលជាភាគីមួយក្នុងចំណោមភាគីនៃកិច្ចសន្យា ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងអនុប្បទានសិទ្ធិលើបំណុលដែរ ប៉ុន្តែនវកម្មដែលប្តូរម្ចាស់បំណុលនេះ ធ្វើអោយកាតព្វកិច្ចដើមរលត់។ ឧទាហរណ៍៖ ក្នុងចំណោមម្ចាស់បំណុលចំនួន ៣នាក់ បានសម្រេចឲ្យម្ចាស់បំណុលតែម្នាក់ធ្វើការទទួលយកការសងនូវកាតព្វកិច្ច ដែលកូនបំណុលមានចំពោះម្ចាស់បំណុលនីមួយៗ។

-ការប្តូរកូនបំណុល អាចធ្វើបាននូវពេលដែលកាតព្វកិច្ចលើបំណុលបានកើតឡើងថ្មី ចំពោះកូនបំណុលផ្សេងទៀតដែលមិនមែនជាកូនបំណុលដើម ហើយត្រូវបង្វិលកាតព្វកិច្ចទាំងអស់ទៅកូនបំណុលថ្មីនោះវិញ។

[33] មាត្រា ៤៧៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[34] មាត្រា៤៧៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ប្រសិនបើកាតព្វកិច្ចថ្មីដែលបានបង្កើតឡើងដោយនវកម្ម មិនអាចអនុវត្តដោយកូនបំណុលបានតាំងពីដំបូង កាតព្វកិច្ចចាស់ក៏មិនត្រូវបានរំលត់ដែរ ដោយហេតុថានវកម្មនោះគ្មានអានុភាព។

នវកម្មបង្កើតឡើងដើម្បីរំលត់នូវកាតព្វកិច្ចចាស់ ដូចនេះប្រសិនបើកាតព្វកិច្ចគ្មានអានុភាពនវកម្មក៏មិនអាចកើតឡើងបានទេ ហើយកាតព្វកិច្ចដើមក៏មិនត្រូវបានរំលត់ដែរ[35]។ ក្នុងនោះនវកម្មនិងគ្មានអានុភាព នៅពេលដែលករណីពីរខាងក្រោមកើតឡើង៖

-ករណីដែលកាតព្វកិច្ចថ្មីមិនបានបង្កើតអានុភាព ដោយសារមូលហេតុច្បាប់។ កាតព្វកិច្ចដែលមានលក្ខណៈផ្ទុយពីច្បាប់ ហើយបង្កផលប៉ះពាល់ដល់ទំនៀមទម្លាប់ល្អ និងសណ្តាប់ធ្នាប់សាធារណៈនាំឲ្យកាតព្វកិច្ចថ្មីនោះគ្មានភាពស្របច្បាប់ហើយនវកម្មក៏គ្មានអានុភាពផងដែរ។

-ករណីដែលកាតព្វកិច្ចថ្មីមិនបានបង្កើតអានុភាព ដោយសារមូលហេតុភាគីដែលពាក់ព័ន្ធមិនអាចព្យាករបាន។ ករណីនេះ កូនបំណុលនៃកាតព្វកិច្ចនោះមិនអាចអនុវត្តបាន ឬមិនអាចផ្តល់តាវកាលិកថ្មីឲ្យទៅម្ចាស់បំណុលបាន នាំឲ្យកាតព្វកិច្ចថ្មីនោះគ្មានអានុភាព។

ឧទាហរណ៍៖ លោក "ក" និង លោក "ខ" បង្កើតកិច្ចសន្យាខ្ចីប្រាក់ ១.០០០ ដុល្លារ។ លោក "ក" ជាកូនបំណុលរបស់លោក "ខ" ហើយក៏បានព្រមព្រៀងគ្នាកំណត់ពេលវេលាសងប្រាក់។ លុះដល់ថ្ងៃកំណត់លោក "ក" ពុំមានលទ្ធភាពក្នុងការសងប្រាក់ ក៏បានស្នើសុំលោក "ខ" បង្កើតនូវកិច្ចសន្យាថ្មីមួយដោយលោក "ក" ត្រូវធ្វើការអោយលោក "ខ" ក្នុងរយៈពេល ៣ខែ។ លោក "ខ" ក៏បានយល់ព្រមជាមួយលោក "ក" បានបង្កើតកិច្ចសន្យាថ្មីដែលបញ្ជាក់ពីការរលត់កាតព្វកិច្ចចាស់ ដោយបង្កើតកាតព្វកិច្ចថ្មីដែលតម្រូវអោយលោក "ក" ធ្វើការជំនួសនូវការសងប្រាក់។ ដូចនេះកាត្វកិច្ចដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ពីមុនត្រូវបានរំលត់ដោយនវកម្ម។ ក្នុងករណីដែលលោក "ក" មិនអនុវត្តតាមកិច្ចសន្យាថ្មី នាំឲ្យកាតព្វកិច្ចចាស់ដែលមានចែងក្នុងកិច្ចសន្យាថ្មីពីមុនមិនរលត់នោះទេ ព្រោះនវកម្មដោយកិច្ចសន្យាថ្មីនោះគ្មានអានុភាព ដោយហេតុថាកាតព្វកិច្ចទាំងអស់មិនត្រូវបានអនុវត្ត។

យ៉ាងណាមិញ ក្នុងករណីដែលកូនបំណុលសុំឲ្យតតិយជនណាម្នាក់ប្រតិបត្តិកាតព្វកិច្ចជួសខ្លួនហើយមានការយល់ព្រមពីតតិយជននោះ រួមទាំងម្ចាស់បំណុល ត្រូវចាត់ទុកថានវកម្ម[36]។ យើងឃើញថានៅពេលដែលតតិយជនអនុវត្តកាតព្វកិច្ចជំនួសកូនបំណុល ដោយម្ចាស់បំណុលយល់ព្រមលើសំណើនេះ បណ្តាលអោយកាតព្វកិច្ចរបស់កូនបំណុលដើមនឹងត្រូវរលត់ ហើយតតិយជននោះនិងត្រូវអនុវត្តជំនួស។

ព្យាកុលភាព គឺជាការរំលត់សិទ្ធិលើបំណុល និងការរំលត់កាតព្វកិច្ច នៅពេលដែលសិទ្ធិលើបំណុល និងកាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់។ យើងឃើញថា កូនបំណុលដែលចេញសងជំនួស

[35] មាត្រា៤៧៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[36] ញឹករុធ្វីទំព័រទី១៦,នីតិកាតព្វកិច្ច,

កូនបំណុលឯទៀតដោយឈរជាម្ចាស់បំណុលផង និងកូនបំណុលផង តែបើនៅក្នុងករណីដែលសិទ្ធិលើបំណុលនោះជារបស់តតិយជននោះវិញ វាជាមូលហេតុមួយធ្វើអោយកាតព្វកិច្ចនេះមិនអាចត្រូវបានគេរលត់ដោយព្យាកុលភាពបានឡើយ[37]។ ព្យាកុលភាពអាចស្តែងចេញក្នុងរូបភាពមួយចំនួនដូចជា ប្រទានកម្ម សន្តតិកម្ម និងអច្ច័យទាន។

ឧទាហរណ៍៖ លោក "ក" និង លោក "ខ" ជាឪពុក និងកូនបង្កើត។ ថ្ងៃមួយលោក "ក" ដែលជាកូនបានខ្ចីលុយ លោក "ខ" ដែលជាឪពុកក្នុងការរកស៊ី ចំនួន ១០០.០០០.០០០ រៀល។ ១០ឆ្នាំកន្លង លោក "ខ" បានទទួលមរណភាព ប៉ុន្តែគាត់បានធ្វើសន្តតិកម្មមរតករបស់គាត់អោយទៅកូនរបស់គាត់ដែលមានទឹកប្រាក់ ៥០០.០០០.០០០ រៀល។ នៅពេលនោះបំណុល និងមរតកដែល លោក "ក" ទទួលបានធ្លាក់លើបុគ្គលតែម្នាក់គឺ លោក "ក" នាំឲ្យកាតព្វកិច្ចត្រូវបានរលត់។

### ២.១.៥. ការទទួលបន្ទុកហានិភ័យ

ការទទួលបន្ទុកហានិភ័យ គឺជាការរលត់កាតព្វកិច្ចដែលកើតឡើងដោយអលទ្ធភាព។ ក្នុងនោះបើការអនុវត្តកាតព្វកិច្ចក្លាយជាអលទ្ធភាព ហើយកូនបំណុលគ្មានកំហុសចំពោះអលទ្ធភាព នោះកាតព្វកិច្ចត្រូវរលត់ ហើយម្ចាស់បំណុលមិនអាចទាមទារតាវកាលិកបានទេ[38]។ ប៉ុន្តែក្នុងករណីដែលអលទ្ធភាពមានកំហុសរបស់កូនបំណុលវិញនោះ កាតព្វកិច្ចនឹងមិនត្រូវបានរលត់ទេ។

ចំពោះកិច្ចសន្យាទ្វេភាគី ភាគីទាំងសងខាងមានកាតព្វកិច្ច និងសិទ្ធិទាមទារចំពោះគ្នាទៅវិញទៅមក។ ឧទាហរណ៍៖ "ក" ជាអ្នកលក់ មានកាតព្វកិច្ចផ្ទេរកម្មវត្ថុ និងសិទ្ធិទាមទារឲ្យបង់ប្រាក់ ចំណែកឯ "ខ" វិញជាអ្នកទិញ មានកាតព្វកិច្ចបង់ប្រាក់ និងសិទ្ធិទាមទារឲ្យផ្ទេរកម្មវត្ថុ។ យើងឃើញថាក្នុងទំនាក់ទំនងនេះ កាតព្វកិច្ចផ្ទេរ និងសិទ្ធិទាមទារឲ្យផ្ទេរ ហើយកាតព្វកិច្ចបង់ប្រាក់ និងសិទ្ធិទាមទារឲ្យបង់ប្រាក់ គឺដូចជាមុខពីរនៅលើកាក់តែមួយ។ ដូចនេះ ប្រសិនបើកាតព្វកិច្ចផ្ទេរត្រូវរលត់នោះសិទ្ធិទាមទារក៏ត្រូវរលត់ដែរ។ ក្នុងករណីដែលកូនបំណុលគ្មានកំហុសចំពោះអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច នោះកាតព្វកិច្ចត្រូវរលត់ ហើយម្ចាស់បំណុលមិនអាចទាមទារតាវកាលិកបានទេ។ កូនបំណុលនៅពេលនេះ សំដៅលើបុគ្គលដែលមានកាតព្វកិច្ចផ្ទេរកម្មវត្ថុ និងម្ចាស់បំណុល សំដៅលើបុគ្គលដែលមានសិទ្ធិទាមទារឲ្យផ្ទេរកម្មវត្ថុ។ ដូច្នេះប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាលក់ទិញត្រូវបានខូចខាត ដោយគ្មានកំហុសរបស់ "ក" នោះកាតព្វកិច្ចផ្ទេរត្រូវបានរលត់ ហើយ "ខ" មិនអាចទាមទារការផ្ទេរកម្មវត្ថុបានទេ។

បន្ទាប់មក តើ "ក" អាចទាមទារ "ខ" ឲ្យបង់ប្រាក់បានដែរឬទេ នៅក្នុងករណីខាងលើ? បញ្ហានៃបន្ទុកហានិភ័យ គឺសំដៅលើបុគ្គលណាជាអ្នកទទួលបន្ទុកហានិភ័យ ប្រសិនបើកាតព្វកិច្ចផ្ទេរក្លាយជា

[37] មាត្រា៤៧៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[38] មាត្រា៤១៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

អលទ្ធភាព? តើជាកូនបំណុល ឬជាម្ចាស់បំណុលដែលត្រូវទទួល? ហើយចំពោះករណីដែលកម្មវត្ថុដែលត្រូវធ្វើការផ្ទេរត្រូវបានខូចខាត ដោយគ្មានកំហុសរបស់ភាគីទាំងសងខាង នោះកាតព្វកិច្ចតបត្រូវរលត់ ឬអត់?

ទាក់ទងទៅនិងចំណុចនេះ មានគោលគំនិតពីរៈ

-គោលគំនិតដែលតាវកាលិកតបត្រូវរលត់ៈ ក្នុងករណីខាងលើ ប្រសិនបើកាតព្វកិច្ចបង់ប្រាក់របស់ "ខ" ត្រូវបានរលត់នោះ "ខ" មិនត្រូវបង់ប្រាក់ថ្លៃទិញទៀតទេ។ បានន័យថា "ក" ជាអ្នកបាត់បង់ផលប្រយោជន៍ នោះ "ក" ត្រូវទទួលបន្ទុកហានិភ័យ។

-គោលគំនិតដែលតាវកាលិកតបមិនត្រូវរលត់ៈ ប្រសិនបើតាវកាលិកតបមិនត្រូវបានរលត់ "ខ" នៅតែមានកាតព្វកិច្ចបង់ប្រាក់ ទោះបីជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបានធ្វើឲ្យខូចខាត និងអលទ្ធភាពក្នុងការផ្ទេរ។ បានន័យថា ម្ចាស់បំណុលត្រូវទទួលបន្ទុកហានិភ័យ។

គោលគំនិតទាំងពីរខាងលើអាចអនុវត្តបាន វាអាស្រ័យទៅលើប្រភេទនៃកម្មវត្ថុ។

ក្នុងកិច្ចសន្យាអញ្ញមញ្ញ ឬកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ នៅពេលដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬបាត់បង់ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេនោះកូនបំណុលត្រូវទទួលបន្ទុកហានិភ័យ។ ជាងនេះទៅទៀត ចំពោះកិច្ចសន្យាអញ្ញមញ្ញ ដែលមានគោលបំណងផ្ទេរកម្មសិទ្ធិលើវត្ថុដែល មិនបានកំណត់ជាក់លាក់ ក្នុងករណីវត្ថុដែលត្រូវផ្តល់មិនទាន់បានកំណត់ ទោះបីជាវត្ថុដែលខ្លួនបានរៀបចំដើម្បីអនុវត្ត បាត់បង់ដោយគ្មានកំហុសរបស់ខ្លួនក៏ដោយក៏កាតព្វកិច្ចនោះមិនត្រូវបានរលត់ដែរ។ បានន័យថា នៅក្នុងករណីនេះកូនបំណុលត្រូវទទួលបន្ទុកហានិភ័យ[39]។

លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា ហានិភ័យដោយសារការបាត់បង់ ឬខូចខាតវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវផ្ទេរទៅឲ្យម្ចាស់បំណុលនៅពេលណាមួយក្នុងចំណោមពេលដែលបានកំណត់ដូចខាងក្រោមនេះ[40]ៈ

-ពេលដែលប្រគល់វត្ថុដែលជាកម្មវត្ថុទៅម្ចាស់បំណុល ឬពេលដែលចុះបញ្ជីផ្ទេរអចលនវត្ថុ ឬពេលផ្សេងទៀតដែលយល់ឃើញថា ការគ្រប់គ្រងជាក់ស្តែងលើវត្ថុជាកម្មវត្ថុត្រូវបានផ្ទេរទៅម្ចាស់បំណុល។

-ពេលដែលកូនបំណុលបានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចត្រឹមត្រូវ។

-ពេលដែលម្ចាស់បំណុលប្រកែកមិនព្រមទទួលអនុវត្តរបស់កូនបំណុល ដោយគ្មានមូលហេតុត្រឹមត្រូវ។

[39] មាត្រា៤១៦, កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[40] មាត្រា៤១៦, កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ករណីផ្សេងទៀតដែលម្ចាស់បំណុលត្រូវទទួលបន្ទុកហានិភ័យ គឺនៅពេលដែលអលទ្ធភាពក្នុងការអនុវត្តដោយកំហុសរបស់ម្ចាស់បំណុល ហើយកូនបំណុលមិនត្រូវបាត់បង់នូវតាវកាលិកពីម្ចាស់បំណុលទេ។ ប៉ុន្តែប្រសិនបើកូនបំណុលបានទទួលផលប្រយោជន៍ ដោយការរួចផុតពីកាតព្វកិច្ចរបស់ខ្លួន កូនបំណុលត្រូវប្រគល់ផលប្រយោជន៍នេះទៅម្ចាស់បំណុលវិញ។

## ២.២.ការរំលត់កាតព្វកិច្ចតាមច្បាប់កំណត់

ជាការពិតណាស់ កាតព្វកិច្ចត្រូវរលត់ដោយកូនបំណុលបានសងបំណុលទៅឲ្យម្ចាស់បំណុល ឬតតិយជនបានសងជំនួសកូនបំណុល ឬការសម្តែងឆន្ទៈលើកលែងនូវបំណុលដោយម្ចាស់បំណុលមានការអាណិតអាសូរ ឬដោយសកម្មភាពណាមួយផ្សេងទៀត។ ប៉ុន្តែគូភាគីក៏អាចរំលត់កាតព្វកិច្ចផងដែរដោយសារភាគីទាំងសងខាង ឬតែម្ខាង មានកំហុសនៅក្នុងកិច្ចសន្យាដែលច្បាប់បានកំណត់។ ក្នុងនោះការរំលត់កាតព្វកិច្ចតាមច្បាប់កំណត់រួមមាន ការរំលាយកិច្ចសន្យា ការផុតអាជ្ញាយុកាល និងការអនុវត្តសិទ្ធិលុបចោល។

### ២.២.១.ការរំលាយកិច្ចសន្យា

កិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានគូភាគីពីរ គឺម្ចាស់បំណុល និងកូនបំណុល ដែលក្នុងនោះការរំលត់កាតព្វកិច្ចត្រូវបានកើតឡើងដោយកូនបំណុលនៃកិច្ចសន្យាមិនអនុវត្តកាតព្វកិច្ច ដែលកើតឡើងពីកិច្ចសន្យានោះ។ តាមរយៈកិច្ចសន្យាអញ្ញមញ្ញភាគីម្ខាងនៃកិច្ចសន្យាអាចរំលាយកិច្ចសន្យានោះបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានយ៉ាងធ្ងន់ធ្ងរ។[41] បន្ថែមពីលើនេះផងដែរទាក់ទងទៅនឹងការបំពានធ្ងន់ធ្ងរ សំដៅលើការមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាដោយការបំពានអំពីភាគីម្ខាងនៃកិច្ចសន្យា។ ក្នុងន័យនេះផងដែរ ប្រសិនបើការបំពាននោះមានលក្ខណៈស្រាលមិនធ្ងន់ធ្ងរ ឬមិនបានអនុវត្តកាតព្វកិច្ចបន្តិចបន្តួចនោះ ភាគីម្ខាងទៀតមិនអាចធ្វើការរំលាយកិច្ចសន្យាបាននោះទេ។ វាក៏មិនមានលក្ខណៈដាច់ខាតនោះទេ ភាគីម្ខាងដែលមិនបានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន ភាគីម្ខាងទៀតអាចទាមទារអោយភាគីម្ខាងដែលជាប់កាតព្វកិច្ចនោះអនុវត្តកាតព្វកិច្ចនោះម្តងទៀតបាន ដោយផ្តល់អោយនូវពេលវេលាដែលសមរម្យណាមួយ ប៉ុន្តែបើភាគីម្ខាងទៀតនៅតែមិនអនុវត្តកាតព្វកិច្ចទៀតនោះ ភាគីម្ខាងទៀតអាចទាមទារឲ្យរំលាយកិច្ចសន្យាបាន។ ភាគីម្ខាងអាចធ្វើការរំលត់កាតព្វកិច្ចដោយតាមរយៈការរំលាយកិច្ចសន្យា ដោយយោងតាមលក្ខខណ្ឌមួយចំនួនហើយវានិងបង្កើតអានុភាពផងដែរ។

#### ២.២.១.១. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា

លក្ខខណ្ឌដែលអាចធ្វើការរំលាយកិច្ចសន្យា ដោយមូលហេតុនៃការបំពានធ្ងន់ធ្ងរមានដូចខាងក្រោម៖[42]

---

[41] មាត្រា៤០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[42] មាត្រា៤០៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

-ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀត ដែលមិនបានអនុវត្តកាតព្វកិច្ចតាមការកំណត់ដោយអំឡុងពេលសមរម្យ ដើម្បីធ្វើការអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។ ក្នុងន័យនេះ គឺម្ចាស់បំណុលបានធ្វើការដាស់តឿនភាគីដែលមិនអនុវត្តកាតព្វកិច្ច តាមកាលកំណត់ ហើយបានអោយភាគីដែលមិនអនុវត្តកាតព្វកិច្ចអនុវត្តម្តងទៀតក្នុងរយៈពេលមួយសមរម្យ ប៉ុន្តែកូនបំណុលនៅតែមិនអនុវត្តតាមការកំណត់របស់ខ្លួនទៀត នោះម្ចាស់បំណុលអាចធ្វើការរំលាយកិច្ចសន្យាបានភ្លាម។ ឧទាហរណ៍៖ លោក "ក" បានធ្វើកិច្ចសន្យាទិញលក់ឡានជាមួយលោក "ខ" ហើយលោក "ក" បានប្រគល់ឡានអោយទៅលោក "ខ" ប៉ុន្តែលោក "ខ" មិនបានបង់ប្រាក់តាមកាលបរិច្ឆេទកំណត់ក្នុងកិច្ចសន្យាទេ លោក "ក" ក៏បានដាស់តឿន លោក "ខ" ក្នុងការប្រគល់ប្រាក់ថ្លៃទិញឡានដោយកំណត់អំឡុងពេលសមរម្យមួយសម្រាប់អនុវត្តកាតព្វកិច្ច ប៉ុន្តែ លោក "ខ" មិនបានបង់ប្រាក់ថ្លៃទិញក្នុងអំឡុងពេលដែលបានកំណត់នោះទេ ដូច្នេះលោក "ក" អាចធ្វើការរំលាយកិច្ចសន្យាបាន ហើយកម្មវត្ថុនៃកិច្ចសន្យាមិនមានលក្ខណៈប្រតិសកម្មដោយ លោក "ខ" ត្រូវប្រគល់ឡានទៅលោក "ក" វិញ។

-ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមការកំណត់នោះ។ បានន័យថា ភាគីម្ខាងមិនបានអនុវត្តទៅតាមកាតព្វកិច្ចដែលខ្លួនត្រូវអនុវត្ត ដែលភាគីដែលជាម្ចាស់បំណុលមានបំណងអោយធ្វើក្នុងអំឡុងពេលកំណត់មួយ ដែលក្នុងនោះប្រសិនបើផុតអំឡុងពេលនោះ កម្មវត្ថុនៃកិច្ចសន្យានឹងបាត់បង់នូវប្រយោជន៍ ឬខុសពីគោលបំណងរបស់ម្ចាស់បំណុល។ ឧទាហរណ៍៖ លោក "ក" និងលោក "ខ" បង្កើតកិច្ចសន្យាមួយ ដែលលោក "ខ" ជាអ្នកផ្គត់ផ្គង់ភេសជ្ជៈ សម្រាប់មង្គល់ការរបស់លោក "ក" ។ ប៉ុន្តែលោក "ខ" បានខកខានក្នុងការផ្តល់នូវភេសជ្ជៈសម្រាប់ថ្ងៃមង្គល់ការរបស់ លោក "ក"។ លោក "ក" អាចធ្វើការរំលាយកិច្ចសន្យានេះ ដោយលោក "ខ" មិនបានអនុវត្តតាមការកំណត់នៃកិច្ចសន្យា ហើយគោលបំណងនៃកិច្ចសន្យាក៏គ្មានបានសម្រេចអ្វី។

-ភាគីមិនអាចអនុវត្តករណីកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ។ បានន័យថា ភាគីម្ខាងដែលជាកូនបំណុលមិនអាចអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ទៅតាមគោលបំណងនៃកម្មវត្ថុរបស់កិច្ចសន្យានាំឲ្យម្ចាស់បំណុលអាចធ្វើការរំលាយកិច្ចសន្យាបាន។ ឧទាហរណ៍៖ លោក "ក" និងលោក "ខ" បង្កើតកិច្ចសន្យាទិញលក់ទូរស័ព្ទមួយគ្រឿងដោយកំណត់ពេលវេលា។ ថ្ងៃប្រគល់វត្ថុ ស្រាប់តែទូរសព្ទ័របស់លោក "ក" ដែលជាអ្នកលក់នោះបានបាត់ដោយចោរលួច នោះលោក "ក" មិនអាចប្រគល់នូវកម្មវត្ថុនៃកិច្ចសន្យាឲ្យទៅលោក "ខ" នោះទេ។ ដូចនេះលោក "ខ" អាចធ្វើការរំលាយកិច្ចសន្យាបានដោយសម្អាងហេតុផល លោក "ក" មិនអាចប្រគល់ទូរស័ព្ទដែលជាតាវកាលិកចម្បងនៃកិច្ចសន្យាទិញលក់ទៅអោយខ្លួន។

-ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើអោយបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិន

អាចជឿជាក់បាន នឹងអនុវត្តកាតព្វកិច្ចនោះទៅថ្ងៃអនាគតបាន។ បានន័យថា ភាគីទាំងពីរបង្កើតកិច្ចសន្យាដែលមានលក្ខណៈយូរ ឬបន្តបន្ទាប់ក្នុងការអនុវត្តករណីកិច្ច និងកាតព្វកិច្ច ប៉ុន្តែភាគីម្ខាងនៃកិច្ចសន្យាអនុវត្តកាតព្វកិច្ចដោយបំពានភាគីម្ខាងទៀត ម្តងហើយម្តងទៀតរហូតដល់ភាគីម្ខាងនៃកិច្ចសន្យានោះអស់ជំនឿនិងទំនុកចិត្តក្នុងការអនុវត្តកាតព្វកិច្ច។ ឧទាហរណ៍៖ លោក "ក" និង លោក "ខ" បានបង្កើតកិច្ចសន្យាផ្គត់ផ្គង់សំណង់ ដោយលោក "ខ" ជាអ្នកផ្គត់ផ្គង់សម្រាប់លោក "ក" ប្រចាំខែ។ លោក "ខ" បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដំបូងមានលក្ខណៈត្រឹមត្រូវតាមកម្មវត្ថុនៃកិច្ចសន្យាដោយប្រគល់គ្រឿងសំណង់ឲ្យទាន់កាលកំណត់។ មិនយូរលោក "ខ" បានផ្គត់ផ្គង់គ្រឿងសំណង់ដោយយឺតយ៉ាវថ្ងៃកំណត់ម្តងហើយម្តងទៀតនោះនាំអោយលោក "ក" ខាតបង់ប្រាក់កាក់។ ក្នុងករណីនេះ លោក "ក" អាចធ្វើការរំលាយកិច្ចសន្យាដោយមូលហេតុ លោក "ខ" បំពានកិច្ចសន្យាមានលក្ខណៈហួសហេតុ។

ប្រសិនបើមានករណីណាមួយ ក្នុងចំណោមករណីទាំងអស់ខាងលើកើតឡើងក្នុងពេលអនុវត្តកាតព្វកិច្ចនោះចាត់ទុកថាជាការបំពានកាតព្វកិច្ចធ្ងន់ធ្ងរ ហើយដែលបាត់បង់ប្រយោជន៍ អាចធ្វើការរំលាយកិច្ចសន្យា។ ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន ហើយម្យ៉ាងទៀតការបង្ហាញឆន្ទៈនេះមិនអាចដកវិញបានទេ ដោយសារការបង្ហាញឆន្ទៈនេះអាចមានភាពមិនច្បាស់លាស់ ធ្វើអោយកិច្ចសន្យាដែលបានរំលាយហើយមានអានុភាពឡើងវិញ ប៉ុន្តែភាគីដែលបង្ហាញឆន្ទៈក្នុងការរំលាយនេះ អាចដាក់លក្ខខណ្ឌបង្អង់បានដោយដាស់តឿនឲ្យភាគីអនុវត្តកាតព្វកិច្ចម្តងទៀត ប្រសិនបើនៅតែមិនអនុវត្ត ខ្លួននឹងរំលាយកិច្ចសន្យានោះ។[43]

សិទ្ធិក្នុងការរំលាយកិច្ចសន្យានឹងត្រូវរលត់ ក្នុងករណីដែលអ្នកដែលទទួលបានសិទ្ធិរំលាយនោះបានធ្វើអោយខូចខាត ឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនអាចសងវត្ថុនោះវិញបាន ឬវត្ថុនោះត្រូវបាគេកែច្នៃឲ្យក្លាយជាវត្ថុអ្វីផ្សេងមួយទៀត។ ប្រសិនបើកម្មវត្ថុនោះមានកំណត់តម្លៃ ភាគីបង្កត្រូវសងមកវិញសមស្របទៅនិងតម្លៃនៃវត្ថុនោះ។ ក្នុងករណីដែលការខូចខាតនៃវត្ថុនោះត្រូវបានប្រព្រឹត្តិឡើងដោយភាគីម្ខាង ដែលភាគីនោះមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាមិនចាំបាច់ធ្វើការសងការខូចខាតនៃវត្ថុនោះទេ។ ម្យ៉ាងវិញទៀតអ្នកដែលមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាត្រូវបានបាត់បង់សិទ្ធិ នៅពេលដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬបាត់បង់ដោយទង្វើរបស់ខ្លួន។[44]

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច

[43] មាត្រា៤០៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[44] មាត្រា៤១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

មានអំឡុងពេលប្រាំឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច។[45] ការកំណត់អំឡុងពេលប្រាំឆ្នាំ ក្នុងការទទួលសិទ្ធិដើម្បីរំលាយកិច្ចសន្យា ដោយគិតចាប់ពីថ្ងៃដែលទទួលបានសិទ្ធិនោះ ប្រសិនបើហួសរយៈពេលនេះ សិទ្ធិក្នុងការរំលាយកិច្ចសន្យាក៏ត្រូវបានរលត់ផងដែរ។

ក្នុងការរំលាយកិច្ចសន្យានេះផងដែរ ភាគីទាំងពីរនៃកិច្ចសន្យាអាចធ្វើការព្រមព្រៀងគ្នា ដោយមិនចាំបាច់ក្នុងករណីដែលមានកំហុសរបស់ភាគីដែលអនុវត្តកិច្ចសន្យានោះទេ។

**២.២.១.២. អានុភាពនៃការរំលាយកិច្ចសន្យា**

ការរំលត់កាតព្វកិច្ចតាមរយៈការរំលាយកិច្ចសន្យា បណ្ដាលអោយកើតមានអានុភាពចំពោះគូភាគី និងចំពោះតតិយជនផងដែរ។

-អានុភាពចំពោះគូភាគី៖ ការរំលាយកិច្ចសន្យាបណ្ដាលអោយរាល់កាតព្វកិច្ចទាំងឡាយ របស់គូភាគីដែលកើតឡើងដោយកិច្ចសន្យានឹងត្រូវរលត់ ហើយធ្វើអោយគូភាគីនៃកិច្ចសន្យារួចផុតពីកិច្ចសន្យានោះបាន ប៉ុន្តែក្នុងករណីមានសំណងការខូចខាតដែលកើតមានពីការរំលាយកិច្ចសន្យានោះ អានុភាពនៃការសងការខូចខាតរបស់កូនបំណុលនៅតែមាន។ ភាគីដែលទទួលបានតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬទាំងអស់ ត្រូវមានករណីកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីអោយភាគីនោះទទួលបដិទានឡើងវិញដោយសារការរំលាយ។ ចំណែកក្នុងករណីដែលភាគីទាំងសងខាង មានករណីកិច្ចធ្វើបដិទានទៅវិញទៅមក ករណីកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។ បដិទាន សំដៅលើការស្ដារឡើងវិញនូវស្ថានភាពដើម ឬការប្រគល់ត្រឡប់វិញ។ ការរំលាយកិច្ចសន្យាគឺនាំឲ្យមានករណីកិច្ចធ្វើបដិទាន និងមានទំនាក់ទំនងជាមួយនឹងការអនុវត្តករណីកិច្ចក្នុងពេលជាមួយគ្នា។ បន្ថែមពីលើនេះផងដែរ ក្នុងករណីដែលគូភាគីមានករណីកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យា ពេលនោះអានុភាពរបស់វាគឺ ភាគីត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលប្រាក់ដើម។ ចំពោះភាគីដែលមានករណីកិច្ចបង្វិលជាវត្ថុ ឬជាតាវកាលិកផ្សេងៗ ដែលខ្លួនបានទទួលទៅភាគីម្ខាងទៀត ដោយសារការរំលាយត្រូវសងទាំងផលដែលទទួលបានពីវត្ថុ ឬតាវកាលិកនោះផងដែរ។

-អានុភាពចំពោះតតិយជន៖ អានុភាពដែលកើតចេញពីការរំលាយកិច្ចសន្យា មិនត្រឹមតែគូភាគីនោះទេ តែវាក៏មានអានុភាពចំពោះតតិយជនផងដែរ។ ចំពោះការរំលាយកិច្ចសន្យាមិនអាចធ្វើឲ្យខូចខាតប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ។ ក្នុងន័យនេះ ការការពារផលប្រយោជន៍របស់តតិយជន ក្នុងករណីដែលតតិយជននោះគឺជាជនសុចរិត និងគ្មានកំហុសតែប៉ុណ្ណោះ ចំណែកឯតតិយជនដែលជាជនទុច្ចរិត ឬសុចរិត តែមានកំហុសមិនត្រូវបានការពារឡើយ ព្រោះគាត់មិនមានផលប្រយោជន៍ត្រឹមត្រូវទេ។[46]

[45] មាត្រា៤១៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[46] មាត្រា៤១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

### ២.២.២.ការផុតអាជ្ញាយុកាល

អាជ្ញាយុកាលនៃការរំលត់កាតព្វកិច្ច សំដៅទៅលើការរលត់សិទ្ធិលើបំណុល ដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិលើក្នុងអំឡុងពេលដែលត្រូវបានកំណត់[47]។ កូនបំណុលត្រូវបានការពារដោយវិធាននៃការផុតអាជ្ញាយុកាលនេះ ដោយរឹតត្បឹតនូវសិទ្ធិរបស់ម្ចាស់បំណុលមានប្រសិទ្ធិភាពតាមកាលកំណត់មួយជាក់លាក់។ ក្នុងនោះផងដែរ ដើម្បីធ្វើឲ្យរលត់សិទ្ធិណាមួយ ការកំណត់អំឡុងពេលនៃអាជ្ញាយុកាលត្រូវសមល្មម សក្តិសមសម្រាប់ឲ្យម្ចាស់បំណុលមានពេលគ្រប់គ្រាន់ក្នុងការអនុវត្ត។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ ត្រូវបានគិតចាប់តាំងពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន។

#### ២.២.២.១.លក្ខខណ្ឌ

ជាការពិតណាស់លក្ខខណ្ឌនៃអាជ្ញាយុកាលសិទ្ធិលើបំណុល គឺជាលក្ខខណ្ឌដែលកំណត់ថា រយៈពេលប៉ុន្មានដែលសិទ្ធិលើបំណុលត្រូវបានរលត់ និងនៅពេលដែលរយៈពេលដែលសិទ្ធិលើបំណុលត្រូវបានរលត់ហើយ តើវានឹងមានអានុភាពកើតឡើងយ៉ាងដូចម្តេចដែរ?

អំឡុងពេលអាជ្ញាយុកាល គឺជារយៈពេលសម្រាប់ភាគីដែលទទួលការខូចខាតអាចធ្វើបណ្តឹងទាមទារសំណងចំពោះកិច្ចសន្យាណាមួយបាន។ ជាគោលការណ៍អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានរយៈពេលប្រាំឆ្នាំ[48]។ ប៉ុន្តែទាក់ទងនឹងសិទ្ធិលើបំណុលថ្លៃទិញទំនិញ ឬសេវារវាងផលិតករ ឬពាណិជ្ជករលក់ទៅឲ្យអ្នកមិនមែនជាពាណិជ្ជករ គឺរយៈពេលនៃអាជ្ញាយុកាលមានត្រឹមតែ២ឆ្នាំ ប៉ុណ្ណោះ ពីព្រោះសិទ្ធិលើបំណុលចំពោះអ្នកប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការរបស់អ្នកប្រើប្រាស់មានការពិបាកនឹងរក ព្រមទាំងការរក្សាទុកនៃភស្តុតាងក្នុងការសង។[49] ឧទាហរណ៍៖ លោក "ក" បានទិញទំនិញនៅហាងរបស់លោក "ខ" នៅថ្ងៃ ០១ ខែ មីនា ឆ្នាំ ២០១៧ ប៉ុន្តែអត់បានអោយប្រាក់។ ដូចនេះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺមានរយៈពេលតែពីរឆ្នាំ គិតចាប់ពីថ្ងៃ ០១ ខែ មីនា ឆ្នាំ២០១៧។ ម្យ៉ាងវិញទៀត ចំពោះសិទ្ធិលើបំណុលដែលបានចូលជាស្ថាពរ ដោយអានុភាពសាលក្រម ឬសាលដីការស្ថាពរ ឬការផ្សះផ្សារតាមផ្លូវតុលាការ ឬវិធីផ្សេងទៀតដែលមានអានុភាពដូចនឹងសាលក្រមស្ថាពរ រយៈពេលនៃអាជ្ញាយុកាលត្រូវមានអំឡុងពេលប្រាំឆ្នាំ គិតចាប់ពីថ្ងៃដែលសិទ្ធិលើបំណុលដើមចូលជាស្ថាពរដែរ។[50] ផ្ទុយមកវិញ ប្រសិនបើនៅពេលដែលលិខិតទាំងនោះចូលជាស្ថាពរ មុនពេលកំណត់ត្រូវអនុវត្តមិនទាន់មកដល់ រយៈពេលនៃអាជ្ញាយុកាលគឺមានរយៈពេលប្រាំ

[47] មាត្រា៤៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[48] មាត្រា៤៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[49] មាត្រា៤៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[50] មាត្រា៤៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ឆ្នាំ ឬពីរឆ្នាំគិតចាប់ពីពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចមកដល់។ ក្រឡែកទៅសិទ្ធិលើទ្រព្យសម្បត្តិដែលក្រៅពីសិទ្ធិលើបំណុវិញ មានរយៈពេលដប់ឆ្នាំសម្រាប់ការធ្វើបណ្តឹងទាមទារសំណង តែបើរយៈពេលនេះបានកន្លងផុតនោះ សិទ្ធិលើបំណុលនឹងត្រូវរលត់ដោយការផុតអាជ្ញាយុកាល។

តុលាការមិនអាចលើកឡើងនូវអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ដោយខ្លួនឯងបានទេ ទោះបីជាបានដឹងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏ដោយ ពីព្រោះបើអនុញ្ញាតឲ្យតុលាការអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺវាបំពាននូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ លើសពីនេះទៀត បញ្ហានៃការលើកឡើងនេះជាផលប្រយោជន៍របស់ភាគីទេ នោះការលើកឡើងពីអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលរបស់ភាគីដែលមានប្រយោជន៍នេះ គឺជាភាពចាំបាច់មួយដើម្បីឲ្យតុលាការធ្វើការវិនិច្ឆ័យ ដើម្បីចេញសាលក្រមដោយផ្អែកលើងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ជាគោលការណ៍ បុគ្គលដែលអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺមានតែកូនបំណុល កូនបំណុលសាមគ្គី អ្នកធានា អ្នកធានាដោយវត្ថុ និងតតិយជនដែលបានធ្វើលទ្ធកម្មទេ ប៉ុន្តែក្នុងច្បាប់បានអនុញ្ញាតឲ្យបុគ្គលដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ ក៏អាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានផងដែរ។ ផ្អែកលើគោលការណ៍នៃភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស ក្នុងករណីដែលកូនបំណុលបានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់កាតព្វកិច្ចសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល ដែលនាំឲ្យផលប្រយោជន៍ដែលកើតចេញពីការលើកឡើងនេះ ក៏ត្រូវកើតមានចំពោះតតិយជនដែរ។ ផ្ទុយទៅវិញបើបុគ្គលដែលមិនមែនជាកូនបំណុលដែលមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាល ហើយបានលើកឡើងធ្វើឲ្យកាតព្វកិច្ចនោះរំលត់វិសាលភាពនៃការលើកឡើងនេះ មានតែរវាងបុគ្គលដែលបានលើកឡើង និងម្ចាស់បំណុលទេ មិនមានវិសាលភាពដល់កូនបំណុល ឬបុគ្គលផ្សេងទៀតទេ។[51]

### ២.២.២.២.ការផ្អាក និងការបង្អង់អាជ្ញាយុកាល

ការផ្អាកអាជ្ញាយុកាល សំដៅលើការបញ្ឈប់ដំណើរការនៃអាជ្ញាយុកាល ក្នុងករណីដែលមានហេតុនៃការផ្អាក។ ការផ្អាកនូវអាជ្ញាយុកាល គឺមិនត្រឹមតែផ្អាកដំណើរការនៃអាជ្ញាយុកាលនោះមួយរយៈពេលនោះទេ គឺចាត់ទុកថាអំឡុងពេលនៃអាជ្ញាយុកាលដែលមានដំណើរកន្លងមកនេះ ពុំមានអត្ថន័យតាមផ្លូវច្បាប់។ ដូចនេះពេលដែលហេតុនៃការផ្អាកនោះរលត់ទៅ នោះអំឡុងពេលនៃអាជ្ញាយុកាលដែលត្រូវចាប់ផ្តើមគិត ឬចាប់ផ្តើមរាប់ជាថ្មីម្តងទៀត។

មូលហេតុដែលនាំឲ្យមានការផ្អាកអាជ្ញាយុកាលមានដូចជា៖[52]

-ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬការអនុវត្តសិទ្ធិដែលមានលក្ខណៈ

---

[51] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០,មាត្រា ៤៨៦

[52] មាត្រា ៤៨៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ប្រហាក់ប្រហែល។ ការទាមទារតាមផ្លូវតុលាការមិនត្រូវបានបង្កើនអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ក្នុងករណីដែលបណ្តឹងត្រូវបានលើកចោល ឬត្រូវបានដកវិញ[53]។

-សកម្មភាពអនុវត្តដោយបង្ខំ ឬសកម្មភាពចាត់ចែងការរក្សាការពារ។ ការអនុវត្តដោយបង្ខំ ឬការរក្សាការពារ ត្រូវបានលុបចោលតាមពាក្យសុំរបស់គូភាគី ឬដោយការខ្វះលក្ខខណ្ឌតាមផ្លូវច្បាប់ ការផ្អាកអាជ្ញាយុកាលត្រូវបានចាត់ទុកថាមិនអាចកើតមានបានឡើយ។[54]

-ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេង។ នៅពេលដែលកូនបំណុលបានធ្វើសកម្មភាពនានាដូចមានចែងខាងលើដែលធ្វើឲ្យជឿជាក់ថាកូនបំណុលបានទទួលស្គាល់កាតព្វកិច្ច ហើយម្ចាស់បំណុលមិនបានអនុវត្តសិទ្ធិរបស់ខ្លួននាំឲ្យមានការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ។

ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល កើតឡើងចំពោះកូនបំណុលនោះហើយ ការផ្អាកនេះក៏កើតមានចំពោះអ្នកដទៃដែរ។ ប៉ុន្តែក្នុងករណីដែលការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលកើតឡើងចំពោះភាគីដទៃទៀត ក្រៅពីកូនបំណុល នោះការផ្អាកមានអានុភាពតែរវាងម្ចាស់បំណុល និងភាគីនោះតែប៉ុណ្ណោះ លើកលែងតែមានករណីដែលសកម្មភាពអនុវត្តដោយបង្ខំ ឬសកម្មភាពចាត់ចែងរក្សាការពារត្រូវបានធ្វើឡើងចំពោះភាគីផ្សេងទៀត ក្រៅពីកូនបំណុលក៏ដោយ ក៏សកម្មភាពនោះបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ប្រសិនបើសកម្មភាពនោះត្រូវបានជូនដំណឹងទៅកូនបំណុល។

ការបង្អង់អាជ្ញាយុកាលសំដៅលើការបញ្ឈប់នៃដំណើរការនៃអាជ្ញាយុកាល តែក្នុងអំឡុងពេលដែលត្រូវបង្អង់តែប៉ុណ្ណោះ។ ការបង្អង់អាជ្ញាយុកាល គ្រាន់តែជាការធ្វើកុំឲ្យអាជ្ញាយុកាលបានសម្រេចតែប៉ុណ្ណោះ ដោយវាបញ្ឈប់នូវដំណើរការនៃអាជ្ញាយុកាល នៅដំណាក់កាលចុងក្រោយ ដែលជាពេលបញ្ចប់នៃអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

មូលហេតុនៃការបង្អង់អាជ្ញាយុកាលមានដូចជា៖

-ការដាស់តឿន សំដៅលើហេតុមួយនៃការបង្អង់ការសម្រេចអាជ្ញាយុកាល ប៉ុន្តែអាចដាស់តឿនបានតែម្តងប៉ុណ្ណោះ។ ទោះបីមានការលើកចោលពាក្យបណ្តឹង ឬការដកបណ្តឹងតាមផ្លូវតុលាការក៏ដោយក៏ត្រូវបានចាត់ទុកថា អ្នកប្តឹងបានដាស់តឿនជាបន្ត ចាប់ពីពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀត។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានបង្អង់ក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីការលើកចោលបណ្តឹង ឬការដកពាក្យបណ្តឹង។ ក្នុងករណីមួយទៀត ដែលត្រូវបានចាត់ទុកថាជាការដាស់តឿនបន្តក្នុងអំឡុងពេលបណ្តឹងកំពុងចាត់ការ ប្រសិនបើម្ចាស់បំណុល

[53] មាត្រា ៤៩១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[54] មាត្រា ៤៩២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អះអាងសិទ្ធិរបស់ខ្លួនជាចុងចម្លើយ។[55]

-អនីតិជន ឬជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ។ ក្នុងនោះច្បាប់បានការពារផលប្រយោជន៍អនីតិជន និងជនក្រោមអាណាព្យាបាលទូទៅ ពីការណ៍ដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានសម្រេច ដោយសារតែជនទាំងនោះពុំបានចាត់វិធានការឲ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន ព្រោះខ្លួនជាអនីតិជន ឬជនក្រោមអាណាព្យាបាលទូទៅ គ្មានអ្នកតំណាងដែលច្បាប់បានកំណត់នៅក្នុងអំឡុងពេល ៦ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាល។ ហេតុនេះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងមិនត្រូវបានសម្រេចទេ ក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីពេលជននោះក្លាយជាសមត្ថជន ឬមានអ្នកតំណាងដែលច្បាប់កំណត់ ប្រសិនបើអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ គ្មានអ្នកតំណាងក្នុងអំឡុងពេល ៦ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។[56]

-ការបង្អង់អាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលរវាងប្តីប្រពន្ធ។ ជាការពិបាកមួយក្នុងការចាត់វិធានការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ហេតុនេះនាំឲ្យច្បាប់បានទុកពេលវេលាមួយសមស្រប ក្រោយពីការរំលាយអាពាហ៍ពិពាហ៍ដើម្បីបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។[57]

-ករណីមហន្តរាយធម្មជាតិ សំដៅលើករណីដែលអ្នកមានសិទ្ធមិនអាចចាត់វិធានការឲ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិ ដូចជា ខ្យល់ព្យុះ រញ្ជួយផែនដី ទឹកជំនន់ ប្រធានសក្តិជាដើម នៅពេលណាមួយក្នុងរយៈពេល ៦ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីប្រធានសក្តិនោះបានកន្លងផុតឡើយ។[58]

### ២.២.២.៣.អានុភាព

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអានុភាពប្រតិសកម្មចាប់ពីតាំងពីថ្ងៃចាប់ផ្តើមគិតអាជ្ញាយុកាល។[59] នៅពេលដែលអាចអនុវត្តសិទ្ធិលើបំណុលបាន បានន័យថាបើអាជ្ញាយុកាលនៃការរលត់កាតព្វកិច្ចលើបំណុលបានកន្លងផុត ដូច្នេះ សិទ្ធិលើបំណុលត្រូវបានរលត់ដោយប្រតិសកម្មចាប់ពីថ្ងៃដែលចាប់ផ្តើមគិតអាជ្ញាយុកាល និងនាំឲ្យកូនបំណុលរួចផុតពីកាតព្វកិច្ចក្នុងការបង់ប្រាក់ ឬសំណងនៃការខូចខាតផ្សេងៗទៀត នៅក្នុងអំឡុងពេលចាប់ផ្តើមគិតអាជ្ញាយុកាលតាមរយៈបណ្តឹង

[55] មាត្រា ៤៩៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[56] មាត្រា ៤៩៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[57] មាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[58] មាត្រា ៤៩៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[59] មាត្រា ៤៨៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទាមទារសុំរំលត់អាជ្ញាយុកាលធ្វើឡើងដោយឆន្ទៈរបស់កូនបំណុល។ ឧទាហរណ៍៖ លោក "ក" បានខ្ចីលុយលោក "ខ" ចំនួនប្រាំរយដុល្លារ ហើយបានកំណត់ការសងនៅថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ២០១០។ លុះដល់ថ្ងៃកំណត់ លោក "ក" មិនបានបង់ប្រាក់នោះទេ ហើយលោក "ខ" ក៏ភ្លេចពីថ្ងៃកំណត់នៃការសង។ រហូតដល់ថ្ងៃ ០១ ខែ មករា ឆ្នាំ ២០១៨ ទើបលោក "ខ" ប្តឹងទាមទារអោយលោក "ក" សងលុយ។ ក្នុងករណីនេះដោយអាជ្ញាយុកាលបានកន្លងផុតប្រាំឆ្នាំហើយ សិទ្ធិលើបំណុលអាចរលត់ដោយការលើកឡើងនូវអាជ្ញាយុកាលតាមរយៈបណ្តឹងទាមទារសុំរំលត់អាជ្ញាយុកាល ធ្វើឡើងដោយឆន្ទៈរបស់កូនបំណុល។ នៅពេលដែលសិទ្ធិលើបំណុលរលត់នោះ នាំឲ្យលោក "ក" មិនចាំបាច់ធ្វើការសងប្រាក់ និងសំណងនៃការខូចខាតរបស់លោក "ខ" ចំពោះអំឡុងពេលពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១០ ដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៨ ព្រមទាំងប្រាក់ដើមទេ ព្រោះដោយសារអានុភាពប្រតិសកម្មនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល។

### ២.២.៣.ការអនុវត្តសិទ្ធិលុបចោល

ជាទូទៅ កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងគូភាគី មានកម្មវត្ថុស្របច្បាប់ ហើយធ្វើឡើងដោយសមត្ថជន នោះកិច្ចសន្យានឹងមានអានុភាពក្នុងការអនុវត្ត។ ប៉ុន្តែក្នុងករណីមួយចំនួនកិច្ចសន្យាត្រូវបានគេលុបចោល ដោយសារកិច្ចសន្យានោះបង្កើតឡើងដោយជនកម្រិតសមត្ថភាព និងកិច្ចសន្យាដែលបានបង្កើតឡើងរវាងគូភាគីមានភាពមិនប្រក្រតី និងមានភាពមិនត្រឹមត្រូវណាមួយតាមរយៈការសម្តែងឆន្ទៈ និងនៅក្នុងករណីដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ។

#### ២.២.៣.១. ការលុបចោលនូវសកម្មភាពដែលធ្វើឡើងដោយជនកម្រិតសមត្ថភាព

សកម្មភាពដែលធ្វើឡើងដោយជនកម្រិតសមត្ថភាពអាចលុបចោលបាន។ ក្នុងនោះផងដែរ ជនទាំងនោះរួមមាន អនីតិជន ជនក្រោមអាណាព្យាបាលទូទៅ និងជនស្ថិតក្រោមហិតូបត្ថម្ភ។

-អនីតិជន សំដៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំ។[60] ហើយសកម្មភាពដែលអនីតិជនបានធ្វើដោយមិនមានការទទួលយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ សកម្មភាពទាំងនោះអាចលុបចោលបាន។[61] ការលុបចោលសកម្មភាពនេះ ព្រោះដើម្បីការពារផលប្រយោជន៍របស់អនីតិជននោះ បានន័យថា អនីតិជន គឺជាបុគ្គលដែលស្ថិតក្នុងវ័យដែលមិនចេះគិតគូរអោយបានវែងឆ្ងាយ និងអោយបានល្អិតល្អន់ ដែលងាយនិងភាន់ច្រឡំ ឬងាយនឹងជឿគេ។ ប៉ុន្តែសកម្មភាពមួយចំនួនដែលបានធ្វើដោយអនីតិជន ក៏អាចមានអានុភាពបានដែរ រួមមាន សកម្មភាពទទួលបានសិទ្ធិ សកម្មភាពដែលទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃ ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបានអនុញ្ញាតឲ្យចាត់ចែង

[60] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[61] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

និងសកម្មភាពទាក់ទងនឹងអាជីវកម្មដែលអនីតិជន ត្រូវបានអនុញ្ញាតអោយធ្វើដោយអ្នកមានសិទ្ធិអំណាចមេបា ឬអាណាព្យាបាល។[62]

-ជនក្រោមអាណាព្យាបាលទូទៅ សំដៅលើជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី[63]។ ចំពោះសកម្មភាពរបស់ជនក្រោមអាណាព្យាបាលទូទៅបានធ្វើ អាចធ្វើការលុបចោលបាន។ ទោះបីជាសកម្មភាពដែលជននោះបានធ្វើដោយមានការយល់ព្រមដោយអាណាព្យាបាលទូទៅក៏ដោយ ក៏សកម្មភាពនោះអាចធ្វើការលុបចោលបានដែរ ព្រោះជននៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលស្ថិតក្នុងស្ថានភាពជានិរន្តន៍ដែលខ្វះសមត្ថភាពក្នុងការសំដែងឆន្ទៈ ឬចុះកិច្ចព្រមព្រៀងផ្សេងៗ។ យ៉ាងណាមិញ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ មិនអាចធ្វើការលុបចោលបានទេ។[64] ឧទាហរណ៍៖ ការទិញម្ហូបអាហារ សំលៀកបំពាក់ ការបង់ទឹកភ្លើងជាដើម។

-ជននៅក្រោមហិត្វបត្ថម្ភ សំដៅលើជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។[65] លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ សកម្មភាពដែលបានធ្វើឡើងដោយជនក្រោមហិត្វបត្ថម្ភដោយគ្មានការយល់ព្រមពីហិត្វបត្ថម្ភកៈ អាចធ្វើការលុបចោលបានរួមមាន ក.ការទទួល ឬការប្រើប្រាស់ទុន ខ.ការខ្ចីទ្រព្យ ឬការធានា គ.ការធ្វើសកម្មភាពដែលមានគោលបំណងទទួលទាន ឬធ្វើឲ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងៗទៀត ឃ.ការធ្វើសកម្មភាពបណ្តឹង ង.ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តកម្ម ច.ការប្រកែកមិនទទួលប្រទានកម្ម ឬអច្ច័យទាន ឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ជ.ការសាងសង់សំណង់ថ្មី ការសាងសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំ ឈ.ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ ឆ្នាំ ចំពោះដីធ្លី ២ឆ្នាំ ចំពោះអាគារ លើសពី ៦ខែ ចំពោះចលនវត្ថុ ញ.សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិត្វបត្ថម្ភកៈ តាមពាក្យសុំរបស់ជនក្នុងការប្រកាសការចាប់ផ្តើមហិត្វបត្ថម្ភ ឬហិត្វបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិត្វបត្ថម្ភកៈ។[66]

**២.២.៣.២.ការលុបចោលដោយមានវិការៈ**

ជាការពិតណាស់ កិច្ចសន្យាត្រូវបានបង្កើតឡើងដោយបានបំពេញលក្ខខណ្ឌដែលបានកំណត់

[62] មាត្រា ១៩២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[63] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[64] មាត្រា ២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[65] មាត្រា ២៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[66] មាត្រា ៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ប៉ុន្តែគេអាចធ្វើការលុបចោល ដោយសារមានវិការៈតាមរូបភាពមួយចំនួនរួមមាន ការភាន់ច្រឡំ ការឆបោក ពត៌មានមិនពិត ការគំរាមកំហែង អំពើកេងចំណេញហួសហេតុ ការរំលោភបំពានលើស្ថានភាព។ ប៉ុន្តែទោះបីជាកិច្ចសន្យាបានប្រព្រឹត្តរួចហើយ និងមានអានុភាពក្នុងការអនុវត្តក៏ដោយក៏កិច្ចសន្យាទាំងនោះត្រូវបានលុបចោលដែរ ដោយការបង្ហាញមានវិការៈ។

-ការភាន់ច្រឡំ សំដៅលើសកម្មភាពនៃការសម្តែងឆន្ទៈ ដែលមានលក្ខណៈខុសគ្នាទៅនឹងឆន្ទៈពិតរបស់ខ្លួន ហើយគេក៏មិនបានដឹងអំពីភាពខុសគ្នានេះ នៅពេលបង្ហាញឆន្ទៈឡើយ។ ក្នុងករណីនេះ ប្រសិនបើគូភាគីបានដឹងពីការភាន់ច្រឡំ នោះមិននាំឲ្យការចុះកិច្ចសន្យានោះទេ។ ក្នុងករណីដែលភាគីដែលមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចធ្វើការលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ រីឯក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ។[67]

-ការឆបោក សំដៅលើឧបាយកលដោយភាគីម្ខាង ឬតតិយជនយកមកប្រើ ដើម្បីអោយភាគីម្ខាងទៀតមានការភាន់ច្រឡំ រួចភាគីដែលមានការភាន់ច្រឡំនោះក៏សម្តែងឆន្ទៈចុះកិច្ចសន្យា។ បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀតអាចលុបចោលបាននូវកិច្ចសន្យាដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលការបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈលុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈបានដឹង ឬអាចដឹងអំពីការឆបោកនោះ។ ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជនបានឡើយ។[68]

-ពត៌មានមិនពិត សំដៅទៅលើហេតុដែលត្រូវបានលើកឡើងដោយភាគី សម្រាប់ជាមូលដ្ឋាននៅក្នុងការបង្កើតកិច្ចសន្យា គឺខុសពីការគិត។ ទន្ទឹមនឹងនេះ ប្រសិនបើអ្នកបង្ហាញឆន្ទៈបានដឹងថាហេតុនោះមិនមែនជាការពិត នោះខ្លួននឹងមិនបង្ហាញនោះទេ ហើយភាគីនោះអាចលុបចោលកិច្ចសន្យាបានដោយសារការបង្ហាញឆន្ទៈនោះមានវិការៈ។ ក្នុងករណីដែលពត៌មានមិនពិត គឺតម្រូវឲ្យភាគីម្ខាង

[67] មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[68] មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទៀតមិនបានដឹងថាហេតុដែលគាត់បានលើកឡើងនោះមិនមែនជាការពិត។ ប្រសិនបើគាត់បានដឹងថាហេតុនោះខុសពីការគិត វាត្រូវបានគេចាត់ទុកថាជាការបោក។ ម្យ៉ាងទៀត ប្រសិនបើភាគីដែលបានបង្ហាញការណ៍មិនពិតនោះមានកំហុសក្នុងការបង្ហាញពតិមានមិនពិតនេះ ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត។[69]

-ការគំរាមកំហែង សំដៅលើការបង្ហាញឆន្ទៈដែលផ្ទុយទៅនឹងគោលបំណងរបស់ខ្លួន ដោយសារមានការភ័យខ្លាចពីភាគីម្ខាងទៀត ឬតតិយជន។ ការបង្ហាញឆន្ទៈនោះមានវិការៈ ហើយបញ្ញត្តិច្បាប់អនុញ្ញាតឲ្យអ្នកបង្ហាញឆន្ទៈ អាចលុបចោលកិច្ចសន្យាបាន។[70] ផ្ទុយទៅវិញ វាមិនមានបញ្ញត្តិច្បាប់ណាការពារតតិយជនទេ ទោះបីជាតតិយជននោះបានបង្កើតទំនាក់ទំនងក្នុងកិច្ចសន្យាដោយផ្អែកលើកិច្ចសន្យាដែលអាចត្រូវបានគេលុបចោលនោះ។ ដូច្នេះ អ្នកបង្ហាញឆន្ទៈអាចអះអាងពីអានុភាពនៃការលុបចោលចំពោះតតិយជន ទោះបីជាតតិយជននោះជាសុចរិតក៏ដោយ។

-អំពើកេងចំណេញ សំដៅលើករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ខ្លៅ ឬការខ្វះបទពិសោធន៍ ហើយបានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ហើយភាគីម្ខាងទៀតនោះអាចលុបចោលកិច្ចសន្យាដោយហេតុការបង្ហាញឆន្ទៈមានវិការៈ។[71] ច្បាប់ក៏បានការពារភាគីម្ខាងនៃកិច្ចសន្យាដែលជាអ្នកប្រើប្រាស់ពីអ្នកផលិតនូវផលិតផលជាច្រើន ដែលប៉ុនប៉ងកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ដោយឆ្លៀតឱកាសកេងយកផលប្រយោជន៍ពីអតិថិជនដែលមានភាពល្ងង់ខ្លៅ ឬខ្វះបទពិសោធន៍។ យើងឃើញថា អ្នកបង្ហាញឆន្ទៈ គឺជាសាធារណជនដែលប្រើប្រាស់ផលិតផលជាទូទៅ និងភាគីម្ខាងទៀតគឺជាផលិតករដែលផលិតផលិតផលនៅក្នុងទ្រង់ទ្រាយធំ។ ទោះបីជាភាគីម្ខាងបានកេងចំណេញហួសហេតុពីកិច្ចសន្យា គេមិនអាចចាត់ទុកថាគ្រប់កិច្ចសន្យាបែបនេះទាំងអស់ទេ ត្រូវចាត់ទុកថាជាអំពើកេងចំណេញហួសហេតុទេ វាតម្រូវឲ្យភាគីម្ខាងទៀតបង្កើតកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ខ្លៅ ឬការខ្វះបទពិសោធន៍។

-ការរំលោភបំពានលើស្ថានភាព សំដៅលើករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបប្រទះនូវការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬសង្គម ឬបានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ។ ក្នុងករណីនេះ ភាគីដែលបានរំលោភបំពានលើស្ថានភាពមិនត្រូវបានគេចាត់ទុកថាបានគំរាមកំហែងឡើយ ព្រោះគាត់មិនបានប្រើវិធានការបង្ខំ។ ប៉ុន្តែ ដើម្បីកំណត់ថាជាការរំលោភបំពានលើស្ថានភាព វាមានភាព

[69] មាត្រា ៣៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[70] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[71] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចាំបាច់ដែលភាគីម្ខាងទៀតឆ្លៀតឱកាសនៃស្ថានភាពទន់ខ្សោយរបស់អ្នកបង្ហាញឆន្ទៈ។ ដូចនេះភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[72]

**២.២.៣.៣.អ្នកដែលមានសិទ្ធិលុបចោល**

ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថាមានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានរៀបរាប់ខាងលើ អ្នកដែលបង្ហាញឆន្ទៈដោយវិការៈ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។ ចំពោះការលុបចោលដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈអនីតិភាព ឬការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាង ដែលច្បាប់បានកំណត់ ឬហិតូបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន។ សន្តតិជន ឬអច្ច័យលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។ ការលុបចោលដែលធ្វើឡើងដោយជនដែលគ្មានសមត្ថភាព ឬត្រូវបានគេកម្រិតសមត្ថភាពមិនត្រូវបានគេចាត់ទុកថាជា សកម្មភាពដែលអាចលុបចោលបាននោះទេ ព្រោះជាទូទៅការបដិសេធនូវអានុភាពនៃសកម្មភាព ត្រូវបានចាត់ទុកថាជាការការពារនូវជននោះ។[73]

អ្នកមានសិទ្ធិលុបចោល អាចធ្វើសច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន។ ប៉ុន្តែក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងអំពីមូលហេតុនៃការលុបចោល។[74] រីឯសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពវិញ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលអាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវបានរលត់។ សច្ចានុមតិ សំដៅលើសកម្មភាពដែលបុគ្គលដែល មានសិទ្ធិលុបចោលបង្ហាញជាស្ថាពរថា ខ្លួនមិនអនុវត្តសិទ្ធិលុបចោលដោយផ្អែកលើបុរេលក្ខខណ្ឌដែលបានដឹងថា សកម្មភាពរបស់ខ្លួនអាចលុបចោលបាន។ ការលុបចោលសកម្មភាពដោយមូលហេតុមានវិការៈអាចផ្តល់សច្ចានុមតិបាននៅពេលដែលជនមានសិទ្ធិលុបចោលនោះ បានដឹងពីមូលហេតុនៃការលុបចោល បានន័យថាទោះបីជនដែលមានសិទ្ធិលុបចោលនោះ បានដឹងថាខ្លួនមានសិទ្ធិលុបចោលនូវសកម្មភាពនោះ ប៉ុន្តែនៅតែយល់ព្រមអនុវត្ត។ យ៉ាងណាមិញ ជនដែលបានកម្រិតសមត្ថភាពអាចអនុវត្តសិទ្ធិលុបចោល

[72] មាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[73] មាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[74] មាត្រា ៣៦១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

នូវសកម្មភាព មុនពេលដែលជននោះមានសមត្ថភាពធ្វើការឡើងវិញ ឬមុនការឈានចូលដល់នីតិភាព ប៉ុន្តែមិនអាចផ្តល់សច្ចានុមតិបានទេ។ ក្នុងករណីដែលមានការអនុវត្តកាតព្វកិច្ចទាំងមូល ឬមួយផ្នែក នៃកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិ ហើយមិនអាចធ្វើការលុបចោលនូវសកម្មភាពនោះវិញបានទេ។

**២.២.៣.៤.អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល**

ប្រសិនបើអ្នកដែលមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និងសិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះត្រូវរលត់។ ការផ្អាកអាជ្ញាយុកាលមិនត្រូវបានយកមកអនុវត្តឡើយ។ យ៉ាងណាមិញ សិទ្ធិលុបចោលត្រូវរលត់ផងដែរ ប្រសិនបើហួសអំឡុងពេល ១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពនោះ។ ក្រោយពេលអាជ្ញាយុកាលរំលត់ត្រូវបានបញ្ចប់ នោះជនដែលមានសិទ្ធិលុបចោល មិនអាចលុបចោលសកម្មភាពនោះទៀតទេ នាំឲ្យសកម្មភាពនោះត្រូវបានចាត់ទុកថាមានសុពលភាពជាស្ថាពរ។[75]

នៅក្រោយពេលដែលអាចផ្តល់សច្ចានុមតិ សកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិរួចហើយក្នុងករណីដូចខាងក្រោម៖[76]

-ការអនុវត្តកាតព្វកិច្ចទាំងមូល ឬមួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ។

-ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬការទាមទារឲ្យភាគីម្ខាងទៀតអនុវត្ត។

-អនុប្បទាន ឬការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬមួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន។

[75] មាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[76] មាត្រា ៣៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "មូលហេតុនៃការរំលត់កាតព្វកិច្ច" នេះ រួចមកខ្ញុំបាទអាចសន្និដ្ឋានបានថា សារៈសំខាន់ដែលកើតចេញពីការយល់ដឹងអំពីការរំលត់កាតព្វកិច្ចសម្រាប់សង្គម គឺជាកត្តាសំខាន់ក្នុងទំនាក់ទំនងប្រចាំថ្ងៃដោយបានការពារនូវប្រយោជន៍សាធារណៈ ក៏ដូចជាចំពោះគូភាគីនៃកិច្ចសន្យា។ ក្រៅអំពីផលប្រយោជន៍នេះផងដែរ ច្បាប់បានសម្របសម្រួលនូវទំនាក់ទំនងក្នុងសង្គម ដោយបង្កើននូវការជួយយកអាសាគ្នា ភាពយោគយល់ និងលើកលែងឲ្យគ្នាទៅវិញទៅមក។ ម្យ៉ាងវិញទៀត ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នក៏មានការបញ្ញត្តិច្បាប់អំពីកាតព្វកិច្ចសម្រាប់អនុវត្តក្នុងទំនាក់ទំនងគតិយុត្តិរវាងម្ចាស់បំណុល និងកូនបំណុល ដោយបង្ហាញយ៉ាងច្បាស់នូវសិទ្ធិ និងករណីកិច្ចចំពោះគូភាគី ហើយក៏រឹតបន្តឹងនូវការអនុវត្តដោយសុចរិត និងជៀសវាងការគេចវេះមិនព្រមអនុវត្តនូវកាតព្វកិច្ចនោះ។ បន្ថែមពីលើនេះ ការរលត់កាតព្វកិច្ចមានពីរប្រភេទដូចជា ការរលត់កាតព្វកិច្ចតាមគូភាគី និងការរលត់កាតព្វកិច្ចតាមច្បាប់កំណត់។

ចំពោះការរលត់កាតព្វកិច្ចតាមគូភាគី គឺជាការបង្ហាញនូវឆន្ទៈរបស់គូភាគីក្នុងការរំលត់នូវកាតព្វកិច្ចដោយភាពព្រមព្រៀង ក្នុងនោះផងដែរយើងឃើញថាវាជាដំណោះស្រាយមួយដែលមានភាពយោគយល់ សន្តោសប្រណីចំពោះគ្នាដើម្បីរក្សានូវទំនាក់ទំនងរបស់គូភាគី។ ដោយឡែកគូភាគីអាចធ្វើការរំលត់នូវកាតព្វកិច្ចដោយ ការសង ការទូទាត់ ការលើកលែងរបស់ម្ចាស់បំណុល នវកម្ម ឬព្យាកុលភាព និងការទទួលបន្ទុកហានិភ័យ។

ចំណែកឯការរលត់កាតព្វកិច្ចតាមច្បាប់កំណត់ គឺជាការរំលត់នូវកាតព្វកិច្ចដោយភាគីនៃកិច្ចសន្យា ឬភាគីណាម្ខាង បង្ហាញឆន្ទៈក្នុងការរំលត់នូវកាតព្វកិច្ចនោះ។ តាមរយៈកំហុសរបស់ភាគីម្ខាងនៃកិច្ចសន្យាមិនអនុវត្ត ឬអនុវត្តដោយបំពានទៅលើកិច្ចសន្យាធ្ងន់ធ្ងរបណ្តាលឲ្យមិនអាចសម្រេចតាមគោលបំណងនៃកិច្ចសន្យា។ មួយផ្នែកទៀត ទាក់ទងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលក៏បានកំណត់អំពីអាជ្ញាយុកាលកំណត់ផងដែរ សម្រាប់ការពារដល់ភាគីដែលអនុវត្តនូវកាតព្វកិច្ចនោះ ហើយវាបានបង្ហាញអោយភាគីដែលជាម្ចាស់បំណុល ត្រូវយកចិត្តទុកដាក់ទៅលើសិទ្ធិដែលខ្លួនមានជៀសវាងភាពធ្វេសប្រហែសបណ្តាលឲ្យបាត់បង់សិទ្ធិនោះ។ កាតព្វកិច្ចនឹងត្រូវរលត់ក្នុងករណីដែលកិច្ចសន្យានោះបង្កើតឡើងដោយជនកម្រិតសមត្ថភាព ឬក្នុងករណីនៃការបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យាមានវិការៈ ភាគីណាម្ខាងដែលបានបង្ហាញថាភាគីម្ខាងទៀតបានបង្ហាញឆន្ទៈមានវិការៈនាំឲ្យភាគីនោះអាចរំលត់កាតព្វកិច្ចបាន។ កាតព្វកិច្ចដែលកំណត់ដោយច្បាប់រួមមាន ការរំលាយកិច្ចសន្យា ការផុតអាជ្ញាយុកាល និងការអនុវត្តសិទ្ធិលុបចោល។ ជារួម ច្បាប់ការពារដល់ផលប្រយោជន៍គូភាគីដែលពាក់ពន្ធទៅនឹងកិច្ចសន្យា ហើយរក្សានូវភាពយុត្តិធម៌ចំពោះកូនបំណុល និងម្ចាស់បំណុល។

ក្នុងនោះផងដែរ គូភាគីនៃកិច្ចសន្យាអាចធ្វើការរំលត់កាតព្វកិច្ចដោយមានការព្រមព្រៀងគ្នា ដោយអនុវត្តតាមវិធានមួយចំនួនខាងលើ ។

ស្របជាមួយគ្នានេះ ការអនុវត្តនូវការរំលត់កាតព្វកិច្ច ច្បាប់បានទុកនូវសិទ្ធិឲ្យភាគីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសវិធានណាមួយដែលគ្មានការបង្ខំ និងស្របទៅតាមឆន្ទៈរបស់ភាគី។ តាមរយៈនេះផងដែរ អ្នកអនុវត្តច្បាប់មានការយកចិត្តទុកដាក់ក្នុងការសម្របសម្រួល និងទុកឱកាសឲ្យភាគីបានសម្រេចចិត្តដោយខ្លួនឯង មុនពេលបញ្ចប់នូវកាតព្វកិច្ច និងមិនឲ្យភាគីណាមួយបាត់បង់ផលប្រយោជន៍របស់ខ្លួន។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទរួចមក លទ្ធផលបានបង្ហាញឲ្យឃើញអំពីចំណុចជាច្រើនជាមូលហេតុនៃវិវាទ ទោះជាហេតុផលទាំងនោះផ្តើមចេញពីឆន្ទៈ ឬក្រៅឆន្ទៈរបស់ភាគី។ ក្នុងការរួមចំណែកជម្រុញ និងលុបបំបាត់ភាពអសកម្មនានា ក្នុងជីវភាពគតិយុត្តទាក់ទងទៅនឹងបញ្ហាខាងលើ ខ្ញុំបាទសូមអនុញ្ញាតធ្វើការលើកឡើងនូវអនុសាសន៍ដូចខាងក្រោម៖

-គូភាគីចាំបាច់ត្រូវពិនិត្យឲ្យបានច្បាស់លាស់នូវកម្មវត្ថុនៃកិច្ចសន្យា ព្រមទាំងបង្ហាញអំពីមូលហេតុជាក់លាក់ក្នុងការចុះកិច្ចសន្យា។ បន្ថែមពីលើនេះ ភាគីត្រូវយល់ដឹងពីផលប៉ះពាល់ដែលបណ្តាលមកពីកម្មវត្ថុនៃកិច្ចសន្យា ដែលមិនត្រូវប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អក្នុងសង្គម។

-គូភាគីចាំបាច់ត្រូវសម្តែងនូវឆន្ទៈដោយពិតប្រាកដ និងសេរីភាព សុច្ចរិតទៀងត្រង់ ក្នុងអំឡុងពេលចុះកិច្ចសន្យាជាមួយគ្នាដើម្បីជៀសវាងមានភាពមិនប្រក្រតីទាក់ទងនឹង ការបង្ហាញឆន្ទៈនាំឲ្យមានវិការៈកើតឡើងដូចជា ការភាន់ច្រឡំ ការផ្តល់ពត៌មានមិនពិត ការឆបោក និង ការគេងចំណេញហួសហេតុ។

-គូភាគីត្រូវអនុវត្តកាតព្វកិច្ចដែលកើតចេញពីឆន្ទៈរបស់ខ្លួនដោយសុចរិត ស្មោះត្រង់រវាងគ្នាទៅវិញទៅមក។ ក្នុងករណីដែលភាគីណាមួយមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះ ភាគីត្រូវមានទំនួលខុសត្រូវចំពោះកំហុសរបស់ខ្លួន ហើយហ៊ានអះអាងដោយភាពពេញចិត្ត និងមិនស្ទើរស្ទាក់ក្នុងការជួសជុលនូវសំណងការខូចខាតនោះ។ ក្នុងនោះផងដែរ ទាក់ទងនឹងការរំលត់កាតព្វកិច្ចដោយការលើកលែង វាបង្ហាញអំពីភាពអនុគ្រោះនៃភាគីគតិយុត្តិ និងជាកិច្ចដ៏ល្អប្រសើរនៅក្នុងទំនាក់ទំនងសង្គម។ យ៉ាងណាមិញការអនុគ្រោះបែបនេះវានឹងមានកម្រិត ប្រសិនបើការយោគយល់ការសន្តោសប្រណី ការអនុគ្រោះនោះមិនបានកម្រិតវិញ វាអាចធ្វើឲ្យភាគីបាត់បង់ផលប្រយោជន៍ផងដែរ។

-ចំពោះភាគីដែលជាម្ចាស់បំណុល ទាក់ទងទៅនឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវធ្វេសប្រហែស ប្រងើយកន្តើយ មិនយកទុកដាក់ទៅនឹងការទាមទាររបស់ខ្លួនដែលមានទំនាក់ទំនងជាមួយកូនបំណុលឡើយ។ ប្រសិនបើម្ចាស់បំណុលមិនបានទាមទារសិទ្ធិលើបំណុលរបស់ខ្លួនក្នុងអំឡុងពេលណាមួយដែលច្បាប់បានកំណត់ នោះមានន័យថា លះបង់សិទ្ធិលើបំណុលជាប្រយោជន៍កូនបំណុល។

ខ្ញុំសង្ឃឹមថា ចំណងគតិយុត្តិដែលបានបង្កើតឡើងដោយភាគី និងប្រព្រឹត្តទៅដោយភាពរលូនដោយគោរពតាមច្បាប់កំណត់ និងដោយឆន្ទៈរបស់ភាគីពិតប្រាកដ ដើម្បីឈានទៅរកទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពទទួលបានផ្លែផ្កា និងជៀសវាងភាពមិនប្រក្រតីកើតឡើង។ ចំពោះពលរដ្ឋ

ទាំងអស់ត្រូវយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន និងសិក្សាយល់ដឹងពីបទដ្ឋានគតិយុត្តិនានាដែលមានក្នុងសង្គម។

-ការយល់ដឹងអំពីច្បាប់ក្នុងគតិយុត្តិរបស់សខ្លួននឹងនាំមកនូវ ភាពលុបបំបាត់វិវាទនា គ្មានវិវាទ មានការវិវឌ្ឍន៍ខាងសេដ្ឋកិច្ចគ្រួសារ និងសង្គម។

# ឯកសារយោង

# ឯកសារយោង


១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

២.ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នសរ/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

៣.សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៦

៤.សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣

៥.ក្រឹត្យច្បាប់ លេខ៣៨ ក្រ.ច, ២៨ តុលា ១៩៨៨

៦.ញឹកវុទ្ធី, នីតិកាតព្វកិច្ច, ភាគី១,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៧.រស់ស៊ីសុវណ្ណា, នីតិកាតព្វកិច្ច,ភាគ១, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៨.ជិនវណ្ណារ៉ា, នីតិកាតព្វកិច្ច, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៩.ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ ,សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, បោះពុម្ពលើកទី៥ ឆ្នាំ២០១១

# ឧបសម្ព័ន្ធទី១

# គន្ថីទី ៤
# កាតព្វកិច្ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃទស្សនៈផ្សេងៗ

**មាត្រា ៣០៨.—** និយមន័យនៃកាតព្វកិច្ច

១-កាតព្វកិច្ចគឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត ។

២-បុគ្គលដែលមានករណីយកិច្ចហៅថា កូនបំណុល រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា ម្ចាស់បំណុល ។

៣-ម្ចាស់បំណុលមានសិទ្ធិត្រូវផ្ទាទៅនឹងករណីយកិច្ចរបស់កូនបំណុល ។

**មាត្រា ៣០៩.—** ប្រភពនៃកាតព្វកិច្ច

១-កាតព្វកិច្ចកើតមានឡើងដោយកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្ដីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ ។

២-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និង ដោយសកម្មភាពឯកតោភាគី គឺជាកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ។

៣-កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្ដីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ។ បញ្ញត្តិពីជំពូកទី ៣ (ការអនុវត្តកិច្ចសន្យា) ដល់ជំពូកទី ៧ (ការរលត់កាតព្វកិច្ច) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកាតព្វកិច្ចដែលកំណត់

ឬ តាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

## ផ្នែកទី ២
## វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.-** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើជៀតនិកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

**មាត្រា ៣៤៦.-** ការភាន់ច្រឡំ

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា នោះបើជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៧.- ការឆបោក**

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៨.- ព័ត៌មានមិនពិត**

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន

វិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៩.-** ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

**មាត្រា ៣៥០.-** ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥១.-** អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ

**មាត្រា ៣៥៧.— អត្ថន័យនៃមោឃភាព**

ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមាន ដោយក្រមនេះ ឬ ច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។

**មាត្រា ៣៥៨.— សកម្មភាពដែលអាចលុបចោលបាន**

១-សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ ។

២-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ។

៣-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្ដល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ ។

**មាត្រា ៣៥៩.— អ្នកដែលមានសិទ្ធិលុបចោល**

១-ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ ចាប់ពីមាត្រា ៣៤៦ (ការភាន់ច្រឡំ) ដល់មាត្រា ៣៥១ (អំពើកេងយកចំណេញហួសហេតុ) នៃក្រមនេះ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន ។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

២-ចំពោះការលុបចោល ដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិរញ្ញបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន ។ សន្តតិជន ឬ អគ្គិយលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

ឬ ឱ្យរំលាយកិច្ចសន្យាទេ ។ ក្នុងករណីដែលម្ចាស់បំណុលរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូចខាតដែលជាការជំនួសកម្មវត្ថុនៃកិច្ចសន្យា ចំនួនទឹកប្រាក់នៃសំណងដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាដោយគិតជាមុន អំពីការខូចខាតដែលកើតឡើងដោយការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចនោះ មិនត្រូវចងធូភាគីទេ ។

៥-ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង ។

**មាត្រា ៤០៤.–** គោលការណ៍នៃការសងការខូចខាតជាប្រាក់

ចំពោះសំណងនៃការខូចខាតដែលកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាំងសងខាងបានកំណត់ផ្សេងពីនេះដោយការសន្យាពិសេស ។

**មាត្រា ៤០៥.–** ឧបាទេសកម្មនៃអ្នកសង

ប្រសិនបើម្ចាស់បំណុលបានទទួលនូវសំណងនៃការខូចខាតដោយការសងតម្លៃនៃវត្ថុ ឬ សិទ្ធិដែលជាអត្ថន័យនៃសិទ្ធិលើបំណុល កូនបំណុលត្រូវទទួលឋានៈដែលម្ចាស់បំណុលធ្លាប់មានចំពោះវត្ថុ ឬ សិទ្ធិនោះ ដោយស្វ័យប្រវត្តិ ។

**មាត្រា ៤០៦.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង ។

## ផ្នែកទី ៤
## ការរំលាយកិច្ចសន្យា

**មាត្រា ៤០៧.–** ការរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ៤០៨.-** ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ

១-ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត ។ ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោមនេះ :

ក- ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ ។

ខ-ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ ។

គ-ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ ។

ឃ-ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន ។

២-ភាគីដែលបំពានកិច្ចសន្យា មិនអាចរារាំងការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយយកមូលហេតុថាខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន បានឡើយ ។

**មាត្រា ៤០៩.-** វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា

១-ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន ។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន ។

២-ការបង្ហាញឆន្ទៈរំលាយនេះ មិនអាចដកវិញបានទេ ។

៣-ការបង្ហាញឆន្ទៈរំលាយនេះ អាចដាក់លក្ខខណ្ឌបង្អង់បាន ។

**មាត្រា ៤១០.-** ការរំលាយកិច្ចសន្យាដែលភាគីម្ខាងមានច្រើននាក់

១-ក្នុងករណីដែលភាគីម្ខាងមានច្រើននាក់ ការរំលាយកិច្ចសន្យាត្រូវធ្វើឡើងដោយ

# ជំពូកទី ៧
## ការរលត់កាតព្វកិច្ច

**មាត្រា ៤៣៣.–** មូលហេតុនៃការរលត់កាតព្វកិច្ច

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ :

ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ល្បាយកម្ម ឯកត្តភាព ដូចបានកំណត់ពីផ្នែកទី ១ (ការសង) ដល់ផ្នែកទី ៥ (ល្បាយកម្ម ឯកត្តភាព) នៃជំពូកទី ៧ នេះ ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល ដូចបានកំណត់ក្នុងជំពូកទី ៥ (ការទទួលបន្ទុកហានិភ័យ) នៃគន្ថីនេះ ។

គ-ការបំពេញល័ក្ខខ័ណ្ឌនៃការរំលាយដូចបានកំណត់ក្នុងផ្នែកទី ៣ (ល័ក្ខខ័ណ្ឌ កំណត់ពេល និង អំឡុងពេល) នៃជំពូកទី ១ ឬ ការរំលាយកិច្ចសន្យាដូចបានកំណត់ក្នុងផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) នៃជំពូកទី ៤ នៃគន្ថីនេះ ។

ឃ-ការផុតអាជ្ញាយុកាលនៃការរលត់ដូចបានកំណត់ក្នុងជំពូកទី ៨ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) នៃគន្ថីនេះ ។

ង-ការអនុវត្តសិទ្ធិលុបចោលតាមបញ្ញត្តិនៃផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ជំពូកទី ២ នៃគន្ថីនេះ។

## ផ្នែកទី ១
## ការសង

### កថាភាគទី ១
### គោលការណ៍ទូទៅស្ដីពីការសង

**មាត្រា ៤៣៤.–** អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន ។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រម

## ជំពូកទី ៧
## ការរលត់កាតព្វកិច្ច

**មាត្រា ៤៣៣.-** មូលហេតុនៃការរលត់កាតព្វកិច្ច

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ :

ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ល្បាយកុលភាព ដូចបានកំណត់ពីផ្នែកទី ១ (ការសង) ដល់ផ្នែកទី ៥ (ល្បាយកុលភាព) នៃជំពូកទី ៧ នេះ ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល ដូចបានកំណត់ក្នុងជំពូកទី ៥ (ការទទួលបន្ទុកហានិភ័យ) នៃគន្ថីនេះ ។

គ-ការបំពេញល័ក្ខខ័ណ្ឌនៃការរំលាយដូចបានកំណត់ក្នុងផ្នែកទី ៣ (ល័ក្ខខ័ណ្ឌ កំណត់ពេល និង អំឡុងពេល) នៃជំពូកទី ១ ឬ ការរំលាយកិច្ចសន្យាដូចបានកំណត់ក្នុងផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) នៃជំពូកទី ៤ នៃគន្ថីនេះ ។

ឃ-ការផុតអាជ្ញាយុកាលនៃការរលត់ដូចបានកំណត់ក្នុងជំពូកទី ៨ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) នៃគន្ថីនេះ ។

ង-ការអនុវត្តសិទ្ធិលុបចោលតាមបញ្ញត្តិនៃផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ជំពូកទី ២ នៃគន្ថីនេះ។

## ផ្នែកទី ១
## ការសង

### កថាភាគទី ១
### គោលការណ៍ទូទៅស្ដីពីការសង

**មាត្រា ៤៣៤.-** អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន ។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រម

ពេលកំណត់សងនៃសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគូភាគីធ្វើការសន្យាពិសេសថា អាចទូទាត់គ្នានូវកាតព្វកិច្ចរៀងៗខ្លួនបានដោយមិនគិតអំពីពេលកំណត់មុន ឬ ក្រោយ ។

**មាត្រា ៤៧២.-** ការកាត់បំណុលដោយការទូទាត់

ក្នុងករណីដែលភាគីម្ខាង ឬ ទាំងសងខាងមានកាតព្វកិច្ចច្រើនដែលអាចទូទាត់បាន អ្នកសុំទូទាត់អាចជ្រើសរើសកាតព្វកិច្ចណាមួយរបស់ខ្លួន និង កាតព្វកិច្ចណាមួយរបស់ភាគីម្ខាងទៀតដើម្បីរំលត់ដោយការទូទាត់នោះបាន ។ បញ្ញត្តិស្តីពីការកាត់បំណុលដោយការសង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទូទាត់ដែលគ្មានការជ្រើសរើស ដូចកំណត់ក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះ ។

## ផ្នែកទី ៣
## ការលើកលែង

**មាត្រា ៤៧៣.-** ការលើកលែងកាតព្វកិច្ច

ក្នុងករណីដែលម្ចាស់បំណុលបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុល កាតព្វកិច្ចនោះត្រូវរលត់ ។

**មាត្រា ៤៧៤.-** ការលើកលែងតែមួយផ្នែក

ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចតែមួយផ្នែកបាន ។

**មាត្រា ៤៧៥.-** ករណីដែលកម្រិតការលើកលែង

ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានរឹបអូសដោយតតិយជន ឬ សិទ្ធិចាត់ចែងរបស់ម្ចាស់បំណុលត្រូវបានកម្រិត ដោយមូលហេតុផ្សេង ម្ចាស់បំណុលមិនអាចលើកលែងកាតព្វកិច្ចបានឡើយ ។

## ផ្នែកទី ៤
## នវកម្ម

**មាត្រា ៤៧៦.-** និយមន័យនៃនវកម្ម

១-នវកម្មសំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និង កូនបំណុលដែលរំលត់កាតព្វកិច្ចដើម និង បង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ ។

២-នៅពេលកិច្ចសន្យានវកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បង្កើតអានុភាព នោះកាតព្វកិច្ចដើមត្រូវរលត់ ។

**មាត្រា ៤៧៧.-** ការមិនរលត់កាតព្វកិច្ចដើម

ប្រសិនបើកាតព្វកិច្ចថ្មីដែលត្រូវបានបង្កើតឡើងដោយនវកម្ម មិនបានបង្កើតអានុភាព ដោយសារមូលហេតុដែលកូនបំណុលនៃកាតព្វកិច្ចចាស់មិនអាចល្បាករបាន ឬ ប្រសិនបើ កាតព្វកិច្ចថ្មីនោះជាអលទ្ធភាពក្នុងការអនុវត្តតាំងពីដើម នោះកាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ ។

**មាត្រា ៤៧៨.-** ការផ្ទេរប្រាតិភោគ

១-សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក ឬ ប្រាតិភោគផ្សេងទៀតដែលបានបង្កើតឡើង ដើម្បីធានាកាតព្វកិច្ចដើម អាចផ្ទេរដើម្បីធានាកាតព្វកិច្ចថ្មី ក្នុងទំហំនៃកាតព្វកិច្ចដើម ដោយការព្រមព្រៀងគ្នារបស់គូភាគីនៃកិច្ចសន្យានវកម្មបាន ។ ប៉ុន្តែ ប្រាតិភោគដែលត្រូវបានដាក់ដោយតតិយជន មិនត្រូវផ្ទេរឡើយ លើកលែងតែមានការយល់ព្រមពីតតិយជននោះ ។

២-ក្នុងឧបសន្យាខ្ចីបរិភោគវត្ថុ ត្រូវសន្មតថា មានការព្រមព្រៀងដែលបានកំណត់នៅវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ។

## ផ្នែកទី ៥
## ល្បាកុលភាព

**មាត្រា ៤៧៩.-** ល្បាកុលភាពរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច

១-ក្នុងករណីដែលសិទ្ធិលើបំណុល និង កាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិលើបំណុល និង កាតព្វកិច្ចនោះត្រូវរលត់ដោយល្បាកុលភាព ។

២-សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិនោះមិនត្រូវរលត់ដោយល្បាកុលភាពឡើយ ។

## ជំពូកទី ៨
## អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

**មាត្រា ៤៨០.-** និយមន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុល ដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ ។

**មាត្រា ៤៨១.-** ពេលចាប់ផ្ដើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន ។

**មាត្រា ៤៨២.-** អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង ។

**មាត្រា ៤៨៣.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានអំឡុងពេលខ្លី

ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករ ឬ ពាណិជ្ជករលក់ទៅឱ្យអ្នក

- សកម្មភាពដទៃផ្សេងទៀត ជាសកម្មភាពដែលបុគ្គលម្នាក់ចាប់ផ្ដើមជួសជុល ឬ បំពេញជាដើម ។

ចំពោះករណីបង្ហូចខូច ប្រសិនបើភាគីបង្កើតកិច្ចសន្យាជាមួយអ្នកជួសជុលថា អ្នកជួសជុលត្រូវជួសជុលបង្ហូរនោះវាអាចជាការគ្រប់គ្រងសកម្មភាពគតិយុត្ត ។

ប្រសិនបើគាត់ជួសជុលបង្ហូចដោយខ្លួនគាត់ផ្ទាល់ វាមិនមែនជាសកម្មភាពគតិយុត្តនោះទេ ប៉ុន្តែវានៅតែជាការគ្រប់គ្រងដដែល ។

## ២.៩. ការគ្រប់គ្រងដោយធ្វើឡើងតាមវិធីដែលសមរម្យជាងគេ និង ដោយផ្អែកតាមឆន្ទៈ

លក្ខខណ្ឌនេះ គឺការពារផលស់សាមីខ្លួនក្នុងការបង់សោហ៊ុយច្រើនហួសហេតុ ដោយការគ្រប់គ្រងដោយឈឺឆ្អាលនោះ ឬ ក៏ជាការធ្វើឱ្យបានត្រឹមត្រូវ និង យុត្តិធម៌ក្នុងនាមជាអ្នកជួយគ្រប់គ្រងដោយភាពសុចរិត និង ឆ្លើយតបទៅនឹងអំពើមនុស្សធម៌ ប្រកបដោយសីលធម៌ និង សមធម៌រវាងបុគ្គលឯកជន ។

ជារួម អ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រងឱ្យសមស្របទៅតាមលក្ខណៈនៃការគ្រប់គ្រងនោះ ។

ចំពោះវិធីដែលសមរម្យជាងគេ ប្រសិនបើអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងអំពីឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងនោះត្រូវគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ យោងតាមមាត្រា ៧២៩ កថាខណ្ឌទី ៣ ។ ប៉ុន្តែ ប្រសិនបើអ្នកគ្រប់គ្រងមិនអាចដឹងអំពីឆន្ទៈពិតប្រាកដទេ អ្វីដែលសមស្របជាងគេនោះ គឺត្រូវកំណត់ដោយសត្យានុម័ត ។

**ឧទាហរណ៍ :** នៅពេល ក បានជួយសង្គ្រោះជនលង់ទឹក ខ ដែលបានធ្វើអត្តឃាតដោយមិនបានដឹងអំពីឆន្ទៈរបស់ ខ ការជួយសង្គ្រោះបែបនេះ គឺត្រូវបានចាត់ទុកថាជាវិធីដែលសមស្របជាងគេ ពីព្រោះការជួយសង្គ្រោះបុគ្គលណាម្នាក់ដែលលង់ទឹក គឺស្របទៅតាមវិធីដែលសមរម្យជាងគេតាមការជាក់ស្ដែង ។

ប៉ុន្តែ ក៏មានករណីលើកលែងផងដែរ មាត្រា ៧៣០ ។

**ឧទាហរណ៍ :** ក្នុងករណីបន្ទាន់ ទោះបីជាការគ្រប់គ្រងនោះ បណ្ដាលឱ្យមានការខូចខាតក៏ដោយ ក៏នៅតែជាការគ្រប់គ្រងដោយឈឺឆ្អាលដែរ ។

**ឧទាហរណ៍ :** ក សន្លប់ ហើយ ខ បានបញ្ជូន ក ទៅមន្ទីរពេទ្យដែលនៅជិត តែមន្ទីរពេទ្យនោះគ្មានគ្រូពេទ្យជំនាញ ដូច្នេះក៏ធ្វើឱ្យ ក មានជម្ងឺកាន់តែធ្ងន់ធ្ងរ ។

ចំពោះការគោរពតាមឆន្ទៈ ប្រសិនបើអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងពីឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រង ដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួននោះ មាត្រា ៧២៩ កថាខណ្ឌទី ៣ ។

ប៉ុន្តែក៏នៅតែមានករណីលើកលែងផងដែរ ។ ក្នុងករណីដែលសាមីខ្លួនចង់ធ្វើអត្តឃាត ដោយលោតទឹក ហើយដោយបានដឹងថាសាមីខ្លួនធ្វើអត្តឃាត អ្នកគ្រប់គ្រងបានជួយសង្គ្រោះដោយយកគាត់ទៅព្យាបាលនៅឯមន្ទីរពេទ្យ និង បានបង់សោហ៊ុយព្យាបាលអស់ចំនួន ១០០ ដុល្លារ ប៉ុន្តែសាមីខ្លួនបដិសេធមិនបង់សោហ៊ុយព្យាបាលទេ ដោយអះអាងថាការជួយសង្គ្រោះគាត់ គឺផ្ទុយនឹងឆន្ទៈរបស់គាត់ ។ បើយើងគោរពតាមឆន្ទៈរបស់សាមីខ្លួននោះ សាមីខ្លួននឹងស្លាប់ ប៉ុន្តែបើយើងមិនគោរពតាមឆន្ទៈរបស់សាមីខ្លួនទេ គឺយើងបកស្រាយបានថាសាមីខ្លួនត្រូវសងតម្លៃឱ្យអ្នកគ្រប់

- សកម្មភាពដទៃផ្សេងទៀត ជាសកម្មភាពដែលបុគ្គលម្នាក់ចាប់ផ្តើមជួសជុល ឬ បំពេញជាដើម ។

ចំពោះករណីបង្ខូចខូច ប្រសិនបើភាគីបង្កើតកិច្ចសន្យាជាមួយអ្នកជួសជុលថា អ្នកជួសជុលត្រូវជួសជុលបង្ខូច នោះវាអាចជាការគ្រប់គ្រងសកម្មភាពគតិយុត្ត ។

ប្រសិនបើគាត់ជួសជុលបង្ខូចដោយខ្លួនគាត់ផ្ទាល់ វាមិនមែនជាសកម្មភាពគតិយុត្តនោះទេ ប៉ុន្តែវានៅតែជាការគ្រប់គ្រងដដែល ។

## ២.៩. ការគ្រប់គ្រងដោយធ្វើឡើងតាមវិធីដែលសមរម្យជាងគេ និង ដោយផ្អែកតាមឆន្ទៈ

លក្ខខណ្ឌនេះ គឺការពារផលប្រយោជន៍សាមីខ្លួនក្នុងការបង់សោហ៊ុយច្រើនហួសហេតុ ដោយការគ្រប់គ្រងដោយឈឺឆ្អាលនោះ ឬ ក៏ជាការធ្វើឱ្យបានត្រឹមត្រូវ និង យុត្តិធម៌ក្នុងនាមជាអ្នកជួយគ្រប់គ្រងដោយភាពសុចរិត និង ឆ្លើយតបទៅនឹងអំពើមនុស្សធម៌ ប្រកបដោយសីលធម៌ និង សមធម៌រវាងបុគ្គលឯកជន ។

ជារួម អ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រងឱ្យសមស្របទៅតាមលក្ខណៈនៃការគ្រប់គ្រងនោះ ។

ចំពោះវិធីដែលសមរម្យជាងគេ ប្រសិនបើអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងអំពីឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងនោះត្រូវគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ យោងតាមមាត្រា ៧២៩ កថាខណ្ឌទី ៣ ។ ប៉ុន្តែ ប្រសិនបើអ្នកគ្រប់គ្រងមិនអាចដឹងអំពីឆន្ទៈពិតប្រាកដទេ អ្វីដែលសមស្របជាងគេនោះ គឺត្រូវកំណត់ដោយសត្យានុម័ត ។

**ឧទាហរណ៍ :** នៅពេល ក បានជួយសង្គ្រោះជនលង់ទឹក ខ ដែលបានធ្វើអត្តឃាតដោយមិនបានដឹងអំពីឆន្ទៈរបស់ ខ ការជួយសង្គ្រោះបែបនេះ គឺត្រូវបានចាត់ទុកថាជាវិធីដែលសមស្របជាងគេ ពីព្រោះការជួយសង្គ្រោះបុគ្គលណាម្នាក់ដែលលង់ទឹក គឺស្របទៅតាមវិធីដែលសមរម្យជាងគេតាមការជាក់ស្តែង ។

ប៉ុន្តែ ក៏មានករណីលើកលែងផងដែរ មាត្រា ៧៣០ ។

**ឧទាហរណ៍ :** ក្នុងករណីបន្ទាន់ ទោះបីជាការគ្រប់គ្រងនោះ បណ្តាលឱ្យមានការខូចខាតក៏ដោយ ក៏នៅតែជាការគ្រប់គ្រងដោយឈឺឆ្អាលដែរ ។

**ឧទាហរណ៍ :** គ សន្លប់ ហើយ ខ បានបញ្ជូន គ ទៅមន្ទីរពេទ្យដែលនៅជិត តែមន្ទីរពេទ្យនោះគ្មានគ្រូពេទ្យជំនាញ ដូច្នេះក៏ធ្វើឱ្យ គ មានជម្ងឺកាន់តែធ្ងន់ធ្ងរ ។

ចំពោះការគោរពតាមឆន្ទៈ ប្រសិនបើអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងពីឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រង ដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួននោះ មាត្រា ៧២៩ កថាខណ្ឌទី ៣ ។

ប៉ុន្តែក៏នៅតែមានករណីលើកលែងផងដែរ ។ ក្នុងករណីដែលសាមីខ្លួនចង់ធ្វើអត្តឃាត ដោយលោតទឹក ហើយដោយបានដឹងថាសាមីខ្លួនធ្វើអត្តឃាត អ្នកគ្រប់គ្រងបានជួយសង្គ្រោះដោយយកគាត់ទៅព្យាបាលនៅឯមន្ទីរពេទ្យ និង បានបង់សោហ៊ុយព្យាបាលអស់ចំនួន ១០០ ដុល្លារ ប៉ុន្តែសាមីខ្លួនបដិសេធមិនបង់សោហ៊ុយព្យាបាលទេ ដោយអះអាងថាការជួយសង្គ្រោះគាត់ គឺផ្ទុយនឹងឆន្ទៈរបស់គាត់ ។ បើយើងគោរពតាមឆន្ទៈរបស់សាមីខ្លួននោះ សាមីខ្លួននឹងស្លាប់ ប៉ុន្តែបើយើងមិនគោរពតាមឆន្ទៈរបស់សាមីខ្លួនទេ គឺយើងបកស្រាយបានថាសាមីខ្លួនត្រូវសងតម្លៃឱ្យអ្នកគ្រប់

ទី ២) ។

១) កិច្ចសន្យា ( មាត្រា ៣១១) : គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រម បង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ។

២) សកម្មភាពឯកតោភាគី ( មាត្រា ៣១២) : គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវ កាតព្វកិច្ចដោយ :

ក- បង្ហាញឆន្ទៈ នៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ

ខ- អនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ បញ្ញត្តិនៃច្បាប់ ។

តាមរយៈសកម្មភាពឯកតោភាគី វាមិនចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតទេ ។

ឧទាហរណ៍នៃចំណុច ក :

- ការលើកលែងកាតព្វកិច្ច ( មាត្រា ៤៧៣) : ក្នុងករណីដែលម្ចាស់បំណុល បង្ហាញឆន្ទៈ លើកលែងកាតព្វកិច្ចចំពោះកូនបំណុល ដោយមិនមានការយល់ព្រមពីកូនបំណុល ក៏កាតព្វកិច្ចនោះត្រូវរលត់ដែរ ។
- អច្ច័យទាន ( មាត្រា ១១៩៥) : ម្ចាស់បណ្តាំឱ្យទ្រព្យសម្បត្តិតាមរយៈមតកសាសន៍ ដោយ មិនចាំបាច់មានការយល់ព្រមពីអច្ច័យលាភី ។

ឧទាហរណ៍នៃចំណុច ខ :

- ការរំលាយ ដែលបានកំណត់ក្នុងកិច្ចសន្យា ( មាត្រា ៤១៤ កថាខណ្ឌទី ១)
- ការបង្ហាញឆន្ទៈទូទាត់ ( មាត្រា ៤៦៥ កថាខណ្ឌទី ១)

## ២.២. កាតព្វកិច្ចដែលកំណត់ដោយច្បាប់

- ការគ្រប់គ្រងដោយឈឺឆ្អាល ( មាត្រា ៧២៩ ដល់មាត្រា ៧៣៥)
- សេចក្តីចម្រើនដោយឥតហេតុ ( មាត្រា ៧៣៦ ដល់មាត្រា ៧៤១)
- អំពើអនីត្យានុកូល ( មាត្រា ៧៤២ ដល់មាត្រា ៧៦៥)
- បញ្ញត្តិផ្សេងៗនៃច្បាប់ ( ឧទាហរណ៍ : កាតព្វកិច្ចបង់ពន្ធ)

# ៣. កម្មវត្ថុនៃកាតព្វកិច្ច

## ៣.១. ការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិពាក់ព័ន្ធលើវត្ថុ ឬ ប្រាក់

**ឧទាហរណ៍ : ក បានលក់ម៉ូតូឱ្យ ខ**

- ក មានកាតព្វកិច្ចផ្ទេរវត្ថុ ( ម៉ូតូ) ឬ កម្មសិទ្ធិនៃម៉ូតូ
- ខ មានកាតព្វកិច្ចប្រគល់ប្រាក់ថ្លៃទិញម៉ូតូ

### ៣.២. ធ្វើសកម្មភាពជាក់លាក់ណាមួយ

នេះ គឺជាកាតព្វកិច្ចមានគោលបំណងឱ្យធ្វើសកម្មភាព។ **ឧទាហរណ៍ :** ករណីយកិច្ចរបស់អាណត្តិគាហក (មាត្រា ៦៤០)។

### ៣.៣. មិនឱ្យធ្វើសកម្មភាពជាក់លាក់ណាមួយ

កាតព្វកិច្ចដែលមានកម្មវត្ថុមិនឱ្យធ្វើសកម្មភាពណាមួយដែលត្រូវបានឱ្យឈ្មោះថា "កាតព្វកិច្ចមានគោលបំណងមិនឱ្យធ្វើសកម្មភាព"។ ក្រមរដ្ឋប្បវេណីមិនមានចែងពីបញ្ញត្តិនេះទេ ប៉ុន្តែ វាមានសុពលភាពដោយផ្អែកទៅលើគោលការណ៍សេរីភាពក្នុងការបង្កើតកិច្ចសន្យា។

**ឧទាហរណ៍ :** កិច្ចសន្យារវាងអ្នកចម្រៀង និង ផលិតកម្មថតសម្លេង ដោយហាមអ្នកចម្រៀងមិនឱ្យច្រៀងឱ្យផលិតកម្មផ្សេង។

## ៤. ប្រភេទនៃកាតព្វកិច្ច




### ៤.១. កាតព្វកិច្ចមានគោលបំណងឱ្យធ្វើសកម្មភាព / កាតព្វកិច្ចមានគោលបំណងមិនឱ្យធ្វើសកម្មភាព

កាតព្វកិច្ចមានគោលបំណងឱ្យធ្វើសកម្មភាព គឺជាកាតព្វកិច្ចធ្វើសកម្មភាពជាក់លាក់ណាមួយ ចំណែកឯកាតព្វកិច្ចមានគោលបំណងមិនឱ្យធ្វើសកម្មភាព គឺជាកាតព្វកិច្ចមិនធ្វើសកម្មភាពជាក់លាក់ណាមួយ។

### ៤.២. កាតព្វកិច្ចប្រគល់ / កាតព្វកិច្ចធ្វើសកម្មភាព

កាតព្វកិច្ចមានគោលបំណងឱ្យធ្វើសកម្មភាព អាចត្រូវបានបែងចែកចេញជាពីរ គឺកាតព្វកិច្ចប្រគល់ និង កាតព្វកិច្ចធ្វើសកម្មភាព។ កាតព្វកិច្ចប្រគល់ គឺជាកាតព្វកិច្ចក្នុងការប្រគល់អ្វីមួយ ដូចជា វត្ថុ ជាដើម។ កាតព្វកិច្ចធ្វើសកម្មភាព គឺជាកាតព្វកិច្ចដែលកម្មវត្ថុរបស់វា គឺជាការធ្វើសកម្មភាព ឬ ការបំពេញការងាររបស់កូនបំណុលនោះផ្ទាល់តែម្តង។

### ៤.៣. កាតព្វកិច្ចជាប្រាក់ / កាតព្វកិច្ចមិនមែនជាប្រាក់

#### ៤.៣.១. កាតព្វកិច្ចជាប្រាក់

កាតព្វកិច្ចជាប្រាក់ គឺជាកាតព្វកិច្ចក្នុងការសងប្រាក់ ( មាត្រា ៣១៦) ។

នៅក្នុងករណីនៃកាតព្វកិច្ចជាប្រាក់ គេមិនអាចលើកឡើងពីអលទ្ធភាពក្នុងការអនុវត្ត ដើម្បីជៀសវាងការអនុវត្តកាតព្វកិច្ច ដោយផ្អែកលើមាត្រា ៣៩៥ កថាខណ្ឌទី ១ នោះទេ ។

#### ៤.៣.២. កាតព្វកិច្ចមិនមែនជាប្រាក់

វាជាកាតព្វកិច្ចឱ្យប្រគល់វត្ថុ ដែលមិនមែនជាប្រាក់ ។

កាតព្វកិច្ចមិនមែនជាប្រាក់ ត្រូវបានគេចែកចេញជាកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ និង កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ ។

### ៤.៤. កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ / កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

#### ៤.៤.១. កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់

វត្ថុដែលបានកំណត់ជាក់លាក់ សំដៅទៅលើវត្ថុដែលលក្ខណៈរបស់វា ត្រូវបានភាគីផ្តោតការយកចិត្តទៅលើ ។ ឧទាហរណ៍មួយនៃវត្ថុដែលបានកំណត់ជាក់លាក់ គឺនាឡិកាដៃបុរាណ ។ ចំពោះកាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់ កូនបំណុលមានករណីយកិច្ចថែរក្សាវត្ថុនោះដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ ។

#### ៤.៤.២. កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

វត្ថុកំណត់ដោយប្រភេទ មានន័យថា កម្មវត្ថុនៃការប្រគល់ត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ ។ ការកំណត់ប្រភេទនៃវត្ថុមានពីរគឺ :

- វត្ថុកំណត់មិនជាក់លាក់ ( មាត្រា ៣១៥ កថាខណ្ឌទី ១) : ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ ប្រសិនបើកម្មវត្ថុដែលត្រូវបានផ្តល់គុណភាពច្រើនយ៉ាង កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពដូចដែលគូភាគីបានកំណត់ ។ ក្នុងករណីគូភាគីមិនបានធ្វើការកំណត់គុណភាពទេ កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុ ដែលមានគុណភាពមធ្យម ។
- វត្ថុដែលត្រូវបានកំណត់ជាក់លាក់ ( មាត្រា ៣១៥ កថាខណ្ឌទី ២) : ចំពោះកាតព្វកិច្ចដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុលបានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់ និង ដែលបានបញ្ចប់សកម្មភាពចាំបាច់ ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុនោះតែប៉ុណ្ណោះ ។

### ៤.៥. ទំនាក់ទំនងរវាងកាតព្វកិច្ច និង ការអនុវត្តដោយបង្ខំ

វិធីនៃការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ច អាស្រ័យលើប្រភេទរបស់កាតព្វកិច្ច ដូចជា :

### ៤.៣. កាតព្វកិច្ចជាប្រាក់ / កាតព្វកិច្ចមិនមែនជាប្រាក់

#### ៤.៣.១. កាតព្វកិច្ចជាប្រាក់

កាតព្វកិច្ចជាប្រាក់ គឺជាកាតព្វកិច្ចក្នុងការសងប្រាក់ ( មាត្រា ៣១៦) ។

នៅក្នុងករណីនៃកាតព្វកិច្ចជាប្រាក់ គេមិនអាចលើកឡើងពីអលទ្ធភាពក្នុងការអនុវត្ត ដើម្បីជៀសវាងការអនុវត្តកាតព្វកិច្ច ដោយផ្អែកលើមាត្រា ៣៩៥ កថាខណ្ឌទី ១ នោះទេ ។

#### ៤.៣.២. កាតព្វកិច្ចមិនមែនជាប្រាក់

វាជាកាតព្វកិច្ចឱ្យប្រគល់វត្ថុ ដែលមិនមែនជាប្រាក់ ។

កាតព្វកិច្ចមិនមែនជាប្រាក់ ត្រូវបានគេចែកចេញជាកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ និង កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ ។

### ៤.៤. កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ / កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

#### ៤.៤.១. កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់

វត្ថុដែលបានកំណត់ជាក់លាក់ សំដៅទៅលើវត្ថុដែលលក្ខណៈរបស់វា ត្រូវបានភាគីផ្ដោតការយកចិត្តទៅលើ ។ ឧទាហរណ៍មួយនៃវត្ថុដែលបានកំណត់ជាក់លាក់ គឺនាឡិកាដៃបុរាណ ។ ចំពោះកាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់ កូនបំណុលមានករណីយកិច្ចថែរក្សាវត្ថុនោះដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ ។

#### ៤.៤.២. កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

វត្ថុកំណត់ដោយប្រភេទ មានន័យថា កម្មវត្ថុនៃការប្រគល់ត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ ។ ការកំណត់ប្រភេទនៃវត្ថុមានពីរគឺ :

- វត្ថុកំណត់មិនជាក់លាក់ ( មាត្រា ៣១៥ កថាខណ្ឌទី ១) : ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ ប្រសិនបើកម្មវត្ថុដែលត្រូវបានផ្ដល់គុណភាពច្រើនយ៉ាង កូនបំណុលមានករណីយកិច្ចផ្ដល់នូវវត្ថុដែលមានគុណភាពដូចដែលគូភាគីបានកំណត់ ។ ក្នុងករណីគូភាគីមិនបានធ្វើការកំណត់គុណភាពទេ កូនបំណុលមានករណីយកិច្ចផ្ដល់នូវវត្ថុ ដែលមានគុណភាពមធ្យម ។
- វត្ថុដែលត្រូវបានកំណត់ជាក់លាក់ ( មាត្រា ៣១៥ កថាខណ្ឌទី ២) : ចំពោះកាតព្វកិច្ចដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុលបានកំណត់កម្មវត្ថុដែលត្រូវផ្ដល់ច្បាស់លាស់ និង ដែលបានបញ្ចប់សកម្មភាពចាំបាច់ ដើម្បីផ្ដល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុលមានករណីយកិច្ចផ្ដល់នូវវត្ថុនោះតែប៉ុណ្ណោះ ។

### ៤.៥. ទំនាក់ទំនងរវាងកាតព្វកិច្ច និង ការអនុវត្តដោយបង្ខំ

វិធីនៃការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ច អាស្រ័យលើប្រភេទរបស់កាតព្វកិច្ច ដូចជា :

# ជំពូក១

# នីតិកាតព្វកិច្ច

## I. សញ្ញាណកាតព្វកិច្ច

កាតព្វកិច្ចដែលត្រូវបានប្រើនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មានន័យថាជាអំពើរបស់ជនម្នាក់ដែលត្រូវតែអនុវត្ត ដើម្បីជាផលប្រយោជន៍របស់ជនដទៃទៀត ប៉ុន្តែការអនុវត្តអំពើទាំងនេះវាស្ថិតនៅលើចិត្តដែលផ្អែកលើមនោសញ្ចេតនា ហើយ វាពុំមានលក្ខណៈគតិយុត្តក្នុងការចាប់បង្ខំទេ។

បើតាមផ្លូវច្បាប់ កាតព្វកិច្ចគឺជាទំនាក់ទំនងនីតិវេជ្ជបូរណៈមួយដែលជាចំណងតាមផ្លូវច្បាប់ (Lien de droit) រវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដែលនៅក្នុងនោះភាគីម្ខាងហៅថា ម្ចាស់បំណុល(Créancier) អាចបង្ខំឲ្យភាគីម្ខាងទៀតហៅថា កូនបំណុល (Débiteur) ឲ្យបំពេញតាវកាលិក[១] អ្វីមួយដូចជាឲ្យធ្វើ ឬមិនធ្វើ ដើម្បីជាផលប្រយោជន៍ស្របច្បាប់របស់ខ្លួនដែលជាម្ចាស់បំណុល។

សិទ្ធិប្រត្យក្ស ឬភណ្ឌិក (Doit réel) ត្រូវបានវិភាគដូចជាអំណាចមួយប្រព្រឹត្តផ្ទាល់ដោយមានមនុស្សម្នាក់ទៅលើវត្ថុ រីឯក្នុងសិទ្ធិបាតិបុគ្គល មានមនុស្សពីរនាក់ ដោយម្នាក់អាចតំរូវតាវកាលិកអ្វីមួយ (ម្ចាស់បំណុល) ហើយ មនុស្សម្នាក់ទៀតដែលមានកាតព្វកិច្ចអនុវត្តតាវកាលិកនោះ (កូនបំណុល)។

<u>ឧទាហរណ៍</u>: លោក ក បានឲ្យលោក ខ ខ្ចីប្រាក់ចំនួន ១០០០ USD ដោយមានកិច្ចសន្យាសងក្នុងរយៈពេល១ ឆ្នាំ រីឯការប្រាក់ ៣% ក្នុងមួយខែ ជាម្ចាស់បំណុល (ឬប្រធានសកម្ម Subject actif)។ ដល់ពេលកំណត់ លោក ក មានសិទ្ធិតំរូវឲ្យលោក ខ កូនបំណុល (ឬប្រធានអកម្ម)សងប្រាក់ដើម រួមទាំងការប្រាក់ផង។ បើមិនសងតាមកាលកំណត់ទេ លោក ក អាចប្តឹងទៅតុលាការមានសមត្ថកិច្ចដើម្បីឲ្យជំនុំជំរះចេញសាលក្រម(Un jugement) បើសាលក្រមមានអាជ្ញាអនុវត្តហើយ មានន័យថារួបមន្តអនុវត្ត លោក ក អាចសុំឲ្យតុលាការរឹបអូសទ្រព្យរបស់កូនបំណុលក្នុងខណៈពេលគ្មានប្រាក់សង ហើយដាក់លក់ដើម្បីយកប្រាក់មកសងម្ចាស់បំណុល។

## II. លក្ខណៈនៃកាតព្វកិច្ច (Caractère de l'obligation)

**កាតព្វកិច្ចគតិយុត្ត** (l'obligation juridique) : ជាចំណងរវាងមនុស្សពីរនាក់ (ប្រធាននៃកាតព្វកិច្ច) មានអំណាចបង្ខំមួយយ៉ាងពិតប្រាកដដើម្បីជំរុញឲ្យកូនបំណុលអនុវត្តកាតព្វកិច្ចរបស់គេ (កម្មវត្ថុនៃកាតព្វកិច្ច Object de l'obligation)។ វាជាកាតព្វកិច្ចច្បាប់ កាតព្វកិច្ចនេះបើមិនគោរព អាជ្ញាធរអាចបង្ខំឲ្យគោរព ហើយភាគីរង

---

១: តាវកាលិក គឺអ្វីៗដែលអ្នកជាប់កាតព្វកិច្ចត្រូវតែបំពេញ។ ឧទាហរណ៍ : តាវកាលិករបស់អ្នកទិញគឺបង់ថ្លៃអោយទៅអ្នកលក់ ឯតាវកាលិករបស់អ្នកលក់គឺប្រគល់វត្ថុអោយទៅអ្នកទិញ។

ឧទាហរណ៍ : នៅក្នុងកិច្ចសន្យាជួលសាងសង់ កិច្ចសន្យាម៉ៅការដោយជ្រើសរើសសំភារៈសំណង់ច្បាស់លាស់។
ឧទាហរណ៍ : កិច្ចសន្យាលក់-ទិញ ដែលបានកំណត់កម្មវត្ថុនៃកិច្ចសន្យានោះជាក់លាក់ហើយ។

**២-ដោយមិនអាចប្រតិបត្តិកើត**

ក្នុងករណីនេះកាលបើវត្ថុជាអង្គនៃកាតព្វកិច្ចអន្តរាយដោយគ្មានកំហុសរបស់កូនបំណុល ហើយម្ចាស់បំណុលក៏ពុំបានកំណត់កាតព្វកិច្ចផ្សេងក្រៅពីនេះដែរ ពេលដែលមានព្រឹត្តិការណ៍ដូច្នេះកើតឡើងនោះ។
ឧទាហរណ៍: កិច្ចសន្យាទិញផល្លានុផលនៅរដូវបន្ទាប់, កិច្ចសន្យាទិញកូនគោនៅក្នុងផ្ទៃរបស់មេគោ។ល។

**៣-ដោយបានផ្ដល់វត្ថុដទៃជាសំណង**

ការប្រតិបត្តិនេះកាលបើកូនបំណុលបានប្រគល់វត្ថុដទៃណាមួយ ក្រៅពីវត្ថុដែលជាប់ក្នុងកាតព្វកិច្ចឲ្យម្ចាស់បំណុលរួចហើយ ហើយម្ចាស់បំណុលក៏យល់ព្រមផងដែរ។
ឧទាហរណ៍: លោក "ក" បានឲ្យលោក "ខ" ខ្ចីប្រាក់ចំនួន ៥០០$ ដោយមានការយល់ព្រមពីឈ្មោះ "ក" លោក "ខ" បានយកម៉ូតូមួយគ្រឿងដែលជាកម្មសិទ្ធិរបស់ខ្លួនមកសងជំនួសកំចីនោះ។

**៤-ដោយមាននវកម្ម (បង្កើតកាតព្វកិច្ច)** La novation

នវកម្មសំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និងកូនបំណុលដែលរំលត់កាតព្វកិច្ចដើមនិងបង្កើតកាតព្វកិច្ចថ្មីជំនួសកាតព្វកិច្ចដើមនោះ។ នៅពេលដែលកិច្ចសន្យានវកម្មនេះបង្កើតអានុភាព នោះកាតព្វកិច្ចដើមត្រូវរលត់។ ក្នុងករណីបែបនេះដើម្បីឲ្យកាតព្វកិច្ចថ្មីកើតឡើងបាន ត្រូវតែមានការផ្លាស់ប្តូរម្ចាស់បំណុល កូនបំណុល ឬផ្លាស់ប្តូរវត្ថុ។នវកម្មអាចកើតបានពេលកូនបំណុលសុំឲ្យតតិយជនណាម្នាក់ប្រតិបត្តិកាតព្វកិច្ចជួសខ្លួន ហើយតតិយជននោះក៏ព្រមទទួលជំនួសដែរ ហើយម្យ៉ាងទៀតម្ចាស់បំណុលក៏មានការយល់ព្រមផងដែរទើបបាន។ នវកម្មនេះក៏បានដោះអ្នកធានា និងកូនបំណុលដែលជាប់កាតព្វកិច្ចចាស់ជាមួយគ្នានោះឲ្យរួចខ្លួនទាំងអស់គ្នា។

**៥-ដោយការលើកលែងកាតព្វកិច្ចចោលដោយចេតនា**

ការលើកនូវកាតព្វកិច្ចចោល គឺម្ចាស់បំណុលបានបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុលរបស់ខ្លួនចោល ករណីនេះកាតព្វកិច្ចនោះត្រូវរលត់។ ការលើកកាតព្វកិច្ចចោលនេះត្រូវមានភស្តុតាងច្បាស់លាស់ ដូចជាលិខិត ឬបង្កាន់ដៃ ឲ្យរួចផុតពីតប្រាកដ ឬគ្រាន់តែប្រគល់ប័ណ្ណបំណុលឲ្យទៅកូនបំណុលវិញ ឬក៏បំផ្លាញប័ណ្ណបំណុលនោះចោលជាអាសារបង់ក៏បាន។ ពេលនោះអ្នកធានាក៏រួចផុតពីកាតព្វកិច្ចធានាលើកូនបំណុលដែរហើយកូនបំណុលក៏រួចស្រឡះពីអ្នកធានាផងដែរ។

**៦-ដោយបានទូទាត់រួចហើយ**

ការទូទាត់សំដៅលើការរំលត់កាតព្វកិច្ចទៅវិញទៅមក ដោយយកចំនួនប្រាក់ស្មើគ្នា ក្នុងករណីដែលបុគ្គលទាំងពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក។ ដើម្បីធ្វើការទូទាត់

កាតព្វកិច្ចទាំងពីរ ត្រូវដល់ពេលកំណត់សងហើយ។ គូភាគីអាចធ្វើកិច្ចសន្យាទូទាត់ដែលរំលត់កាតព្វកិច្ចដែលគ្មានគោលបំណងប្រគេនដូចគ្នាទៅវិញទៅមកបាន។

ការទូទាត់មិនអាចនឹងធ្វើបានទេ កាលណាបើម្ចាស់បំណុលនៃកាតព្វកិច្ចនេះមិនមែនជាកូនបំណុលផ្ទាល់នៃកាតព្វកិច្ចនោះ ហើយម្ចាស់បំណុលនៃកាតព្វកិច្ចនេះក៏មិនមែនជាកូនបំណុលនោះដែរ។

<u>ឧទាហរណ៍</u>: ឈ្មោះ "ក" ជំពាក់ប្រាក់ឈ្មោះ "ខ" ២០០០០ រៀល តែឈ្មោះ "ខ" នៅជំពាក់ថ្លៃសង់ផ្ទះឲ្យឈ្មោះ "ក" ដែរ។ អ្នកទាំងពីរគិតជាបំណុលខ្លួនល្មមកាត់កងគ្នាបាន ក៏សុខចិត្តព្រមទូទាត់គ្នាមិនឲ្យជំពាក់គ្នាទៅវិញទៅមក។

**៧_ដោយបានល្បាយគុណភាពរួចហើយ** (La confusion)

គឺជាវិធីរំលត់កាតព្វកិច្ចមួយដែលបុគ្គលម្នាក់ទៀតមានឋានៈជាម្ចាស់បំណុលលើបុគ្គលម្នាក់ទៀតផង និងជាកូនបំណុលរបស់បុគ្គលនោះទៀតផង។

<u>ឧទាហរណ៍</u>: កូនបំណុលស្នងម្ចាស់បំណុល។

**៨_ដោយផុតអាជ្ញាយុកាល** (La prescription extinctive)

ជាការរំលត់នូវកាតព្វកិច្ចដែលបណ្តាលមកពីម្ចាស់បំណុលមិនអនុវត្តសិទ្ធិលើបំណុលក្នុងការប្តឹងទារអស់កាលយូរអង្វែងពេក ដែលជាហេតុផុតថេរវេលាកំណត់របស់ច្បាប់។

លើកលែងតែច្បាប់ចែងផ្សេងពីនេះ កាតព្វកិច្ចទាំងឡាយដែលកើតចេញពីកិច្ចសន្យាត្រូវផុតអាជ្ញាយុកាល កាលបើភាគីដើមបំណុលមិនប្តឹងទាមទារឲ្យអនុវត្តក្នុងកំឡុង៥ឆ្នាំ គិតពីថ្ងៃកំណត់ក្នុងកិច្ចសន្យាឬបើគ្មានកំណត់ថ្ងៃទេត្រូវគិតពីថ្ងៃចុះកិច្ចសន្យា។

អាជ្ញាយុកាលត្រូវបានផ្អាកសិន កាលបើភាគីកូនបំណុលអវត្តមានពីលំនៅស្ថានហើយអវត្តមាននេះត្រូវបានរដ្ឋអំណាចមូលដ្ឋានបញ្ជាក់ត្រឹមត្រូវតាមច្បាប់។ បណ្តឹងរបស់ភាគីដើមបំណុលក៏ត្រូវផ្អាកអាជ្ញាយុកាលនៃកិច្ចសន្យាដែរ។

កូនបំណុល ឬអ្នកធានា អាចនឹងលើកយកអាជ្ញាយុកាលមកតវ៉ាបាន។ បើកូនបំណុល ឬអ្នកធានាពុំបានលើកយកអាជ្ញាយុកាលមកតវ៉ាទេ តុលាការប្រដាប់ជនត្រូវលើកជួសសាមីខ្លួន។

ភាគីកូនបំណុល ឬអ្នកធានាដែលបានបំពេញកាតព្វកិច្ចដែលផុតអាជ្ញាយុកាលរួចទៅហើយ ពុំអាចទាមទារយកចំនួនទឹកប្រាក់ ឬតម្លៃនោះមកវិញបានឡើយ[១១]។

**៩_ការបំពេញលក្ខខណ្ឌនៃការរំលាយ**: គឺលក្ខខណ្ឌបដិសេធ។

10. [illegible]

១១: មាត្រា២៥ ដល់ មាត្រា២៨ ក្រឹត្យច្បាប់លេខ៣៨

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣*៥៥៥

កំពូល

រដ្ឋប្បវេណី

១ ខែកក្កដា ឆ្នាំ២០០៨

រឿ

# សាលដីកា

## គាមនាមប្រជារាស្ត្រខ្មែរ

ខែមីនា ឆ្នាំ២០០៩

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈនៅថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៩ ។

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឃឹម | ប៉ុណ្ណ | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៣-លោក | យស់ | សួខឿន | ជាចៅក្រម |
| ៤-លោក | យូរ | ឧត្តរា | ជាចៅក្រមរបាយការណ៍ |
| ៥-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រម |

ក្រឡាបញ្ជី

លោកស្រី អ៊ុច ឡានី

តំណាងមហាអយ្យការ

លោក ហ៊ីង ធីឫទ្ធិ ជាព្រះរាជអាជ្ញា

ដើមចោទឈ្មោះ ស (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីរាជការ ទីលំនៅសព្វថ្ងៃផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ ក្រុងភ្នំពេញ ។

ចុងចំលើយឈ្មោះ ខ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃភូមិ ឃុំ ស្រុក ខេត្ត ។

មានលោក គាត និមល និងលោក នង មានន្ទ ជាមេធាវីតំណាងដោយអាណត្តិ ។

<u>កម្មវត្ថុបណ្តឹង</u> : -ប្តឹងសុំរំលាយលិខិតផ្ទេរសិទ្ធិដីចុះថ្ងៃទី០៨-០៤-២០០៦ ។

-សុំប្រគល់ប្រាក់ចំនួន១២.០០០ដុល្លារអាមេរិកត្រឡប់ឱ្យទៅ ខ និង ស ។

**អំពីអង្គហេតុ និង ចំណុចវិវាទ :**

តាមពាក្យបណ្តឹងរបស់ដើមចោទថា ខ្លួនមានដីមួយកន្លែងទំហំ ១៨ម គុណ ៣៦ម ស្ថិតនៅភូមិផ្សារព្រំ សង្កាត់ស្ទឹងកាច់ ខណ្ឌសាលាក្រៅ ក្រុងប៉ៃលិន ដីនោះមានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវលំ ខាងកើតទល់នឹងដីរបស់ឈ្មោះទី សុខា ខាងលិចទល់នឹងផ្លូវ ដីនោះដើមចោទបានលក់ផ្តាច់ឱ្យទៅចុងចំលើយពីរនាក់ប្តីប្រពន្ធតាមលិខិតផ្ទេរសិទ្ធិដីចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៧ ក្នុងតំលៃព្រមព្រៀងគ្នា ២២.៥០០ដុល្លាអាមេរិក ដោយការទិញលក់នោះ មិនទាន់កាត់ឈ្មោះឱ្យទៅឈ្មោះ [illegible] និងឈ្មោះ [illegible] នៅឡើយ បានធ្វើត្រឹមលិខិតផ្ទេរសិទ្ធិដីតែប៉ុណ្ណោះ ។ ចាប់តាំងពីចុះកិច្ចសន្យាលក់-ទិញមក ឈ្មោះ [illegible] និងឈ្មោះ [illegible] ទើបតែបានឱ្យប្រាក់ថ្លៃលក់-ទិញ ដីនោះចំនួនពាលើក សរុបបានចំនួន ៩.៩៩៧ដុល្លាអាមេរិក ។ ឈ្មោះ [illegible] និងឈ្មោះ [illegible] បានសន្យាថា ប្រាក់ដែលនៅសល់ទាំងប៉ុន្មាននឹងប្រគល់ឱ្យខ្លួនក្នុងអំឡុងពេលពាខែក្រោយ ។ លុះដល់ថ្ងៃខានកំណត់ ឈ្មោះ [illegible] និងឈ្មោះ [illegible] មិនព្រមប្រគល់ប្រាក់ដែលនៅខ្វះតាមកិច្ចសន្យា ទើបខ្លួនប្តឹងមកតុលាការសុំរំលាយកិច្ចសន្យាលក់ទិញដីនោះវិញ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៤៥ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [illegible] ដែលបានប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេច :

-រំលាយកិច្ចសន្យាផ្ទេរសិទ្ធិដីចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៦ ដែលបានធ្វើឡើងរវាងខ្លួន (ដើមចោទ) ជាមួយនឹងឈ្មោះ [illegible] និងឈ្មោះ [illegible] (ពីរនាក់ប្តីប្រពន្ធ) ។

-ឱ្យឈ្មោះ [illegible] និងឈ្មោះ [illegible] ទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

ដែលដើមចោទបានប្តឹងសុំតាមពាក្យបណ្តឹងរបស់ខ្លួនចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧ និងបានកែសម្រួលកម្មវត្ថុបណ្តឹងក្នុងកំណត់ហេតុធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧ ។

២-ឱ្យឈ្មោះ [illegible] ជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២១៧ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៧ របស់មេធាវី ហម មុនី តំណាងឱ្យដើមចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៤៥ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២០៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ច្រានចោលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧-១០-២០០៧ របស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទឈ្មោះ [illegible] ។

តាមពាក្យបណ្ដឹងរបស់ដើមចោទថា ខ្លួនមានដីមួយកន្លែងទំហំ ១៨ម គុណ ៣៦ម ស្ថិតនៅភូមិផ្សារព្រំ សង្កាត់ស្ទឹងកាច់ ខណ្ឌសាលាក្រៅ ក្រុងប៉ៃលិន ដីនោះមានព្រំប្រទល់ ខាងជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវលំ ខាងកើតទល់នឹងដីរបស់ឈ្មោះទី សុខា ខាងលិចទល់នឹងផ្លូវ ដីនោះដើមចោទបានលក់ផ្ដាច់ឱ្យទៅចុងចំលើយពីរនាក់ប្ដីប្រពន្ធតាមលិខិតផ្ទេរសិទ្ធិដីចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៧ ក្នុងតំលៃព្រមព្រៀងគ្នា ២២.៥០០ដុល្លាអាមេរិក ដោយការទិញលក់នោះ មិនទាន់កាត់ឈ្មោះឱ្យទៅឈ្មោះ [illegible] និងឈ្មោះ [illegible] នៅឡើយ បានធ្វើត្រឹមលិខិតផ្ទេរសិទ្ធិដីតែប៉ុណ្ណោះ ។ ចាប់តាំងពីចុះកិច្ចសន្យាលក់-ទិញមក ឈ្មោះ [illegible] និងឈ្មោះ [illegible] ទើបតែបានឱ្យប្រាក់ថ្លៃលក់-ទិញ ដីនោះចំនួន៣លើក សរុបបានចំនួន ៩.៩៩៧ដុល្លាអាមេរិក ។ ឈ្មោះ [illegible] និងឈ្មោះ [illegible] បានសន្យាថា ប្រាក់ដែលនៅសល់ទាំងប៉ុន្មាននឹងប្រគល់ឱ្យខ្លួនក្នុងអំឡុងពេល៣ខែក្រោយ ។ លុះដល់ថ្ងៃទានកំណត់ ឈ្មោះ [illegible] និងឈ្មោះ [illegible] មិនព្រមប្រគល់ប្រាក់ដែលនៅខ្វះតាមកិច្ចសន្យា ទើបខ្លួនប្ដឹងមកតុលាការសុំរំលាយកិច្ចសន្យាលក់ទិញដីនោះវិញ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៤៥ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [illegible] ដែលបានប្ដឹងសុំឱ្យតុលាការចេញសាលក្រមសម្រេច :

-រំលាយកិច្ចសន្យាផ្ទេរសិទ្ធិដីចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៦ ដែលបានធ្វើឡើងរវាងខ្លួន (ដើមចោទ) ជាមួយនឹងឈ្មោះ [illegible] និងឈ្មោះ [illegible] (ពីរនាក់ប្ដីប្រពន្ធ) ។

-ឱ្យឈ្មោះ [illegible] និងឈ្មោះ [illegible] ទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី ។

ដែលដើមចោទបានប្ដឹងសុំតាមពាក្យបណ្ដឹងរបស់ខ្លួនចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧ និងបានកែសម្រួលកម្មវត្ថុបណ្ដឹងក្នុងកំណត់ហេតុធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលដោយផ្ទាល់មាត់ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៧ ។

២-ឱ្យឈ្មោះ [illegible] ជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ២១៧ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៧ របស់មេធាវី ហម មុនី តំណាងឱ្យដើមចោទ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៤៥ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២០"៨" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ច្រានចោលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧-១០-២០០៧ របស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទឈ្មោះ [illegible] ។

២-[illegible] ១៥៤ [illegible]
ខេត្តបាត់ដំបង ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [illegible] ។

៤-សាលដីកានេះប្រកាសជាសាធារណៈ នាថ្ងៃទី០៩-០៤-២០០៨ បើកផ្លូវប្តឹងសាទុក្ខ អំឡុងពេលមួយខែ គិតចាប់ពីថ្ងៃទទួលការបញ្ជូនសាលដីកានេះ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២១០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ របស់ឈ្មោះ ផាត់ ពៅសិង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២០៨ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

**ខ-អំពីសេចក្តីថ្លែងការណ៍របស់គូភាគី :**

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ [illegible] ចុះថ្ងៃទី៣០-១២-២០០៨ ។

លោក នង មាននួ ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [illegible] បានធ្វើសេចក្តីថ្លែងការណ៍ នាពេលសវនាការថា :

កូនក្តីខ្ញុំពិតជាបានចុះកិច្ចសន្យាទិញដីពីដើមចោទប្រាកដមែនក្នុងតំលៃព្រមព្រៀង២២.៥០០ ដុល្លាអាមេរិក ហើយកូនក្តីខ្ញុំបានប្រគល់ប្រាក់ដល់ដើមចោទចំនួនពាលើករួចហើយ សរុបបានចំនួន ២១.០០០ដុល្លាអាមេរិកហើយ ។ នៅខ្វះតែ ១៥០០ដុល្លាអាមេរិកប៉ុណ្ណោះ ដែលដើមចោទ និងកូនក្តីខ្ញុំបានព្រមព្រៀងគ្នាថា ទុកកាត់ឈ្មោះផ្ទេរសិទ្ធិដីមកឱ្យភាគីកូនក្តីខ្ញុំ ទើបប្រគល់ប្រាក់គ្រប់ចំនួន ។ កូនក្តីខ្ញុំពុំមានចេតនាគេចវេសពីការអនុវត្តកាតព្វកិច្ចកិច្ចសន្យាទេ ។ ហើយភាគីលី សារឿន មិនបានដាក់មូលហេតុនៃបណ្តឹងសាទុក្ខក្នុងការតវ៉ាទេ ។

កាងនាមខ្ញុំជាមេធាវីតំណាងដោយអណត្តិឱ្យ [illegible] សំណូមពរ សុំឱ្យក្រុមប្រឹក្សាជំនុំជំរះច្រានចោលពាក្យបណ្តឹងសាទុក្ខ និងសុំតំកល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

លោក តាត និមល ជាមេធាវីតំណាងដោយអណត្តិឱ្យឈ្មោះ [illegible] បានធ្វើសេចក្តីថ្លែងការណ៍ នាពេលសវនាការថា :

ខ្ញុំឯកភាព និងការសន្និដ្ឋានរបស់លោកមេធាវី នង មាននួ ទាំងស្រុង ។

**គ-អំពីចំណុចវិវាទ :**

តើការដែលដើមចោទប្តឹងសុំរំលាយកិច្ចសន្យាលក់ដីចុះថ្ងៃទី០៨-០៤-២០០៦ ដោយសំអាងថា ចុងចំលើយបានបង់ប្រាក់មិនគ្រប់ចំនួននោះ ត្រឹមត្រូវដែរឬទេ ?

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សាលាបរបស់ដើមចោទ និងសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងចុងចំលើយ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២១០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ របស់លោក ផាត់ ពៅស៊ាង មេធាវីតំណាងដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនិងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

- យល់ឃើញថា ការដែលដើមចោទប្តឹងសុំរំលាយកិច្ចសន្យាលក់ដីចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៦ ដោយសំអាងថា ចុងចំលើយបានបង់ប្រាក់មិនគ្រប់ចំនួននោះ គឺមិនត្រឹមត្រូវទេ ពីព្រោះថា :

.គូភាគីទទួលស្គាល់កិច្ចសន្យាលក់ដីចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៦ ក្នុងតំលៃ២២.៥០០ ដុល្លារអាមេរិក ។

.នៅពេលទាញហេតុផលផ្ទាល់មាត់នៅតុលាការខេត្តបាត់ដំបង សាក្សីដែលបានផ្តិតមេដៃនៅលើកិច្ចសន្យានោះបានបញ្ជាក់ថា ខ្លួនពិតជាបានឃើញ ចុងចំលើយប្រគល់ប្រាក់ចំនួន១០.០០០ ដុល្លារអាមេរិក ឱ្យទៅដើមចោទ នៅថ្ងៃចុះកិច្ចសន្យានោះ ។

.ដើមចោទទទួលស្គាល់ការវេប្រាក់ចំនួនពីរលើក សរុប ១០.០០០ដុល្លា ប៉ុន្តែខ្លួនទទួលបានតែចំនួន ៩៩៧៧ដុល្លា ដោសារកាត់ថ្លៃផ្ទេរប្រាក់ ។

.ចុងចំលើយបានអះអាងអំពីការប្រគល់ប្រាក់បន្ថែមចំនួន១០០០ដុល្លា នៅសណ្ឋាគារតេអូ ដែលចំណុចនេះមិនមានការតវ៉ាពីដើមចោទទេ ។

.តាមភស្តុតាងខាងលើឃើញថា ចុងចំលើយបានបង់ប្រាក់ចំនួន ២១.០០០ដុល្លា ឱ្យទៅដើមចោទរួចហើយ នៅសល់តែចំនួន ១៥០០ដុល្លាទៀតតែប៉ុណ្ណោះ ដែលប្រាក់នេះចុងចំលើយនឹងបង់បង្គ្រប់នៅពេលដែលដើមចោទរត់ការផ្ទេរឈ្មោះបាន ។ ដូច្នេះមិនមានភស្តុតាងណាដែលបញ្ជាក់ថា ចុងចំលើយមានចេតនាមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាចុះថ្ងៃទី០៨ ខែមេសាឆ្នាំ២០០៦ នោះទេ ។ ផ្ទុយទៅវិញ ដើមចោទទេដែលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ពីព្រោះថា ជាគោលការណ៍ អ្នកលក់មានករណីយកិច្ចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញ ។ ដូច្នេះមិនមានមូលហេតុដែលត្រូវរំលាយកិច្ចសន្យាចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៦ ទេ ។

- យល់ឃើញថា ការដែលលោកមេធាវីតំណាងដើមចោទសុំពន្យាពេលសវនាការនេះ ដោយសំអាងថា ខ្លួនមានបេសកកម្មទៅរតនៈគិរីនោះ តុលាការកំពូលមិនអាចសម្រេចតាមសុំនេះបានទេ ។ម៉្យាងទៀត ដើមចោទបានពឹងពាក់មេធាវីឱ្យធ្វើជាតំណាងតាមច្បាប់រួចហើយ ប៉ុន្តែមិន

...នេះទេ តុលាការកំពូលអាចជំនុំជំរះបាន ។

-យល់ឃើញថា សាលដីការបស់សាលាឧទ្ធរណ៍លេខ២០"ជ" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីទាំងមុខគ្គភាគី ប៉ុន្តែចាត់ទុកជាទំនោះមុខ

១-ច្រានចោលបណ្តឹងសាទុក្ខលេខ ២១០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ របស់លោក ផាត់ ពៅស៊ាង មេធាវីតំណាងដើមចោទ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ២០"ជ" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូល ជាបន្ទុករបស់ដើមចោទ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ ។

| | |
|---|---|
| ឯកឧត្តម ឃឹម ប៉ុណ្ណ | ប្រធាន |
| លោក ឈឹម ស៊ីផល | ចៅក្រម |
| លោក យស់ សូខឿន | ចៅក្រម |
| លោក យូរ ឧត្តរា | ចៅក្រម |
| លោក ម៉ុង មុន្នីចរិយា | ចៅក្រម |
| លោកស្រី អ៊ួង ឡានី | ក្រឡាបញ្ជី |

---

ជាវ៉

បានឃើញ

ភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០០៩

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

ឃឹម ប៉ុណ្ណ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០០៩

ក្រឡាបញ្ជី

អ៊ួង ឡានី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាមនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ: ៣១៤

ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២

សាលដីកា

លេខ: ១៤១

ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឌិត | មុន្ទី | ជាប្រធាន |
| ២-លោក | ស៊ិន | ឌិច | ជាចៅក្រម |
| ៣-លោក | ជីវ | កេង | ជាចៅក្រម |
| ៤-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៥-លោក | ឃេស់ | សួរឡិន | ជាចៅក្រម |

ក្រឡាបញ្ជី

កញ្ញា គុក សុខគុណ

តំណាងមហាអយ្យការ

| | | |
|---|---|---|
| ឯកឧត្តម ជួន | ស៊ិនឡេង | ជាអគ្គព្រះរាជអាជ្ញារង |
| លោក ម៉ុង | មុន្នីចរិយា | ជាចៅក្រមរបាយការណ៍ |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ១២៥ "ឈ" ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣១១ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រាជធានី :

ដើមចោទឈ្មោះ (ជាចុងបណ្តឹងសាទុក្ខ) តំណាងដោយឈ្មោះ អាយុ ២៩ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៣ ផ្លូវ២៦៥ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

ចុងចំលើយឈ្មោះ (ម្ចាស់បណ្តឹងសាទុក្ខ) តំណាងដោយប្រពន្ធឈ្មោះស្រីជានី មុខរបរ ជាម្ចាស់ភោជនីយដ្ឋាន ត្រីស៊ីណាថវី ទីលំនៅផ្ទះលេខ ៨១ ផ្លូវ៦៣ សង្កាត់បឹងកេងកង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

លោក ឈិត បូរ៉ាវុធ ជាមេធាវីការពារ ។

តតិយជន : លោក ជាតំណាងឱ្យក្រុមហ៊ុន Cambodia H.K Garment (LTD) អាស័យដ្ឋានផ្ទះលេខ ៤០៧ដ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

កញ្ញា ប៉ៅ សំវុទ្ធារី ជាបេតវិការពារ ។

**កម្មវត្ថុបណ្តឹង** : ប្តឹងសុំរំលាយកិច្ចសន្យាជួលឃ្លាំង

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣១៤ ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០២ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣១០ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះ ស្រី ដានី តំណាងឱ្យចុងចំលើយ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១២៥"ឈ" ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០០ របស់ឈ្មោះមាស សុគន្ធ បានប្តឹងរំលាយកិច្ចសន្យាចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដោយហេតុថា កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដើមចោទបានចុះកិច្ចសន្យា ជួលឃ្លាំងមួយទំហំ ២២ម x ៦៥ម ឱ្យក្រុមហ៊ុនត្រីស្តីណា ដែលមានលោក ជាតំណាងមានរយៈពេលជួល ១០ឆ្នាំ ។ ភាគីអ្នកជួល គឺខាងលោក លឹមឡេង មិនគោរពតាមកិច្ចសន្យា តែងតែមានការយឺតយ៉ាវក្នុងការបង់ប្រាក់ឈ្នួលជានិច្ច ហើយមកដល់ខែកក្កដា-សីហា ឆ្នាំ២០០០ នេះឈ្មោះ លឹម ឡេង នៅតែមិនព្រមបង់ប្រាក់ឈ្នួលឱ្យទៀត ដោយមិនព្រមអនុវត្តន៍តាមកាតព្វកិច្ចរបស់ខ្លួនឡើយទើបខ្លួនប្តឹងសុំឱ្យតុលាការសំរេចរំលាយកិច្ចសន្យាជួលឃ្លាំងលេខ៤៤ នេះចោលជាអសារបង់ ។

តាមបណ្តឹងតបចុះថ្ងៃទី០៧-៩-២០០១របស់ឈ្មោះ ជាតំណាងក្រុមហ៊ុនត្រីស្តីណា បានបញ្ជាក់ថា ខ្លួនប្តឹងទាមទារ :

១-ប្រាក់កក់ចំនួន៨ខែ

២-សងប្រាក់កំរៃចំនួន ១២៦.០០០ដុល្លា ជាប្រាក់ថ្លៃជួលឃ្លាំងបន្តរយៈពេល ៧ឆ្នាំ

៣-ប្រាក់ចំនួន ៥៤.០០០ដុល្លា ដែលភាគីម្ចាស់ឃ្លាំងទទួលយកលើសពីភាគីវេង ឈុនសាំង

៤-ប្រាក់ជំងឺចិត្តចំនួន ២០.០០០ដុល្លា ។

ការទាមទារខាងលើនេះ ភាគីខាងដើមបណ្តឹងតបបានសំអាងថា កិច្ចសន្យាជួលឃ្លាំងរវាងក្រុមហ៊ុនខ្លួន និងភាគីលោក . អ្នកស្រី ជាម្ចាស់ឃ្លាំងពិតជាបានកើតឡើងប្រាកដមែន ដែលមានរយៈពេលជួល១០ឆ្នាំ ក្នុងតំលៃ ៣.០០០ដុល្លា ក្នុង១ខែ ហើយតាមកិច្ចសន្យាភាគីខ្លួនបានកក់មុនចំនួន ៨ខែហើយ ។ ចាប់ពីពេលបង្កើតកិច្ចសន្យា ភាគីទាំងពីពុំមានបញ្ហាអ្វីនឹងគ្នា

ឡើយ ទើបតែមានកើតទំនាស់នៅក្នុងខែ០៦ និង ខែ០៧ ដោយមានការបង់ប្រាក់ថ្លៃឈ្នួលយឺតយ៉ាវ ហើយភាគីខាងអ្នកស្រី មាស សុគន្ធ ជាកពិន័យចំនួន៣% ក្នុង១ថ្ងៃ ។ ក្នុងរយៈពេលនោះ លោក លឹម ម៉េង បានលើកឡើងថា ខ្លួនបានទៅព្យាបាលរោគនៅប្រទេសបារាំង ។ ទំនាស់នេះរវាងភាគីទាំងពីរ បានធ្វើការចរចារគ្នានៅចំពោះមុខរាជធានីសង្កាត់ម៉ីកព្នកំពា ហើយក៏បានការព្រមព្រៀងគ្នាក្នុងការធ្វើវិសោធនកម្មកិច្ចសន្យា ត្រង់ចំណុចស្តីពីប្រាក់ពិន័យ ដោយហេតុថា កិច្ចសន្យាបានធ្វើឡើងជាពីរភាសា ហើយមានអត្ថន័យខុសគ្នា ។ ភាគីខ្លួនបានយកប្រាក់ថ្លៃឈ្នួលខែ៧ ទៅតម្កល់ទុកនៅសង្កាត់ ។ តែភាគីម្ចាស់ឃ្លាំងបានបដិសេធ មិនព្រមធ្វើការដោះស្រាយហើយប្តឹងមកតុលាការតែម្តង។

តាមពាក្យសុំចុះថ្ងៃទី ០១-០២-២០០១ របស់តតិយជន គឺក្រុមហ៊ុន Cambodia H.K Garment (LTD) បញ្ជាក់ថា ខ្លួនបានធ្វើកិច្ចសន្យាជាមួយភាគីលោក ជាតំណាងក្រុមហ៊ុនត្រីស្ទ័ណាក្នុងការជួលឃ្លាំងដែលបោះទីតាំងស្ថិតនៅផ្ទះលេខ៤៤ ផ្លូវ២៦៥សំរាប់រយៈពេល ៥ឆ្នាំ ក្នុងតំលៃ៤៥០០ដុល្លាអាមេរិក ក្នុងមួយខែ ហើយខ្លួនបានកក់មុនចំនួន ៥៤.០០០ដុល្លារអាមេរិក ក្រោយមកខ្លួនបានទទួលដីកាសំរេចតាមពាក្យសុំលេខ ៥៤ ក ចុះថ្ងៃទី០៧-៥-២០០០ ដែលបង្គាប់ឱ្យខ្លួនយកប្រាក់តម្កល់ទុកនៅតុលាការក្រុងភ្នំពេញព្រោះឃ្លាំងនេះជាកម្មវត្ថុទំនាស់រវាងឈ្មោះលឹមម៉េង និងម្ចាស់ឃ្លាំង ។ ហើយហេតុការណ៍នេះ បានធ្វើឱ្យខ្លួនខាតបង់ប្រាក់កក់ជាច្រើន ដូចនេះសំណូមពរ

- រំលាយកិច្ចសន្យារវាងខ្លួន និងលោក លឹម ម៉េង
- ទាមទារប្រាក់កក់
- សុំជួលបន្ត
- ទាមទារជំងឺចិត្ត ៥.០០០ដុល្លា ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៥ ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេចសេចក្តីដូចតទៅ :

១-ក.ទទួលពាក្យបណ្តឹងចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០០ របស់ឈ្មោះ ប្តឹងសុំរំលាយកិច្ចសន្យាចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ពីក្រុមហ៊ុនត្រីស្ទ័ណា ដែលមានលឹម ម៉េង ជាតំណាងទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

ខ.ទទួលពាក្យសុំចូលជាតតិយជន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០១ របស់លោក និងលោកស្រី មេធាវីតំណាងឱ្យឈ្មោះ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់

២-ក.រំលាយចោលជាអសារបង់នូវកិច្ចសន្យា ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ ដែលបានធ្វើឡើងរវាងឈ្មោះ និងប្រពន្ធឈ្មោះ ជាមួយក្រុមហ៊ុនត្រីស្ទ័ណា ដែលមានលោក ជាតំណាង ។

ខ.រំលាយចោលជាអសារបង់នូវកិច្ចសន្យាចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលធ្វើឡើងរវាងឈ្មោះវេង ជាមួយក្រុមហ៊ុនត្រីស្ទ័ណាមានលោក ជាតំណាង ។ តាមមាត្រា ១០៧ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៣-ក.បង្គាប់ឱ្យក្រុមហ៊ុនត្រីស្ទ័ណា ដែលមានឈ្មោះ ជាតំណាង សងសំណងឱ្យទៅដើមចោទឈ្មោះ គឺ:

ប្រាក់ឈ្នួលឃ្លាំងចំនួនពីរខែគឺខែកក្កដា និងខែសីហា ឆ្នាំ២០០០ ចំនួន៦.០០០ដុល្លារអាមេរិក (ប្រាំមួយពាន់ដុល្លារអាមេរិក) ជំងឺចិត្តចំនួន ៦.០០០ដុល្លារអាមេរិក(ប្រាំមួយពាន់ដុល្លារអាមេរិក) សរុបចំនួន ១២.០០០ដុល្លារអាមេរិក (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ប្រាក់នេះត្រូវកាត់យកពីប្រាក់ ចំនួន ២៤.០០០ដុល្លារអាមេរិក (ពីរម៉ឺនបួនពាន់ដុល្លារអាមេរិក) ដែលចុងចំលើយឈ្មោះ បានកក់ទុកនៅដើមចោទ រួចហើយប្រាក់នៅសល់១២.០០០ដុល្លារអាមេរិក (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក) ត្រូវប្រគល់ឱ្យចុងចំលើយវិញ ។

ខ.រឹបអូសប្រាក់ដែលតុលាការបានឃាត់ទុកពីឈ្មោះ តំណាងឱ្យឈ្មោះ មួយខែ ៣.០០០ដុល្លារអាមេរិក ។

តាមដំណាចដីកាចារលើពាក្យសុំលេខ ៥៤ "ក" ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០០ ដោយបានចាប់អនុវត្តពីខែកញ្ញា ឆ្នាំ២០០០ រហូតមក ឱ្យឈ្មោះមាស សុគន្ធ ដែលជាម្ចាស់ឃ្លាំង ។

ក.បង្គាប់ឱ្យក្រុមហ៊ុនត្រីស្ទ័ណា ដែលមានលោក ជាតំណាង សងសំណងឱ្យទៅឈ្មោះវេង ជាតភ័យជន ដែលមានឈ្មោះ និងម៉ៅសិរីវុទ្ធី ជាតំណាងគឺ :

ប្រាក់កក់ចំនួន ៥៤.០០០ ដុល្លារអាមេរិក ជំងឺចិត្តចំនួន ៣.០០០ ដុល្លារអាមេរិក សរុប ៥៧.០០០ ដុល្លារអាមេរិក តតិយជនទាមទារលើសពីនេះបដិសេធចោល ។ ក្នុងករណីក្រុមហ៊ុនត្រីស្ទ័ណា ដែលមានឈ្មោះ ជាតំណាងគ្មានប្រាក់សង ត្រូវរឹបអូសប្រាក់កក់ចំនួន១២.០០០ដុល្លារអាមេរិក ដែលសល់ពីការទូទាត់ឱ្យឈ្មោះ និងរឹបអូសទ្រព្យសម្បត្តិក្រុមហ៊ុនត្រីស្ទ័ណាលក់ឡាយឡុងដើម្បីយកប្រាក់ទូទាត់សំណងបង្គ្រប់តាមច្បាប់ ។ តាមមាត្រា១នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ៥១ក្រ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៩២ ។

៤-អនុញ្ញាតិឱ្យឈ្មោះ មានសិទ្ធិជួលឃ្លាំងម្ចាស់ឃ្លាំង ដើមចោទឈ្មោះមាស សុគន្ធ តាមការព្រមព្រៀងរបស់គូភាគី ។

៥-ឱ្យក្រុមហ៊ុនត្រីស្ទ័ណា ដែលមានឈ្មោះ ជាតំណាងបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្វ៊ីងចំនួន១.៨០០រៀលរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០រ ចំណាយក្នុងកិច្ចស៊ើបសួរចំនួន៥.០០០រ សរុប៧.០០០រ ។ប្រាក់នេះកាត់យកពីប្រាក់ដើមចោទបង់រួចហើយ បើសាល

ក្រមចូលជាស្ថាពរ ឱ្យចុងចំលើយសងប្រាក់ទៅដើមចោទវិញនិងឱ្យបង់ពន្ធសមាមាត្រ១៥ លើទឹកប្រាក់សំណង និង ជំងឺចិត្តដែលត្រូវសងឱ្យទៅ និង ឈ្មោះ ប្រាក់នេះដាក់ចូលថវិការជាតិចំនួន ៨០៥ និងដាក់ចូលកេរ្តិ៍ប្រាក់ ក្រសួងយុត្តិធម៌ទាំងប្រទេសចំនួន២០៥ បើសាលក្រមនេះចូលជាស្ថាពរ ។ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ៣៧ក្រ ចុះថ្ងៃទី ០៨-០៧-១៩៩៣ ។

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទ និងតំណាងតតិយជន និង កំបាំងមុខចុងចំលើយ ទុករយៈពេលប្តឹងទាស់និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០១របស់ឈ្មោះឌី បូរ៉ា មេធាវីតំណាងឱ្យឈ្មោះលិម ឡេង មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៩"ក" ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ លើចំណុចសាលក្រមទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១០៨"ក" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេចសេចក្តីដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០១ របស់មេធាវីឌីបូរ៉ា ជាមេធាវី ការពារ និង ជាតំណាងឱ្យលោក ភាគី"ខ"ចំពោះសាលក្រមកំបាំងមុខលេខ ១៩"ក" ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ និងត្រឹមត្រូវតាមគតិច្បាប់ខ្លះ ទាស់ខុស និងគតិច្បាប់ខ្លះ ។

២-បដិសេធសាលក្រមកំបាំងមុខលេខ ១៩ "ក" ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ចោលហើយសំរេចសេចក្តីជាថ្មីដូចខាងក្រោម :

ក-រំលាយប្រការទី៩ នៃកិច្ចសន្យាចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ជាកាសារអង់គ្លេសត្រង់អត្ថន័យឱ្យបង់ប្រាក់ជាកពិន័យ ៣៥ ក្នុង១ខែ លើថ្លៃឈ្នួលឃ្លាំងក្នុងមួយខែ ៣.០០០ដុល្លាអាមេរិក (មាត្រា ៩ នៃរដ្ឋធម្មនុញ្ញ ) ។

ក១.រំលាយកិច្ចសន្យាចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ រវាងភាគី "ក" និង មាស សុគន្ធ ជាមួយភាគី"ខ" តំណាងក្រុមហ៊ុនត្រីស្ទ័ណាចោល (មាត្រា ១០៩ នៃច្បាប់កិច្ចសន្យា ) ។

ក២.បង្គាប់ឱ្យក្រុមហ៊ុនត្រីស្ទ័ណា មានលោក ជាតំណាងសងប្រាក់ថ្លៃឈ្នួលឃ្លាំងពីរខែ គឺខែកក្កដា និងខែសីហា ឆ្នាំ២០០០ ចំនួន៦.០០០ដុល្លាអាមេរិក និងជំងឺចិត្ត២.០០០ដុល្លាអាមេរិក សរុបចំនួន ៨.០០០ដុល្លាអាមេរិក ឱ្យទៅឈ្មោះ និង ដែលមាន ឈ្មោះម៉ៃ វ៉ាន់ឌី ជាតំណាងដោយឱ្យគាត់យកពីប្រាក់កក់០៨ខែ ចំនួន ២៤.០០០ដុល្លាអាមេរិកដែល

លោក បានកក់នៅដៃដើមចោទឈ្មោះ និងឈ្មោះ ។ ឯប្រាក់កក់នៅសល់ចំនួន ១៦.០០០ដុល្លារអាមេរិក ឈ្មោះ និង ត្រូវប្រគល់ឱ្យឈ្មោះ ជាតំណាងក្រុមហ៊ុនត្រីស្ទីណា វិញ ។ ជំងឺចិត្តដើមចោទ ស៊ុំលើសពី២.០០០ដុល្លារអាមេរិក បដិសេធចោល ។

ក៣. រិបអូសប្រាក់ឈ្នួលឃ្លាំងជួលបន្តដែលតុលាការរិបអូស ឃាត់ទុកពីឈ្មោះ ជាតំណាងនៃឈ្មោះវេង ឈុនស៊ាំង ក្នុង១ខែ ៣.០០០ដុល្លារអាមេរិក ចាប់ពីខែកញ្ញា ឆ្នាំ២០០០ រហូតមក តាមដីកាសំរេចតាមពាក្យសុំលេខ៩៤ ក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០០ ប្រគល់ឱ្យទៅឈ្មោះ និង ទុកជាថ្លៃឈ្នួលឃ្លាំង ។ ប្រាក់ឈ្នួលឃ្លាំងសល់ពីនេះ ១.៥០០ដុល្លារអាមេរិករៀងរាល់ខែ ត្រូវប្រគល់ឱ្យទៅឈ្មោះលឹម ឡេង តំណាងក្រុមហ៊ុនត្រីស្ទីណាជាអ្នកជួលឃ្លាំងបន្តឱ្យឈ្មោះ ។

ខ-ទទួលពាក្យសុំចូលជាតតិយជនចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០១ របស់លោកវេងឈុនស៊ាំង មានមេធាវីហែម ហូរណារិទ្ធិ និងកញ្ញា ប៉ោ សំសុទ្ធារី ជាតំណាងទុកជាត្រឹមត្រូវ ។

ខ១. រំលាយចោលនូវកិច្ចសន្យាជួលឃ្លាំងបន្តចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧រវាងលោកលឹម ឡេង តំណាងក្រុមហ៊ុនត្រីស្ទីណា ជាមួយលោក វេង ឈុនស៊ាំង មានឈ្មោះចូវ កាពីន ជាតំណាងចោល ។

ខ២. បង្គាប់ឱ្យលោក លឹម ឡេង ជាតំណាងក្រុមហ៊ុនត្រីស្ទីណា ប្រគល់ប្រាក់កក់ ៥៤.០០០ ដុល្លារអាមេរិកឱ្យទៅលោក មានលោក ជាតំណាងវិញ ប្រសិនបើគ្មានប្រាក់សងត្រូវរិបអូសប្រាក់នៅសល់ ១.៦០០ដុល្លារអាមេរិក ដែលនៅសល់ពីការខ្វះទាត់ឱ្យឈ្មោះ និង រិបអូសថ្លៃឈ្នួលឃ្លាំងរៀងរាល់ខែ ដែលតុលាការបានឃាត់ទុកតាមអំណាចដីកាសំរេចតាមពាក្យសុំលេខ ៩៤ ក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០០ ដើម្បីទូទាត់សំណងខាងលើ ។

ខ៣. អនុញ្ញាតិឱ្យលោក មានសិទ្ធិជួលឃ្លាំងទំនាស់បន្តពីម្ចាស់ឃ្លាំងស្វូ សាមឿន និង មាស សុគន្ធ តាមការព្រមព្រៀង ។

៣-ឱ្យលោកលឹម ឡេង តំណាងក្រុមហ៊ុនត្រីស្ទីណា បង់ប្រាក់ប្រដាប់ក្តី៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ប្រដាប់ក្តី៧.០០០៛ របស់ដើមចោទដាក់ថវិកាជាតិ និង ចំណាយផ្សេងៗរួចហើយ ហើយតំរូវឱ្យ តំណាងឱ្យក្រុមហ៊ុនត្រីស្ទីណា សងប្រាក់នេះឱ្យទៅដើមចោទវិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រ ១% លើចំនួនប្រាក់ដែលលោក តំណាងក្រុមហ៊ុនត្រីស្ទីណាត្រូវសងទៅលោកស្វូ សាមឿន និងអ្នកស្រី ។

៤-សាលក្រមនេះ សំរេចសេចក្តី និងប្រកាសជាសាធារណៈនៅចំពោះមុខតំណាងដើមចោទ មេធាវី តំណាងចុងចំលើយ និង មេធាវីតំណាងតតិយជន ។ បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេលពីរខែ

គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០២ របស់មេធាវីឌី ប៊ូរ៉ា តំណាងឲ្យឈ្មោះ មិនសុខចិត្តសាលក្រមលេខ ១០៨ "ក" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០២ របស់ម៉ៅ សំរុទ្ធារី មេធាវីតំណាងឲ្យក្រុមហ៊ុន Cambodia H.K ជាតតិយជនខាងភាគីដើមចោទមិនសុខចិត្តសាលក្រមលេខ ១០៨ "ក" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ ត្រង់ចំណុចទី៣ សេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១២៥"ឈ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០២របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០២របស់លោកមេធាវីឌីប៊ូរ៉ា ការពារឲ្យភាគីចុងចំលើយឈ្មោះ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ របស់ឈ្មោះម៉ៃ វ៉ាន់ធី តំណាងឲ្យភាគី ជាដើមចោទ និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ របស់មេធាវី ម៉ៅ សំរុទ្ធារី ការពារឲ្យតតិយជន ឈ្មោះ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១០៨"ក" ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្វ៉ឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទ តំណាងតតិយជន កំបាំងមុខចុងចំលើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣១០ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះ តំណាងឲ្យចុងចំលើយ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១២៥"ឈ" ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះ តំណាងឲ្យចុងចំលើយ ។

បានឃើញសារណាការពារចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០០២ របស់ឈ្មោះម៉ៅ សំរុទ្ធារីជាមេធាវីតំណាងឲ្យក្រុមហ៊ុន Cambodia H.K Garment(LTD) ។

បានឃើញសារណាតបចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០០២ របស់ឈ្មោះម៉ៃ វ៉ាន់ធី តំណាងឲ្យ

ដើមចោទ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ សាលដីកាជួបប្រណីលេខ១២៥ "ឈ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីបកនេះ មាន លក្ខណៈខុសឆ្គងទាំងទំរង់ និងគតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និង សំរេច ។

បានស្តាប់ចំលើយរបស់អ្នកស្រី បានឆ្លើយនាពេលសវនាការថា ៖ បានជាខ្ញុំបប្តឹង មិនសុខចិត្តគឺបណ្តាលមកពីភាគីខាង ប្តឹងរំលាយកិច្ចសន្យា ។ ក្នុងរឿងនេះភាគីខ្ញុំបាន ធ្វើតាមកិច្ចសន្យារហូតមកមិនដែលយឺតយ៉ាវទេ ទើបតែនៅខែមិថុនា ឆ្នាំ១៩៩៨គឺយឺត២០ថ្ងៃបណ្តាល មកពីប្តីខ្ញុំឈឺ ទៅព្យាបាលនៅស្រុកបារាំង ហើយខ្ញុំក៏បានទៅប្រាប់គាត់ដែរ ហើយគាត់ក៏យល់ព្រម ហើយគាំទ្រឱ្យខ្ញុំបង់ពិន័យ ក្នុងការយឺតយ៉ាវនេះ ៣% ក្នុងមួយថ្ងៃ គិតជាទឹកប្រាក់ ១៨០០ដុល្លា ។ ប៉ុន្តែនៅក្នុងកិច្ចសន្យាព្រោះភាពខុសគ្នា រវាងកិច្ចសន្យាជាភាសាខ្មែរដាក់៣%ក្នុង១ថ្ងៃ តែក្នុងកិច្ចសន្យា ជាភាសាអង់គ្លេស ដាក់ ៣% ក្នុង១ខែ ប្តីខ្ញុំបានប្តឹងទៅសង្កាត់សុំកែប្រែប្រាក់ជាកពិន័យពី៣%ក្នុង ១ថ្ងៃ មក ១% ក្នុងមួយថ្ងៃវិញ ហើយយើងក៏បានឯកភាពគ្នានៅចំពោះមុខលោក ជាចៅ សង្កាត់ទឹកល្អក់៣ ក្រោយពីការសម្រុះសម្រួលគ្នា ខ្ញុំក៏យកប្រាក់ទៅបង់ថ្លៃឈ្នួលខែកក្កដា ឆ្នាំ២០០០តែ អ្នកស្រី មិនព្រមទទួល ហើយប្តឹងទៅតុលាការ សុំរំលាយកិច្ចសន្យានេះ ។

បានស្តាប់ចំលើយឈ្មោះ បានឆ្លើយនាពេលសវនាការថា ៖ ចំពោះបញ្ហានេះ ខ្ញុំ សុំជំរាបតុលាការថា លោក បានអាក់ខាន ដោយមិនគោរពកិច្ចសន្យា ហើយមានការបង់ ពិន័យមកខាងភាគីខ្ញុំដោយមានការព្រមព្រៀងពីអ្នក តែលោក បានមកទារយក ប្រាក់ពិន័យនេះវិញ ធ្វើឱ្យមានបញ្ហាជាមួយគ្នាទើបអ្នកស្រី ប្តឹងសុំរំលាយកិច្ចសន្យានេះ ។ ម្យ៉ាងទៀតភាគីលោក តែងតែយឺតយ៉ាវ ក្នុងការបង់ប្រាក់ឈ្នួលប្រចាំខែជានិច្ច ខ្ញុំសូម ជំរាបថា គាត់យកឃ្លាំងទៅជួលបន្តក្នុង១ខែ បានប្រាក់៤៥០០ដុល្លាអាមេរិក ហើយត្រូវបង់ឱ្យភាគីខ្ញុំ តែ៣.០០០ដុល្លាអាមេរិកទេ ហើយខាងក្រុមហ៊ុនជួលបន្តគេបង់ឱ្យរាល់ខែ ចុះហេតុអ្វីបានជាគាត់មាន ការខកខាន ។ ខ្ញុំសុំឱ្យតុលាការកំពូល តំកល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់តតិយជនតំណាងឱ្យក្រុមហ៊ុន Cambodia H.K ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ជាមេធាវីការពារឱ្យចុងចំលើយនាពេល សវនាការថា ៖ ការដែលមាស សុគន្ធ ប្តឹងនេះធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរណាស់ដល់កូនក្តីខ្ញុំ កន្លងមក មាស សុគន្ធបានទទួលប្រាក់បង់ប្រចាំខែចំនួន ១៤ខែ រួចមកហើយកូនក្តីខ្ញុំ មិនបានបំពានលើកិច្ច-សន្យា ហើយមិនបំពេញកាតព្វកិច្ចនោះទេ ចំពោះការអាក់ខាន គឺដូចកូនក្តីខ្ញុំបានលើកឡើងអញ្ចឹង។

លោក ប៉ៃ វ៉ាន់ឌី បានលើកឡើងនេះពុំពិតទេ ហើយចំពោះការអាក់ខាននោះគឺកូនក្តីខ្ញុំបានបង់ប្រាក់ពិន័យនោះហើយ ។ការសំរេចរបស់តុលាការ គឺសំរេចលំអៀងតែម្តង ព្រោះរឿងអង្គសេចក្តីមិនទាន់ចប់ផង តុលាការសំរេចឱ្យភាគី ទៅបើកប្រាក់ដែលតំកល់ទុកនោះយក ។

ខ្ញុំសុំឱ្យតុលាការបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសុំឱ្យពិចារណាលើបណ្តឹងតបរបស់ភាគីកូនក្តីខ្ញុំ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់កញ្ញា ម៉ៅ សំវុទ្ធាវី ជាមេធាវីការពារឱ្យតតិយជន នាពេលសវនាការថា : ក្នុងការជួលឃ្លាំងបន្តនេះ កូនក្តីខ្ញុំមិនបានអាក់ខានក្នុងការបង់ប្រាក់ថ្លៃជួលនោះទេ។ នៅថ្ងៃមួយកូនក្តីខ្ញុំបានទទួលដីកាពីតុលាការក្រុងឱ្យគាត់យកលុយមកបង់នៅតុលាការវិញ ធ្វើឱ្យខាតពេលវេលា ប៉ះពាល់ដល់ការវិនិយោគរបស់ក្រុមហ៊ុន គឺគាត់មិនចង់ឱ្យកម្មករភ្ញាក់ផ្អើល ដែលមានប្រកាសយកទៅបិទនៅឃ្លាំងអញ្ចឹង ហើយជាពិសេស គឺគាត់មិនចង់ទៅបង់លុយនៅតុលាការទេ ។

សុំតុលាការតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់តំណាងគូភាគី សារណារបស់តតិយជន និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីចុងចំលើយ និង តតិយជន ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣១០ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០២ របស់អ្នកស្រី ស្រ៊ីជានី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤នៃច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចលោពកិច្ចសន្យាចុះថ្ងៃទី -១៩៩៧ រវាងលោក និង ជាមួយក្រុមហ៊ុនគ្រីស្ទីណា ព្រមទាំងកិច្ច ចុះថ្ងៃទី ១៦-១១-១៩៩៧ រវាងក្រុមហ៊ុនគ្រីស្ទីណា ជាមួយលោក និង លោក ជាតំណាងក្រុមហ៊ុន Cambodia H.K Garment ហើយអនុញ្ញាតអោយឈ្មោះ ជួលឃ្លាំងបន្តពីឈ្មោះ ដោយផ្អែកលើចំលើយរបស់ឈ្មោះ ជាចៅសង្កាត់ទឹកល្អក់ ទី៣ ដែលថា ឈ្មោះ ពុំបានយកប្រាក់ថ្លៃឈ្នួលឃ្លាំងខែកក្កដា-សីហា មកបង់ឱ្យដើមចោទនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះតាមលិខិតប្រគល់ទទួលប្រាក់ចុះថ្ងៃទី២៩-០៧-២០០០លោក គង់ សារ៉ូ បានចុះហត្ថលេខា ថាបានឃើញ និងឯកភាពលើលិខិតនេះ ដែលមានខ្លឹមសារថា ក្រោយ

ពីបាងដោះស្រាយតាមសន្ដិវិធីនៅចំពោះមុខចៅសង្កាត់រួចមក លោក បានយកប្រាក់ថ្លៃឈ្នួលឃ្លាំង ខែកក្កដា ឆ្នាំ២០០០ មកប្រគល់ឱ្យភាគី "ក" តាមកិច្ចព្រមព្រៀងហើយដែលលោកមេធាវីបានបញ្ជាក់នៅខាងក្រោមថាអ្នកស្រីមាស សុគន្ធ ពុំព្រមយកទេ ។ ដូច្នេះលោកលឹមឡេងពុំមានកំហុសក្នុងការខកខានមិនព្រមបង់ថ្លៃឈ្នួលឃ្លាំងខែកក្កដា ខែសីហា ឆ្នាំ២០០០ទេ ។

- យល់ឃើញថា លោក ត្រូវបានទទួលការពិន័យតែម្ដងគត់ពីដើមចោទ ដែលតាមប្រការ៩ និងប្រការ៩ នៃកិច្ចសន្យាជួលឃ្លាំងចុះថ្ងៃទី១២-១១-១៩៩៧ រវាងក្រុមហ៊ុនត្រីស្តារជាមួយ និងអ្នកស្រី លោក ពុំមានកំហុស ដែលអាចឱ្យតុលាការសំរេចទុកជាមោឃៈកិច្ចសន្យានេះបានទេ ។

- យល់ឃើញថា ការដែលតំណាងតតិយជន លើកឡើងក្នុងសារណាថា ភាគី បង្កបញ្ហា ធ្វើឱ្យភាគីតតិយជន ខាតពេលវេលា និងផលប្រយោជន៍ដ៏ធំធ្ងរបំផុតនិងបាត់បង់ប្រាក់កក់ចំនួន ៩៤.០០០ដុល្លាអាមេរិកនោះ ជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា ទោះបីជាគ្មានដីការបស់តុលាការឱ្យយកប្រាក់ឈ្នួលទៅតំកល់ទុកនៅតុលាការ ក៏លោកវេងឈុនសាំងត្រូវតែបោះភាគព្វកិច្ចយកប្រាក់ឈ្នួលឃ្លាំងប្រចាំខែ ទៅបង់ឱ្យលោក ដែរ ។ ឯប្រាក់ ៩៤.០០០ដុល្លារអាមេរិកក៏ពុំគេបាត់បង់ដែរ ព្រោះត្រូវកាត់កងនឹងឈ្នួលឃ្លាំងរយៈពេល ១២ខែ ។ ដូច្នេះលោក ពុំមានកំហុសដែលអាចនាំឱ្យលុបកិច្ចសន្យាចុះថ្ងៃទី១៦-១១-១៩៩៧ ជួយតតិយជនបានឡើយ ។

- យល់ឃើញថា ចុងចំលើយបានប្ដឹងសារទ្រឡប់តាំងពីតុលាការថ្នាក់ក្រោម ប៉ុន្តែទាំងតុលាការក្រុង ក៏ដូចជាសាលាឧទ្ធរណ៍ ពុំទាន់បានពិចារណា អំពីបណ្ដឹងនេះឡើយ ។

- យល់ឃើញថា តំណាងតតិយជនបានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាឧទ្ធរណ៍លេខ ១២៥"ឈ" ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីបកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដី ចំពោះមុខបើកទោស ចុងចំលើយ**

**កំបាំងមុខតតិយជន ប៉ុន្តែ ចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្ដឹងសាទុក្ខលេខ ៣១០ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០២ របស់អ្នកស្រី តំណាងឱ្យលោក ទុកជាត្រឹមត្រូវទាំងទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១២៥ "ឈ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣១៤ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០២របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ដែលចុងចំលើយ បានបង់ទុកនៅតុលាការកំពូលចំនួន១៥.០០០រៀល

-ពន្ធចុះបញ្ជីក្តី និងពន្ធភ្លើងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីការដែលបានប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៥.០០០រៀល ។

ហើយត្រូវឱ្យដើមចោទ សងប្រាក់ ១៥.០០០រៀល ទៅចុងចំលើយវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៣ ។

| | | | |
|---|---|---|---|
| ឯកឧត្តម ឌិត | | មុន្ទី | ប្រធាន |
| លោក | ស៊ុន | ឌឹប | ចៅក្រម |
| លោក | ជីវ | កេង | ចៅក្រម |
| លោក | សោម | សិរីវឌ្ឍ | ចៅក្រម |
| លោក | យស់ | សូខឿន | ចៅក្រម |
| កញ្ញា | ហុក | សុខពុល | ក្រឡាបញ្ជី |

---

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញៈ ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៣

ក្រឡាបញ្ជី

បានឃើញ

ភ្នំពេញ ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៣

ប្រធាន